ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Mar-2017, 15:12
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥**

**ម៉ោង ១០:០៥នាទី**

**សវនាការលើកទី២៣១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា រ៉ូប៊ីន្នី ក្រហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់*(Mr. Dale Lysak)*

លោក សាលីម ណាកចាវ៉ានី
*(Mr. Salim Nakhjavani)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារក្តីលោក នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារក្តីលោក ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោក យីគាំង លូ *(Mr. Yiqiang LIU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក យីគាំង លូ | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | <អង់គ្លេស> |
| កញ្ញា អង់តា ហ្គី<ស>សេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក មាស សុខា (2-TCW-936) | ខ្មែរ |
| លោកស្រី អ៊ុំ សុផានី (2-TCCP-296) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ មាស សុខា** (2-TCW-936)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ ទំព័រ ៨

សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ ទំព័រ ២០

សួរដោយកញ្ញា អង់តា ហ្គិ<ស>សេ ផ្តើមពី ........................................ ទំព័រ ៣០

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ អ៊ុំ សុផានី** (2-TCCP-296)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៤៣

សួរដោយលោក យីគាំង លូ ផ្តើមពី ........................................ ទំព័រ ៤៧

# កិច្ចដំណើរការនីតិវិធី

[១០:០៥:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនិតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី មាស សុខា បន្តបញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-296។ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែកសាក្សី មាស សុខា និងដើមបណ្ដឹងរដ្ឋប្បវេណី 2-TCP-296 មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលនូវកំណត់ហេតុពិនិត្យសុខភាពមុនពេលសវនាការព្រឹកនេះរបស់វេជ្ជបណ្ឌិតប្រចាំការទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក បានពិនិត្យឃើញថាស្ថានភាពទូទៅមានលក្ខណៈល្អ តែលោក នួន ជា គឺមានការ អាការៈឈឺចង្កេះពេលអង្គុយយូរ និងមានអាការៈវិលមុខ ហើយផ្ដល់អនុសាសន៍ឲ្យគាត់បន្តស្ដាប់ តាមដានស្ដាប់សវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ហើយទន្ទឹមនឹងនេះដែរ អង្គជំនុំជម្រះបានទទួលលិខិតលះបង់សិទ្ធិចូលរួមសវនាការរបស់ជនជាប់ចោទ នួន ជា ដោយគាត់បង្ហាញអំពីសុខភាពមិនអំណោយផល ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន ហើយដើម្បី ក្នុងការចូលរួមសវនាការនៅក្នុងពេលថ្ងៃនេះ ហើយគាត់សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសវនាការនៅថ្ងៃនេះ។ ហើយគាត់ធានាបញ្ជាក់ថាកិច្ចដំណើរ ការសវនាការនេះគឺ គាត់យល់ដឹងអំពីបញ្ហា គឺអំពីភាពមិនប៉ះពាល់នៃការលះបង់សិទ្ធិ ហើយគាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនអាចបកស្រាយថាការលះបង់សិទ្ធិហ្នឹង គឺរបស់គាត់ហ្នឹង គឺនាំឲ្យមានការកាត់ក្តីដោយអយុត្តិធម៌ទេ។ បានន័យថា គាត់ទទួលស្គាល់ថា ការលះបង់សិទ្ធិហ្នឹង គឺមិនមានលទ្ធភាពក្នុងការបកស្រាយផ្ទុយពីភាពដំណើរការយុត្តិធម៌របស់អង្គជំនុំជម្រះដែលកំពុងដំណើរការនេះទេ។

[១០:០៨:៥៨]

ហើយបន្ទាប់ពីបានឃើញនូវលិខិតរបាយការណ៍របស់ពេទ្យដែលបានបញ្ជាក់ពីសុខភាពនិងបានឃើញលិខិតលះបង់សិទ្ធិចូលរួមសវនាការរបស់លោក នួន ជា អង្គជំនុំជម្រះយល់ព្រម និង អនុញ្ញាតឲ្យលោក នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះដោយ លោក នួន ជា បានលះបង់សិទ្ធិចូលរួមកិច្ចដំណើរសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះហើយ និងបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍មកភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមស្ថិតនៅសាលសវនាការនេះ ក្នុងអំឡុងពេលកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាកិច្ចបន្តអង្គជំនុំជម្រះ បានទទួលព័ត៌មានថាមានសំណើសុំមួយរបស់មេធាវីការពារក្តី នួន ជា មានបំណងលើកឡើងពាក់ព័ន្ធនឹងបញ្ហាមួយដែលខ្លួនមានបំណងលើកឡើងរយៈពេលប្រាំនាទី។ សូមអញ្ជើញលោកមេធាវីការពារក្តី នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម លោកស្រីមេធាវី។ ប្រហែលជាខ្ញុំត្រូវការលើកសារណា១០នាទី។ បញ្ហាទាំងអស់នេះ គឺទាក់ទងទៅនឹងសក្ខីកម្មដែលសាក្សីបានផ្តល់ម្សិលមិញនិងខែកន្លងមក។ <ជាជំហររបស់យើង> សាក្សីរូបនេះគឺលោក សុខា បាននិយាយកុហក។ គាត់បាននិយាយកុហកអំពីឧក្រិដ្ឋកម្មដែលគាត់អះអាងថាបានឃើញនៅក្រាំងតាចាន់។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី កូប៉េ សម្រាកសិន!

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមអភ័យទោសដែលខ្ញុំត្រូវងើបឈរ ព្រោះថាយើងត្រូវតែជំទាស់ជាចាំបាច់ចំពោះនីតិវិធីនេះ

ព្រោះថាសារណានេះ គួរតែធ្វើនៅក្នុងអ៊ីម៉ែលដែលយើងបានផ្សព្វផ្សាយ ហើយយើងបានកត់សម្គាល់។ ដូច្នេះ នេះគឺជាមិនមែនពេលដែលយើងងើបឡើង ហើយយើងលើកអំពីទឡ្ហីករណ៍ បង្ហាញអំពីភាពអាចជឿជាក់បានរបស់សាក្សី។ ដូច្នេះគឺថា ខ្ញុំមិនអាចមិនជំទាស់បាននោះទេ។

ដូច្នេះពេលវេលានេះ គឺជាពេល -- មិនមែនជាពេលវេលាដែលព្រះរាជអាជ្ញា និង មេធាវីការពារក្តីលើកឡើងអំពីភាពមិនអាចជឿជាក់បាននៃសាក្សីនោះឡើយ។ ដូច្នេះ ខ្ញុំគិតថានេះមិនមែនជាពេលវេលាសមស្របសម្រាប់មេធាវីការពារក្តីងើបឡើង ហើយមកជំទាស់ទៅលើភាពអាចជឿជាក់បាននៃសាក្សីបែបនេះនោះឡើយ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីជាតិ តំណាង នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:១២:១៤]

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និង ភាគី។ ពេលដែលព្រឹកមិញដែលខ្ញុំមើលអ៊ីម៉ែលទៅ ខ្ញុំមានការភ្ញាក់ផ្អើលដែលអង្គ -- លោក លោកស្រីចៅក្រម អនុញ្ញាត។ ហើយខ្ញុំយល់ថាករណីនេះ គឺជាករណីដែលលោកប្រធានធ្លាប់បានហាមឃាត់មិនឲ្យមានការធ្វើការសន្និដ្ឋានទៅលើភាពជឿជាក់ ទៅលើសាក្សីក្នុងដំណាក់កាលនេះ ហើយលោកប្រធាន យើងមានវិធានលេខ៩២ នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យភាគីធ្វើនៅពេលសេចក្តីសន្និដ្ឋានចុងក្រោយជាលាយលក្ខណ៍អក្សរ។ ដូច្នេះខ្ញុំគិតថា ការធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងភាពជឿជាក់នៅពេលនេះ មិនមែនជាពេលសមស្របទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញលោក កូប៉េ។ លោកមានបំណងអ្វីឆ្លើយតបទៅនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីនាំមុខជាតិដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទលោកប្រធាន យើងមានសំណើមួយ គឺស្នើសុំសួរដេញដោលទៅលើសាក្សីនេះ គឺយើងត្រូវការពេលវេលាបី។<>ម៉ោង<បន្ថែមទៀត>។ ហេតុអ្វីបានយើងត្រូវការពេលបីម៉ោង? <យើងចង់បង្ហាញអំពីហេតុផល> ព្រោះថាយើងមិនចង់លើកឡើងអំពីសារណា<លើការវាយតម្លៃសាក្សី>នោះទេ

<ព្រោះ>នេះ<មិនមែន>ជាពេលវេលានិងជាទីកន្លែង ដែលយើង<គួរ>ធ្វើ<បែបនេះទេ>។ ហើយខ្ញុំចង់ពន្យល់ចំពោះអង្គជំនុំជម្រះថា ហេតុអ្វីបានជាខ្ញុំត្រូវការពេលវេលាបន្ថែមនេះ។ ដូច្នេះ ខ្ញុំគិតថាសារណាដែលខ្ញុំលើកឡើងនេះ គឺតែប្រាំ ទៅដប់នាទីប៉ុណ្ណោះ។ ហើយវាជាពេលវេលា ក៏ដូចជាទីកន្លែងដ៏សមស្របដែលខ្ញុំអាចធ្វើបាន ព្រោះវាទាក់ទងទៅ<ដោយផ្ទាល់>នឹងសាក្សីនេះ។ ប្រសិនបើ<មិនដូច្នេះទេ តើ>លោកប្រធាន<ចង់ឲ្យខ្ញុំលើកឡើងនៅពេលណាវិញ?>។

**ប្រធានអង្គជំនុំ៖**

លោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមានសំណួរទៅលើមេធាវី។ តើនេះគឺជាទស្សីករណ៍ដែលលោកចង់បង្ហាញជូនអង្គជំនុំជម្រះ ដោយសារតែវាជាលទ្ធផលដែលលោកទទួលបានកាលពីម្សិលមិញ ឬមួយក៏<លទ្ធផលដែលលោកបានដឹងជាយូរ>កន្លងមកហើយ?

**លោក វ៉ិចទ័រ កូប៉េះ៖**

<ទេ> ទេ លោកស្រីចៅក្រម ហ្វេនស៍ <ទើបតែដឹងម្សិលមិញនេះទេ>។ សូមអរគុណលោកប្រធាន ខ្ញុំនឹងបន្ត។

យើងជឿជាក់ថា លោក សុខា មិនដែលឃើញអំពីការធ្វើទារុណកម្មចំពោះអ្នកជាក់ស៊ីក្លូធាត់ម្នាក់ ដែលត្រូវគេច្រកដោយថង់ប្លាស្ទិកនោះឡើយ។ យើងជឿជាក់ថា គាត់បង្កើតរឿងនេះឡើង គាត់ប្រឌិតរឿងនេះឡើង។ កាលដែលគាត់មិនអាច--

[១០:១៥:០០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី យើងមិនអនុញ្ញាតឲ្យលោកធ្វើសេចក្ដីសន្និដ្ឋានថាសាក្សីនិយាយ ឬផ្ដល់សក្ខីកម្មភូតកុហកក្នុងកិច្ចពិភាក្សាដេញដោលនៅក្នុងសវនាការនេះឡើយ! វាជាការបំភិតបំភ័យ ឬក៏ជាការធ្វើឲ្យសាក្សីបាត់បង់នូវជំនឿជាក់ក្នុងការផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

ចំពោះការពិនិត្យវាយតម្លៃភស្តុតាង វាជាឆន្ទានុសិទ្ធិ វាជាឥស្សរចិត្តរបស់អង្គជំនុំជម្រះនៅក្នុងច្បាប់ជាតិ ក៏ដូចជានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក។ លោកអាចដំណើរការសួរសាក្សីបាន សុំឲ្យតែលោកតាំងសំណួរឲ្យបានត្រឹមត្រូវ ច្បាស់លាស់បានហើយ ចៀសវាងសាក្សីមានការយល់ច្រឡំ!

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការឈ្លេចសួរដេញដោលម្សិលមិញ គឺយើងអាចយល់បានអំពីនីតិវិធី ជាបច្ចេកទេស ឬក៏យុទ្ធសាស្ត្ររបស់មេធាវីក្នុងការតាំងសំណួរ ជាសិទ្ធិ។ ប៉ុន្តែកម្រិតមួយគឺថាសូមឲ្យភាគីពាក់ព័ន្ធគឺតាំងសំណួរឲ្យបានត្រឹមត្រូវ ហើយសមស្រប។ សំណួរណាដែលប្រើប្រាស់នៅក្នុងប្រព័ន្ធតុលាការកម្ពុជានេះ ជាពិសេសគឺដំណើរការនៅ អ.វ.ត.ក នេះតែម្តង។

[១០:១៦:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៩:៣៩]

**ចៅក្រម ក្ល្លឌា ហ្វេនស៍៖**

នេះជាសំណួរបន្ថែមទៅលើមេធាវី មុននឹងយើងសម្រេច យើងមានសំណើ<>សុំចុងក្រោយ គឺសូមពន្យារម៉ោងបន្ថែមបីម៉ោង។ ដូច្នេះយើងក៏ត្រូវសួរផងដែរអំពីអ្វីដែលពាក់ព័ន្ធ គឺបានន័យថា លោកគិតថា ថាតើសំណួរដែលលោកសួរនោះ ថាវាអាចពាក់ព័ន្ធឬអត់ ប្រសិនបើលោកមិនត្រូវប្រាប់យើងខ្ញុំស្តាប់នៅទីនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ នោះហើយជាគោលបំណងរបស់ខ្ញុំ មុនពេលខ្ញុំត្រូវបានកាត់ផ្តាច់ដោយមិនចាំបាច់។> វិធីសាស្ត្រតែមួយដើម្បីបង្ហាញតុលាការនេះថា សាក្សីនេះមិនអាចជឿជាក់បាន គឺ<សួរគាត់អំពីព័ត៌មានលម្អិត គឺព័ត៌មានលម្អិតទាក់ទងទៅនឹងព្រឹត្តការណ៍ដែលគាត់ថាបានឃើញផ្ទាល់ភ្នែកនោះ។> ដូច្នេះប្រសិនបើគាត់មិនអាចរៀបរាប់អំពីព័ត៌មានលម្អិតនៃហេតុការណ៍នេះ គឺថាគាត់មិនអាចជឿជាក់បាន។ ដូច្នេះ មានតែការសួរនាំបែបនេះទេ ទើបយើងអាចបង្ហាញជូនអង្គជំនុំជម្រះ និងលោក លោកស្រីចៅក្រមថា គាត់មិនអាចជឿជាក់បាន។ <តើលោកស្រីចង់ឲ្យខ្ញុំធ្វើអ្វីក្រៅពីហ្នឹងទៀត?>

**ចៅក្រម ក្ល្លឌា ហ្វេនស៍៖**

អ៊ីចឹង លោកចង់មានន័យថា លោកចង់សួរដដែលៗទៅលើហេតុការណ៍នេះអស់រយៈបីម៉ោង?

[១០:២១:00]

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនទេ <ខ្ញុំសឹងតែបញ្ចប់ការតាំងសំណួរទាក់ទងទៅនឹងហេតុការណ៍នោះទៅហើយ។> សំណួររបស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងអ្វីដែលគាត់អះអាងថា គាត់បានដឹង បានឮ បានឃើញ ទាក់ទងទៅនឹង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការធ្វើទារុណកម្ម។ ដូច្នេះ សំណួររបស់ខ្ញុំ គឺខ្ញុំនឹងសួរគាត់អំពី<ព័ត៌មានលម្អិត> ដែលថាគាត់ឃើញគេបោកក្អេងនឹងគល់ឈើ ការសម្លាប់រង្គាល។ នេះគឺជាចេតនារបស់ខ្ញុំក្នុងការសួរនាំទៅលើគាត់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ដែលថាមេធាវីការពារក្តីទទួលបានពេលវេលាដូចខាងព្រះរាជអាជ្ញាទេ ប៉ុន្តែចំពោះខ្ញុំៗគិតថាប្រហែលជាគួរតែទទួលបានត្រឹមមួយម៉ោង ទៅមួយម៉ោង<១៥នាទី>ប៉ុណ្ណោះ មិនមែនបីម៉ោងនោះទេ។ និយាយដោយត្រង់ទៅមេធាវីអាចប្រើប្រាស់ពេលវេលាដែលគាត់ចង់បាន ប៉ុន្តែចំពោះខ្ញុំអ្វីដែលគាត់បានចំណាយមួយម៉ោងកាលពីម្សិលមិញ គឺវាអត់ប្រយោជន៍។ ការសួរអំពីហេតុការណ៍លម្អិត<នៃ>រយៈពេលមួយថ្ងៃ ចំពោះសាក្សី<ដែលបាននៅក្នុងនេះរយៈពេលពីរឆ្នាំនោះ> គឺយើងអាចធ្វើត្រឹមតែប្រាំនាទី<>គឺវាគ្រប់គ្រាន់ហើយ។ <មិនគួរមាននរណាម្នាក់ភ្ញាក់ផ្អើលទេ ដែលមនុស្សម្នាក់ ៣០ឆ្នាំក្រោយ នៅចងចាំ>អំពីការច្រកថង់ប្លាស្ទិក<នរណាម្នាក់ ឬចងចាំអំពីការសម្លាប់នរណា ប៉ុន្តែមិនចងចាំអ្វីបន្ថែមទៀត ដែលមានសារៈសំខាន់តិចតួច ដូចជា> <> សួរថាតើជនរងគ្រោះហ្នឹងមានទម្ងន់ប៉ុន្មាន? សក់ពណ៌អ្វី? <ពាក់ស្រោមជើងពណ៌អី>? ខ្ញុំគិតថាវាមិនពាក់ព័ន្ធនោះឡើយ។ ដូច្នោះ វាដូចជាមិនចាំបាច់នោះឡើយដោយត្រូវផ្តល់បីម៉ោងទៅដល់សាក្សី។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំមិនជំទាស់ទេ ប្រសិនបើតុលាការ<ឲ្យគេ>រយៈពេល<>មួយម៉ោង<១៥នាទី>ឲ្យស្មើ ដូចដែលផ្តល់ឲ្យសហព្រះរាជអាជ្ញា។

[១០:២២:៥៤]

**ប្រធានអង្គជំនុំ៖**

ចុះខាងលោកក្រុមមេធាវីការពារក្តីលោក ខៀវ សំផន វិញ ទំនងជាត្រូវការចំណាយពេលវេលាប្រហែលប៉ុន្មានទៅ? អាចប៉ាន់ប្រមាណបានទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន យើងបានពិភាក្សាគ្នាជាមួយមេធាវី គង់ សំអុន យើងទាំងពីរនាក់ហ្នឹង យើងត្រូវការពេលវេលាប្រហែលជាមួយម៉ោង។ បើសិនជាមានសំណួរមួយចំនួនដែលខាងមេធាវីលោក កូប៉េគាត់សួរហើយនុ៎ង ប្រហែលជាអាចត្រូវការពេលវេលាតិចជាងហ្នឹងទេ។ ប៉ុន្តែបើអត់ទេ យើងត្រូវការ

ពេលប្រហែលជាមួយម៉ោងទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីសហមេធាវីនាំមុខអន្តរជាតិ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានការជំទាស់ទៅលើរបៀបប្រើពេលវេលារបស់ភាគីការពារក្ដីទេ គឺថាគេមានសិទ្ធិចោទសំណួរអីក៏បានដែរ ក៏ប៉ុន្តែខ្ញុំមានការជំទាស់ទៅលើការផ្ដល់ពេលវេលាបន្ថែមទៅឱ្យខាងការពារ។ ខ្ញុំសូមរំឭកទៅអង្គជំនុំជម្រះ ហើយនិងភាគី និងសាធារណជនផងដែរ គឺថាៗ <យើងបានធ្វើ>ការស៊ើបអង្កេតដែលវាមានពេ<ល>បីបួនឆ្នាំមកហើយ។ <ក្នុងអំឡុងពេលនោះ> ខាងការពារក្ដីគួរតែ<បាន>ចោទ<សួរ>សំណួរ<>ទាំងអស់ហ្នឹង<>។ អ៊ីចឹង <អ្វីដែលខ្ញុំព្រួយបារម្ភនៅថ្ងៃនេះគឺថា> បើសិន<គ្រប់សាក្សីទាំងអស់> ខាងការពារក្ដីត្រូវការពេលវេលាបន្ថែម ដើម្បីធ្វើតេស្តលើភាពជឿជាក់របស់សាក្សីនេះ ពីព្រោះថាគាត់ហ្នឹងមិនបានស៊ើបតាំងពីមុនមក ក្នុងដំណាក់កាលស៊ើបអង្កេតហ្នឹង <ពេលដែលគេមានលទ្ធភាពអាចសួរបាន>។ អ៊ីចឹងបានន័យថា <សវនាការ>មិនងាយចប់ទេ ការកាត់ក្ដី ព្រោះថាការងារត្រូវធ្វើពីមុន គាត់មិនព្រមធ្វើ។ អ៊ីចឹង សូមឱ្យអង្គជំនុំជម្រះពិចារណាត្រង់ការខកខាននេះផង ពេលដែលខ្លួនធ្វើសេចក្ដីសម្រេចនៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យតំណាងសហព្រះរាជអាជ្ញាអន្តរជាតិនិយាយម្ដងទៀតទេ។ រឿងតែមួយសុំនិយាយតែម្ដងបានហើយ។

ឥឡូវនេះអង្គជំនុំជម្រះសម្រេចថា ពេលវេលាសម្រាប់ក្រុមមេធាវីការពារក្ដីទាំងពីរក្រុមមានពេលវេលាចាប់ពីពេលនេះតទៅ រហូតដល់សម្រាកអាហារថ្ងៃត្រង់ម៉ោងដប់ពីរនេះ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីចូលបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:២៦:៥៧]

**ប្រធានអង្គជំនុំ៖**

សួស្ដីលោក មាស សុខា! ឥឡូវនេះ យើងបន្តការស្ដាប់សក្ខីកម្មរបស់លោកបន្តបញ្ចប់នៅព្រឹកនេះ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីដើម្បីតាំងសំណួរដល់លោក យើងសូមរំឭក

ដល់លោកថា សូមឲ្យលោកស្តាប់នូវសំណួរឲ្យបាន ហើយចំ ហើយឆ្លើយឲ្យចំទៅនឹងសំណួរដែលគេសួរ ក្នុងក្របខ័ណ្ឌចាំបាច់ពេញលេញចំពោះសំណួរដែលសួរ ជៀសវាងឆ្លើយចេញផុត ហួសពីភាពចាំបាច់នៃសំណួរដែលត្រូវសួរ។ ទី២ ប្រសិនបើសំណួរណាមិនច្បាស់លាស់ លោកអាចស្នើសុំឲ្យអ្នកសួរហ្នឹងតាំងសំណួរចំពោះលោកសាជាថ្មីម្តងទៀតកុំឲ្យលោកឆ្លើយទៅមានការភាន់ច្រឡំ ដើម្បីសន្សំពេលវេលាផង ដើម្បីឲ្យតម្លៃនៃការផ្តល់សក្ខីកម្មហ្នឹង គឺងាយក្នុងការវិភាគ ក្នុងការពិចារណារបស់អង្គជំនុំជម្រះផង ជាប្រយោជន៍ដើម្បីស្វែងរកការពិត។ សង្ឃឹមថាលោកស្តាប់យល់អំពីអ្វីដែលយើងបានណែនាំនេះ។

បាទ ជាបន្តនេះអង្គជំនុំជម្រះសូមផ្តល់វេទិកានេះជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។

សូមអញ្ជើញ!

[១០:២៨:១៧]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរបីបួនទៀត ទាក់ទងទៅនឹងហេតុការណ៍ដែលលោកបានរៀបរាប់កាលពីម្សិលមិញ។ គឺហេតុការណ៍ដែលលោកបានឃើញ ដែលថាជាអ្នកធាក់ស៊ីក្លូ ត្រូវបានគេធ្វើទារុណកម្មច្រកថង់ប្លាស្ទិក ដែលថាលោកបានឈរនៅក្បែរចង្ក្រានបាយ។ តើលោកនៅចាំទេថាតើម្តាយលោកមានវត្តមាន ឬក៏នៅក្បែរនោះទេ នៅពេលដែលលោកបានមើលឃើញហេតុ-ការណ៍ហ្នឹង?

**លោក មាស សុខា៖**

**ឆ៖** បាទ ខ្ញុំ វត្តមាននៅទីនោះ។ ម្តាយខ្ញុំអត់បានវត្តមាននៅទីនោះទេ។ គាត់នៅក្រៅបរិវេណទីកន្លែងហ្នឹង ព្រោះកន្លែងចង្ក្រានបាយហ្នឹង ចង្ក្រានបាយអ្នកគេ កន្លែងពួកអង្គរក្សគេអ្នកចម្អិនគ្នាគេទេ ព្រោះមិនមែនចង្ក្រានបាយអ្នកទោសទេ។

**ស៖** ថាតើបងប្អូនប្រុសស្រីរបស់លោកដែលថានៅទីនោះដែរ ពួកគេនៅកន្លែងណាពេលនោះ?

**ឆ៖** ប្អូនខ្ញុំ ដឹងក្តីវានៅខាងក្រៅ វាអត់ដឹងអីទេ ព្រោះវាក្មេងតូចគេអត់ឲ្យនៅជិតហ្នឹងទេ ឲ្យនៅលេងកៀនរបងខាងជើង។

[១០:៣០:០០]

**ស៖** តើលោកអាចប្រាប់តុលាការបានទេ ថាតើចម្ងាយកន្លែងពីលោកឈរ ទៅនឹងកន្លែងគេកើត

ហេតុហ្នឹង តើជាកន្លែងប្រហាក់ប្រហែលគ្នា ប្រហែលទៅចម្ងាយអគារឃុំខ្លួនដែរឬទេ? ឬក៏លោកអាចប្រាប់បានទេ ថាតើអ្នកទោសទាំងនោះ អាចបានឮពីអ្វីៗដូចលោកបានឮដែរឬទេ?

**ឆ៖** មិនអាចឮបានទេ ពីព្រោះពេលគេសួរចម្លើយ គេត្រូវតែចាក់ភ្លេង ឬក៏ចាក់ចម្រៀង ចាក់ចម្រៀងភ្លេងជាតិរបស់គេនោះ។

**ស៖** ឥឡូវនេះ តើជាសក្ខីកម្មរបស់លោក គឺថានៅពេលដែលគេសួរចម្លើយអតីតអ្នកធាក់ស៊ីក្លូនោះ គេចាក់ភ្លេង។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ពេលគេសួរចម្លើយតែងតែចាក់ភ្លេង ចាក់ចម្រៀងហ្នឹងហើយ។

**ស៖** សំណួរចុងក្រោយលោកសាក្សី។ ថាតើ តើអាចទៅរួចទេ ដែលថាលោកអាចឮការសួរចម្លើយរបស់អ្នកសួរចម្លើយ ហើយនិងចម្លើយរបស់អ្នកធាក់ស៊ីក្លូនោះបាន នៅពេលដែលគេចាក់ភ្លេងឮកងរំពងបែបនោះ ហេតុអីក៏លោកឮបាន? តើលោកពន្យល់កើតទេ?

**ឆ៖** ព្រោះគេចាក់ភ្លេង គេចាក់សំដៅទៅតែអគារអ្នកជាប់ទោស។ អត់ឲ្យអ្នកទោសហ្នឹងឮ។ គេមិនឲ្យអ្នកដទៃឮ ក្រៅពីអ្នកទោសសួរចម្លើយ គេត្រូវតែយកទៅសួរ។ អ្នកនៅស្ងៀម គឺគេអត់ឲ្យឮ។

**ស៖** ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលណាស់លោកសាក្សី។ ខ្ញុំ<បានទៅមើលបរិវេណគុកនោះ ហើយ>ខ្ញុំគិតថាផ្ទះបាយនោះ ហើយនិងអគារគុកនោះ គឺនៅក្នុងបរិវេណជិតគ្នា។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:៣២:៤១]

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់នឹងមេធាវីការពារក្តីដែល<>ធ្វើសក្ខីកម្មពីទីតាំង<>ខ្លួនឯងអ៊ីចឹង។ <មានរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ដែលមានផែនទី និងគំនូសពន្យល់អំពីបរិវេណគុកនេះ។ វាមិនសមរម្យសម្រាប់មេធាវីការពារក្តីក្នុងការធ្វើសក្ខីកម្មខ្លួនឯង អំពីបញ្ហាបរិវេណគុកនោះទេ។> ខ្ញុំសូមជំទាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំយល់ស្រប។ ឥឡូវ លោកសាក្សី តើ<ជាការពិតទេថា>អគារគុកនោះ <មានចម្ងាយប្រហែលគ្នាពីកន្លែងសួរចម្លើយទៅផ្ទះបាយ>?

**ឆ៖** អគារបាយ កន្លែងពួកអង្គរក្សគេ ចម្ងាយពីអគារគុក ចម្ងាយដី៥០ម៉ែត្រ។

**ស៖** ចុះផ្ទះបាយនោះ នៅចម្ងាយប៉ុន្មានពីកន្លែងសួរចម្លើយ?

**ឆ៖** ចម្ងាយប្រហែល៤០ម៉ែត្រ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងចូលទៅប្រធានបទមួយផ្សេង។ ខាងដើមនោះ លោកផ្តល់សក្ខីកម្ម លោកបញ្ជាក់ថា លោកបានឃើញកម្មាភិបាលគុក ហើយនិងឆ្មាំគុកបានសម្លាប់ក្មេង ឬទារក ដោយបោកទៅនឹងគល់ឈើ។ តើលោកនៅចាំ<>ទេ កើតឡើងនៅពេលណា? ហើយថាតើរយៈពេលយូរប៉ុនណា បន្ទាប់ពីលោកទៅដល់ក្រាំងតាចាន់ បានឃើញហេតុការណ៍ហ្នឹង?

**ឆ៖** ពេលហេតុការណ៍គេសម្លាប់ក្មេងកុមារតូចៗនៅជាមួយម្តាយ ពេលដែលឆ្នាំ៧៧ ព្រោះខ្ញុំបានដើរសេរី ព្រោះពេលនោះខ្ញុំតែត្រូវយកចិត្តទុកដាក់ និងគយគន់មើល តើគេ -- វិធីសម្លាប់ក្មេងរបៀបណា។

**ស៖** តើលោកអាចពន្យល់បានទេ តើមានហេតុការណ៍អ្វីកើតខ្លះ<>នៅថ្ងៃដែលលោកបានឃើញហ្នឹង?

**ឆ៖** ហេតុការណ៍អត់មានអ្វីកើតឡើង ព្រោះគេមានអ្នកការពារគ្រប់គ្រងត្រួតពិនិត្យតឹងតែងឲ្យអ្នកទោសអ្នកណា -- ហេតុការណ៍កើតឡើង ព្រោះគេសម្លាប់ម្តាយហើយគឺសម្លាប់កូនហើយ គេអត់មានទុកទេកូនហើយនិងម្តាយនោះពេលហ្នឹង។ ជីកស្មៅ ជីកទាំងឫស ជីកទាំងគល់។

[១០:៣៦:០៣]

**ស៖** សំណួររបស់ខ្ញុំហ្នឹង គឺខ្ញុំសួរលោកសាក្សីថា តើលោកអាចរៀបរាប់ដោយសង្ខេបជាទូទៅថាតើលោកបានធ្វើអ្វីខ្លះ<នៅថ្ងៃនោះ> មុនពេលដែលលោកឃើញ<គេ>បោក<ទារកទៅ>នឹងដើមឈើហ្នឹង?

**ឆ៖** មុនពេលក្មេង -- គេបោកក្មេង ខ្ញុំតែងតែដឹកក្របីចូលមកកន្លែងវិញ ហើយកន្លែងក្របីហ្នឹងនៅទីតាំងខាងត្បូងកន្លែងគេសម្លាប់មនុស្ស ព្រោះខ្ញុំលបមើលតាមប្រហោងជញ្ជាំងស្លឹកដូង ព្រោះដើមឈើទាលមានធំនៅជាប់របណ្តៅ។

**ស៖** នេះមិនមែនជាសំណួរដែលខ្ញុំសួរទេ<។> ខ្ញុំសូមឲ្យលោករៀបរាប់ជាទូទៅ គឺថាថ្ងៃដែលលោកបានឃើញហ្នឹង ថាតើព្រឹកឡើងលោកភ្ញាក់ឡើង លោកធ្វើអ្វីនៅពេលព្រឹក? ហើយពេលថ្ងៃធ្វើអ្វី? ថាតើពេលណាដោយជាក់លាក់ដែលគេយកក្មេង ឬក៏ទារកហ្នឹងទៅបោកនឹងគល់ឈើបាទ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពេលព្រឹកខ្ញុំ -- គេអត់ទាន់សម្លាប់ទេមនុស្ស គេសម្លាប់តែថ្ងៃរសៀល ម៉ោងពីរ ម៉ោងបីអីចឹងគេចាប់ផ្ដើមសម្លាប់ហើយ។ ពេលព្រឹកខ្ញុំដើរធ្វើ រកម្ហូបអាហារអីចឹង យកមកឱ្យពួកខាងអង្គរក្សគេទៅ។ ពេលថ្ងៃរសៀលអីចឹងខ្ញុំទៅមើលគោ មើលក្របីបាត់ទៅ ហើយពេលដែលប្រមូលគោចូលក្រោល ប្រមូលក្របីចូលចងទៅ ព្រោះកន្លែងក្របីវាជិតទីស្នាក់ការគេ ឃាតកម្មហ្នឹង។ ពេលនោះខ្ញុំក៏ក្រឡេកឃើញ ឮក្មេងយំ ក៏ខ្ញុំក្រឡេកឃើញគេបោកនឹងគល់ឈើទាល ហើយគេបោះដាក់រណ្ដៅ។

**ស៖** ខ្ញុំនឹងបន្តទៀត ថាតើទារកហ្នឹងជាកូនរបស់អ្នកណា? តើលោកស្គាល់ឈ្មោះម្ដាយឬឪពុកគេទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេរឿងម្ដាយ។

**ស៖** តើលោកបានឃើញម្ដាយរបស់ទារកហ្នឹងទេ នៅពេលដែលគេយកទារកទៅ<សម្លាប់>នោះ?

**ឆ៖** ពេលមុនឃើញគេសម្លាប់ខ្ញុំឃើញគាត់ ដល់ពេលហើយ -- គេសម្លាប់ហើយខ្ញុំលែងឃើញហើយ។

**ស៖** តើលោកអាចពន្យល់ពិស្ដារបន្តិចអំពីម្ដាយទេ តើឈ្មោះអី? <តើលោកអាចរៀបរាប់ពីភិនភាគគាត់ទេ?> តើគាត់ជាអ្នកទោសដែរឬក៏អត់?

**ឆ៖** ម្ដាយគេខ្ញុំអត់ដឹងឈ្មោះ ខ្ញុំអត់ស្គាល់ឈ្មោះ អត់ស្គាល់ស្រុកភូមិគេ មិនដឹងមកពីទិសណាតំបន់ណា ខ្ញុំអត់ដឹង ព្រោះដឹងតែគេយកមកដាក់គុក ដាក់ក្រាំងតាចាន់ហ្នឹង។

**ស៖** ប៉ុន្តែ លោកគួរតែអាចរៀបរាប់ពីភិនភាគ អំពីអ្វីដែលលោកបានឃើញមុននឹងមានហេតុ-ការណ៍ហ្នឹង។

[១០:៤០:០០]

**ឆ៖** មុនហេតុការណ៍ មុនគេធ្វើហេតុការណ៍ ខ្ញុំមិនបាននៅតាមពិនិត្យតាមដានទេ ព្រោះខ្ញុំ តែពេលគេសម្លាប់មនុស្ស គឺគេដេញចេញពីក្រៅហ្នឹងហើយ ឱ្យដើរទៅឃ្វាលគោឃ្វាលក្របីហើយ។ ហើយបន្ទាប់មកខ្ញុំពេលត្រឡប់មកវិញ បានខ្ញុំអាចនឹងលបមើលឃើញ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ!

**ស៖** ប៉ុន្តែប្រាកដណាស់លោកសាក្សី គឺជាហេតុការណ៍ដ៏អាក្រក់ណាស់ ពីព្រោះថាបងប្អូនរបស់លោកក៏មានទារក មានកុមារដែរ តើលោកបាននិយាយពីរឿងហេតុហ្នឹងជាមួយបុគ្គលិកគុកហ្នឹង ឬក៏អ្នកណាផ្សេងទៀតដែរឬទេពីហេតុការណ៍ដែលលោកបានឃើញ បានដឹងនោះ?

**ឆ៖** ខ្ញុំអត់ហ៊ាននិយាយរឿងកិច្ចការហ្នឹង គឺនិយាយគឺខ្ញុំស្លាប់ដែរ។ ខ្ញុំមិនត្រូវនិយាយ។ បើឃើញ គឺធ្វើគធ្វើថ្លង់។

**ស៖** អ៊ីចឹងលោកមិនបានទៅជួបអ្នកយាម <ឬក៏អ្នកផ្សេងទៀត>ទៅសួរថា<>អី<បានកើតឡើង?> ថាហេតុអីបានជាគេយកក្មេងទៅ សម្លាប់ដោយបោកនឹងគល់ឈើអ៊ីចឹង? តើលោកបានសួរអ្នកណាដែរឬទេ?

**ឆ៖** ដូចខ្ញុំជម្រាបប្រាប់លោកហើយ ខ្ញុំមិនបានទៅសួរគេទេព្រោះទៅសួរនាំតែមានរឿងខ្លួនឯង។ ហេតុថាខ្ញុំធ្វើគធ្វើថ្លង់ ខ្ញុំអត់និយាយច្រើនដងទៀតទេកន្លែងហ្នឹង ព្រោះកន្លែងគេឲ្យយើងគថ្លង់ហើយ។

**ស៖** តើលោកនៅចាំទេ តើដើមឈើអ្វីដែលគេបោកកុមារទៅនឹងគល់ឈើនោះ តើដើមឈើហ្នឹងដើមឈើអ្វី?

**ឆ៖** ដើមឈើទាល។

**ស៖** តើដើមឈើហ្នឹងនៅត្រង់ណា? នៅកន្លែងណា?

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយ ក្បាលមេក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**<លោក មាស សុខា៖>**

**ឆ៖** នៅពីខាងជើងរណ្ដៅ ច្រកចូលទៅនាំយកមនុស្សទៅសម្លាប់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកនិយាយថានៅខាងជើងហ្នឹង<>មានន័យដូចម្ដេច? ថាតើកន្លែងហ្នឹងនៅខាងក្នុងបរិវេណហ្នឹងឬក៏នៅខាងក្រៅ?

**ឆ៖** បរិវេណទីមួយ។

**ស៖** តើលោកចាំដែរទេថាតើម្ដាយឬក៏បងស្រីឬក៏បងប្អូនប្រុសរបស់លោកបានឃើញហេតុការណ៍ហ្នឹងដែរឬទេ?

[១០:៤៣:៣៣]

**ឆ៖** ហេតុការណ៍ហ្នឹងគាត់មិនបានឃើញទេ ព្រោះគាត់គេរុញចូលក្នុងអគារហើយ ដល់ពេលគេសម្លាប់មនុស្ស គេអត់ឲ្យគាត់ដឹងអ្វីទាំងអស់។ គាត់ថែមទាំងសុំគេឲ្យជូនគាត់ទៅតាមសហករណ៍ជាមួយ

 E1/250.1

គេផង។ ហើយដល់ថ្ងៃមួយមានអង្គរក្សគុកម្នាក់ឈ្មោះ សៀង ថា៖“យាយញ៉ ឯងចង់ទៅណាដែរ? នេះ! កន្លែងនេះកន្លែងៗទៅសហករណ៍កន្លែងហ្នឹងទៅជួបជុំបងប្អូនកន្លែងហ្នឹង! យាយញ៉ ឯងឈប់សុំគេ”។

**ស៖** តើលោកចាំដែរឬទេ តើឆ្មាំគុកឬក៏អ្នកយាមមួយណាដែលជាអ្នកធ្វើរឿងហ្នឹង?

**ឆ៖** តែអ្នកឆ្មាំគុកគឺនៅក្នុងហ្នឹងគឺគេធ្វើទាំងអស់គ្នា គ្រាន់តែចែកមុខការងារគ្នា។ អ្នកបញ្ជូនមនុស្សពីក្នុងអគារទៅឲ្យកន្លែងរណ្ដៅមានបួននាក់អីចឹងទៅ ពីរនាក់នាំចេញពីមាត់ទ្វា ម្នាក់ចាំអមតាមផ្លូវ ពីរនាក់ចាំទទួលទៅឲ្យគេអ្នករណ្ដៅទៅ។

**ស៖** ម្ដងទៀតហើយ ខ្ញុំមិនសួរពីចម្លើយទូទៅទេ ខ្ញុំចង់សួរថាតើអ្នកណាជាអ្នកបោកទារកទៅនឹងគល់ឈើ? តើអ្នកយាមមួយណា? ចង់សួរថាឈ្មោះអីបាទ?

**ឆ៖** ឈ្មោះ សៀង។

**ស៖** តើលោកចាំទេថាគាត់ធ្វើអីចឹង ធ្វើរឿងហ្នឹងដោយរបៀបណា?

**ឆ៖** ខ្ញុំម៉េចនឹងដឹងរឿងគេធ្វើដោយរបៀបណា ខ្ញុំអត់ដឹងរឿងហ្នឹង ព្រោះខ្ញុំមិនដឹងគេវិធីសម្លាប់មនុស្ស ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំបើខ្ញុំដឹង ខ្ញុំចាំបាច់និយាយធ្វើអី បើឃើញសម្លាប់មនុស្សទូទៅអីចឹងហើយ។

**ស៖** ខ្ញុំដូចមានការភ័ន្តច្រឡំបន្តិច។ តើលោកនិយាយថា<>លោកមិនដឹង ឬក៏លោក<មិន> បានឃើញ? តើលោកចង់បញ្ជាក់ដូចម្ដេចនៅពេលនេះ?

**ឆ៖** ខ្ញុំបញ្ជាក់ថា បើខ្ញុំឃើញហើយ លោកមេធាវីឈប់សួរខ្ញុំ ព្រោះខ្ញុំឃើញជាសក្ដី -- ដែងថ្ងៃគេឃាតកម្មក្មេង ខ្ញុំគ្រាន់តែឃើញពេលខ្លី ខ្ញុំមិនបានឃើញពេលវែងទេ។

**ស៖** បាទ លោកសាក្សី ខ្ញុំនឹងបន្តទៅមុខទៀត ប៉ុន្តែមិនទាន់សួរសំណួរចុងក្រោយនៅឡើយទេនៅប្រធានបទមួយនេះ។ <ខ្ញុំសួរទៅលោក>ថា លោក<ពិតជា>មិនបានឃើញការគេសម្លាប់ទារកដោយបោកនឹងគល់ឈើនឹងទេ។ តើអីចឹងដែរឬទេ?

[១០:៤៧:១៣]

**ប្រធានអង្គជំនុំ៖**

មេធាវី ដូចជាយើងបានប្រាប់លោកហើយ លោកមិនគប្បីធ្វើសេចក្ដីសន្និដ្ឋាន ហើយឲ្យសាក្សីឆ្លើយបញ្ជាក់លើសេចក្ដីសន្និដ្ឋានរបស់លោកទេ។ សេចក្ដីសន្និដ្ឋានលោកនឹងអាចធ្វើបាន ទី១ គឺនៅចុងបញ្ចប់នៃកិច្ចពិភាក្សាដេញដោល។ ទី២ សេចក្ដីសន្និដ្ឋានដែលអង្គជំនុំជម្រះទទួលបានគឺលាយលក្ខណ៍អក្សរ។ នេះចែកច្បាស់លាស់នៅក្នុងក្រមកម្ពុជា ក៏ដូចជានៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក ស្ដីពីនីតិវិធី

ប្រព្រឹត្តទៅនៃកិច្ចពិភាក្សាដេញដោល។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះទេ!

**លោក វិចទ័រ កូប៉េះ**

**ស៖** <លោកប្រធាន ខ្ញុំគិតថានេះគឺជាសំណួរត្រឹមត្រូវតាមច្បាប់ហើយ។ ប៉ុន្តែទោះជាយ៉ាងណានៅក្នុងតុលាការនេះ មានរឿងចម្លែកៗជាច្រើនបានកើតឡើង។> បាទ ដូច្នេះ លោកសាក្សី ខ្ញុំនឹងបន្តទៅប្រធានបទមួយផ្សេងទៀត។ ជាសក្ខីកម្មដែលលោកបានឃើញផ្ទាល់ភ្នែកអំពីការសម្លាប់មនុស្ស<> ទ្រង់ទ្រាយធំ <ជាថ្មី>ម្តងទៀតថា តើ<លោកនៅចាំទេរឿងនោះកើតនៅ>ពេលណា<>ក្នុងរយៈពេល<>គេបញ្ជូនទៅក្រាំងតាចាន់នោះ?

**ឆ៖** ខ្ញុំឃើញសម្លាប់មនុស្សពេលខ្ញុំជាប់គុកក្រាំងតាចាន់ អត់មានឃើញក្រៅពីក្រាំងតាចាន់ទេ។ ក្រៅក្រាំងតាចាន់ ខ្ញុំអត់ដែលដឹងទេ ព្រោះក្នុងបរិវេណក្រាំងតាចាន់ គឺកន្លែងឃាតកម្មមួយដ៏សាហាវយង់ឃ្នង សម្លាប់មនុស្សអត់រើសមុខ។

**ស៖** សុំលោកសាក្សី សុំឱ្យស្តាប់សំណួរខ្ញុំ គឺខ្ញុំសួរថាតើលោកចាំទេ ថានៅពេលណាដែល<> ការកាប់សម្លាប់ទ្រង់ទ្រាយធំ <ដែលលោកបាននិយាយកាលពីម្សិលមិញនោះ បានកើតឡើង>?

**ឆ៖** នៅពេលឆ្នាំ៧៧ ពេលខ្ញុំនៅជាប់ពន្ធនាគារក្រាំងតាចាន់ ដែលចាប់ជាប់តាំងពីឆ្នាំ៧៦ រហូតឆ្នាំ៧៧។

**ស៖** តើលោកបានឃើញហ្នឹង នៅក្នុងរដូវប្រាំង ឬក៏រដូវវស្សា?

**ឆ៖** រដូវច្រូតហើយ។

**ស៖** លោកសាក្សី ខ្ញុំចង់ឱ្យលោក -- ឥឡូវខ្ញុំចង់ឱ្យលោកត្រឡប់ទៅគិតនៅថ្ងៃនោះវិញ។ តើនៅថ្ងៃនោះលោកបានធ្វើអ្វីខ្លះ <>ពេលដែលលោកបានឃើញគេសម្លាប់មនុស្សចំនួនច្រើនហ្នឹង? <>

[១០:៥០:៣៩]

**ឆ៖** ខ្ញុំអត់មានធ្វើអីក្រៅពីតួនាទីមើលគោ មើលក្របីទេ ព្រោះគេសម្លាប់ថ្ងៃហ្នឹងម៉ោងបីរសៀល។ គេដឹកជញ្ជូនមនុស្សមកយ៉ាងច្រើន។ គេអត់កន្លែងដាក់ គេត្រូវតែសម្លាប់យកទៅធ្វើទុកឱ្យហើយ។ គេអត់មានកន្លែងដាក់ទេ។

**ស៖** អ៊ីចឹងគឺថា ឥឡូវយើងរៀបរាប់ហេតុការណ៍មួយម្តងៗ ដូច្នេះលោកនិយាយថា គេសម្លាប់នៅម៉ោងបី។ តើលោកចាំរឿងរ៉ាវ<នេះដោយរបៀបណា ថាវាកើតឡើង>នៅម៉ោងបីហ្នឹង? តើលោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អាចប្រាប់តុលាការលម្អិតបន្តិចបានទេ?

**ឆ៖** ម៉ោងបីរសៀលគេចាប់ជញ្ជូនមនុស្សចេញពីក្នុងបរិវេណរបងទី១ ទៅឱ្យអ្នកផ្ដាំឃាតកម្ម បន្តម្ដងបី ម្ដងបួន ម្ដងពីរ ម្ដងប្រាំនាក់អ៊ីចឹងទៅ។ ហើយមួយគន្លាក់ គេជញ្ជូនម្ដងទៀត។ ជញ្ជូនទាល់តែអស់គ្នា១០០ជាងនាក់។ ហើយដល់ពេលយប់ខ្ញុំក៏ឈប់មើល លបមើលទៀត។ ខ្ញុំដេក ចាប់ផ្ដើមដេកចប់ខ្ញុំត្រឹមដេកហ្នឹង។

**ស៖** តើតាមសក្ខីកម្មរបស់លោកប្រាប់តុលាការ លោកបានឃើញថា គេសម្លាប់មនុស្សដល់ទៅ ១០០នាក់ក្នុងពេលថ្ងៃហ្នឹងអ្នេស?

**ឆ៖** ថ្ងៃគេសម្លាប់ហ្នឹង ជាង១០០នាក់ ប៉ុន្តែដឹងមួយរយប៉ុន្មាននាក់ ខ្ញុំអត់ដឹងទេ។

[១០:៥២:៥០]

**ស៖** បាទលោកសាក្សី។ ឥឡូវនេះខ្ញុំ -- យើងពិនិត្យត្រង់ម៉ោងបីនៅថ្ងៃនោះ តើ<ធ្វើម៉េចទើបលោកចាំថា ពេលនោះគឺម៉ោងបី>?

**ឆ៖** ខ្ញុំចាំយ៉ាងម៉េច បើខ្ញុំប្រាប់ ជម្រាបប្រាប់ដល់លោកប៉ុណ្ណឹងហើយ នៅលោកនៅសួរដេញដោលយ៉ាងណាទៀត បើខ្ញុំឃើញសកម្មភាពតែប៉ុណ្ណឹងហ្នឹង?

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកស្ដាប់សំណួរឱ្យបាន លោកត្រូវឆ្លើយតបរាល់សំណួរដែលសួរ ក្នុងករណីសំណួរណាដែលលោកមិនដឹង លោកអាចឆ្លើយថា "មិនដឹង"។ យើងបានប្រាប់លោកហើយ ប្រសិនបើលោកព្យាយាម និងប្រឹងប្រែងនិយាយច្រើនពេកហួសពីវិសាលភាព ភាពចាំបាច់នៃការឆ្លើយតបទៅនឹងសំណួរ ផលវិបាកនិងបញ្ហានៃការល្មេចសួរដេញដោលតាមនីតិវិធីតុលាការ គឺលោកជាអ្នកឆ្លើយ។ លោកមិនអាចមិនឆ្លើយបានទេ។ គ្រាន់តែការដែលលោកមិនដឹង គឺលោកឆ្លើយច្បាស់ថា "លោកមិនដឹង"។ នេះជាការ ក៏ជាចម្លើយដែរ។ ហើយចម្លើយជាក់ច្បាស់តែម្ដង។ តទៀត!

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។ អ៊ីចឹងជាម៉ោងបីនៅពេលនោះ។ អ៊ីចឹងខ្ញុំនឹងសួរបន្តទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើថ្ងៃហ្នឹងលោកឃ្វាលគោឃ្វាលក្របី មុននឹងត្រឡប់មកបរិវេណហ្នឹងវិញឬថ្ងៃនោះនោះ?

**លោក មាស សុខា៖**

**ឆ៖** ពេលខ្ញុំមើលគោក្របី ខ្ញុំតែម៉ោងបី ម៉ោងបួន ម៉ោងប្រាំ គឺខ្ញុំចូលទៅដល់កន្លែងហើយ។ អត់មាននៅហួសពេលទេ។

[១០:៥៤:៤៥]

**ស៖** បាទលោកសាក្សី ខ្ញុំមិនបានសួរអ៊ីចឹងទេ។ តើនៅថ្ងៃនោះដែលលោក<និយាយថា>ថាបានឃើញគេសម្លាប់អ្នកទោស<១០០នាក់។> តើលោកត្រឡប់មកពីឃ្វាលគោ ឃ្វាលក្របីនៅម៉ោងបីមែនទេថ្ងៃហ្នឹងនោះ?

**ឆ៖** ពេលម៉ោងបី មកយកខ្សែ ខ្សែក្របី ចាប់ក្របី។

**ស៖** តើលោកអាចប្រាប់តុលាការបានទេ តើលោកនៅកន្លែងណានៅពេល<>ដែលលោកបានឃើញគេសម្លាប់អ្នកទោស១០០ហ្នឹង?

**ឆ៖** ខ្ញុំមិនឆ្លើយទេ ព្រោះខ្ញុំអត់បាននៅត្រួតពិនិត្យតទៅទៀត ព្រោះខ្ញុំឃើញ ដើរចេញហើយ។

**ស៖** អ៊ីចឹងនៅក្នុងចម្លើយរបស់លោក លោកបញ្ជាក់ថាលោកមិនបានឃើញគេសម្លាប់មនុស្សទាំង១០០ហ្នឹងទេ។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** គ្រាន់តែឃើញ ប៉ុន្តែគេសម្លាប់ហើយ ក្នុង១០០នាក់ហ្នឹងគេយកមកដាក់បរិវេណហ្នឹងហើយ គេអត់មានទុកទេ។ <>បើខ្ញុំអ្នកទៅកកាយកប់ទៀតផង។

**<ស៖>** អ៊ីចឹងលោកពិតជាមិនបានឃើញដោយផ្ទាល់ភ្នែកទេ គឺលោកបានដឹងដោយសារតែគេឱ្យលោកទៅកប់នៅពេលក្រោយហ្នឹងទេ តើអ៊ីចឹងឬយ៉ាងម៉េច?

**ឆ៖** ពេលស្តាប់ គេសម្លាប់ ខ្ញុំឃើញៗហើយខ្ញុំដើរចេញ មិនមែនខ្ញុំនៅឈររាប់ទេ។

**ស៖** អ៊ីចឹងលោកបានឃើញការសម្លាប់នោះដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** --ខ្ញី។

**ស៖** ប៉ុន្តែលោកសាក្សី ការសម្លាប់មនុស្ស១០០នាក់។ អ៊ីចឹងគឺថាអាចកន្លះម៉ោង ឬក៏មួយម៉ោង តើលោកអាចប្រាប់បានទេ តើលោកបានឃើញនោះរយៈពេលប៉ុនណា?

**ឆ៖** រយៈម៉ោង ខ្ញុំអត់មានម៉ោងវាស់ទេ ព្រោះខ្ញុំដឹងថាម៉ោងបីរសៀលហើយ ព្រោះដល់ម៉ោងប្រាំបីយប់គេដាស់ឱ្យខ្ញុំទៅលាងដារ។

[១០:៥៨:៤៥]

**ស៖** លោកសាក្សី ដើម្បីឱ្យខ្ញុំយល់ច្បាស់ហើយនិងត្រឹមត្រូវនោះ និយាយពីការសម្លាប់អ្នក

ទោស<>ដល់១០០នាក់នោះ គឺថាជាហេតុការណ៍ដ៏អាក្រក់ណាស់ ដើម្បីខ្ញុំយល់ច្បាស់ពីអ្វីដែលកើតឡើង សូមឲ្យលោកនិយាយច្បាស់ៗ<ដើម្បីឲ្យខ្ញុំយល់កាន់តែច្បាស់ពីអ្វីដែលបានកើតឡើង> ថាលោក<ច្បាស់ទេ ថាលោក>បានឃើញគេសម្លាប់ជាក់ស្តែងនូវអ្នកទោសទាំង១០០ដែរឬទេ? បើសិនជាបានឃើញគេសម្លាប់ទាំង១០០ តើគេសម្លាប់របៀបម៉េច? <>

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ?

**លោក ឌេល លីសាក់៖**

ការជំទាស់របស់ខ្ញុំហ្នឹង គឺលោកប្រធាន គឺថាបើគាត់សួរថាឃើញគេសម្លាប់អ្នកទោសទាំង១០០ហ្នឹងដែរឬទេ ឬក៏ថាតើសាក្សីបានឃើញ<អ្នកទោស>មួយចំនួន<ត្រូវបានសម្លាប់>។ <ដោយសារ>សំណួររបស់លោកមេធាវីហ្នឹង<មិនច្បាស់> <ជាហេតុឲ្យគាត់សួរ>ដដែលៗ។ អ៊ីចឹងសូមឲ្យមេធាវីសួរសំណួរជាក់លាក់។

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន នេះគឺជាការបង្ខូចកិត្តិយស-->

**ប្រធានអង្គជំនុំ៖**

សំណួរពិតជាដដែលមែន សំណួរច្រំដែល។ សូមលោកមេធាវី -- សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរដែលសួរដោយមេធាវីអម្បាញ់មិញនេះទេ។ មេធាវីអាចបន្តសំណួរថ្មីទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន <នៅក្នុងកំណត់ត្រានេះ>គឺ<ជា>ការជំទាស់នោះគឺមិនត្រឹមត្រូវ <និងការសម្រេចចិត្តមិនត្រឹមត្រូវ>។ ឥឡូវនេះខ្ញុំនិយាយពីការសម្លាប់មនុស្ស ១០០នាក់។

**ប្រធានអង្គជំនុំ៖**

សំណួររបស់លោកគឺសំណួរច្រំដែល យើងបានកត់ត្រាយ៉ាច្បាស់លាស់ហើយ គឺសំណួរបានឃើញការសម្លាប់មនុស្សហ្នឹងគឺច្បាស់លាស់ហើយ គឺបានឆ្លើយរួចហើយ បានសួររួចហើយ បានឆ្លើយរួចហើយ។ ប្រសិនបើលោកចង់សួរអីផ្សេងទៀត គឺសុំសួរឲ្យបានច្បាស់លាស់ ប៉ុន្តែមិនអនុញ្ញាតឲ្យសួរច្រំដែល ហើយចំណាយពេលវេលា សុំពេលវេលាច្រើន សំណួរច្រំដែលទេ ក្រែងលោអស់ពេលវេលាសម្រាប់មេធាវីការពារក្តី ខៀវ សំផន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:០១:០០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកសាក្សីបានឃើញការសម្លាប់មនុស្ស ១០០នាក់ជាងនោះដែរឬទេ?

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំឃើញ ប៉ុន្តែខ្ញុំឃើញពេលខ្លី ខ្ញុំមិនបាននៅត្រួតពិនិត្យឈរមើលឲ្យអស់ពេលអស់វេលាទេ។

**ស៖** ហេតុអ្វីបានអ៊ីចឹងលោកសាក្សី តើលោកសាក្សីឃើញគេសម្លាប់ប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំអត់បានរាប់ទេ។

**ស៖** តើលោកឃើញម្នាក់ ប្រាំនាក់ ១០នាក់ ឬក៏២០នាក់?

**ឆ៖** ខ្ញុំឃើញតែម្នាក់ ហើយខ្ញុំស្លុតខ្ញុំៗដើរចេញទៅ ព្រោះដឹងតែមនុស្ស១០០នាក់នៅជាប់ ដាក់នៅក្នុងបរិវេណក្នុងហ្នឹងហើយៗ។

**ស៖** អ៊ីចឹង ឥឡូវហ្នឹងលោកបានផ្តល់សក្ខីកម្មថា លោកឃើញគេសម្លាប់តែម្នាក់ទេ។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ? ហើយបើអ៊ីចឹងមែន តើអ្នកដែលគេសម្លាប់ម្នាក់ហ្នឹងជាអ្នកណាដែរ?

**ឆ៖** ខ្ញុំអត់ស្គាល់។

**ស៖** នៅពេលដែលបុគ្គលម្នាក់នេះត្រូវគេសម្លាប់ ចុះអ្នកដទៃទៀត <៩០ ឬ>១០០នាក់ទៀតនៅឯណាដែរ?

**ឆ៖** នៅរណ្តៅតែមួយ។

**ស៖** ការពិតសំណួររបស់ខ្ញុំចង់សួរថា តើអ្នកទោសដទៃទៀតនៅទីណាដែរ? គេទុកនៅកន្លែងណាដែរនៅពេលដែលលោកឃើញគេសម្លាប់មនុស្សម្នាក់នោះ?

**ឆ៖** មនុស្សម្នាក់ហ្នឹងចំណោមមនុស្ស១០០នាក់ៗ ខ្ញុំឃើញគេសម្លាប់ម្នាក់ ហើយគេយកទៅបន្តបន្ទាប់ គឺគ្រាន់ឃើញគេសម្លាប់ម្នាក់ ខ្ញុំដើរចេញ ខ្ញុំតក់ស្លុត ខ្ញុំដើរចេញ។ ១០០នាក់ហ្នឹងគេបញ្ជូនទៅកន្លែងហ្នឹងដដែល អត់មានយកទៅណាទេខុសពីកន្លែងហ្នឹងទេ។

**ស៖** តើលោកដឹងរឿងហ្នឹងដោយរបៀបណា? អ្នកណាប្រាប់លោកដែរ?

[១១:០៣:៤៣]

**ឆ៖** មានគេប្រាប់ខ្ញុំដែរ ពួកអង្គរក្សហ្នឹងវាមានអ្នកត្រង់ អ្នកវៀច អ្នកស្លូត មានអ្នកល្អ អ្នក

អាក្រក់ ដូចគ្នា។ គេថា៖ "១០០នាក់ អ្នែង ក្នុងរណ្ដៅនេះ អ្នែងទៅកប់ផង! ប៉ុន្តែកុំឲ្យគេដឹង អញខ្សឹបប្រាប់អ្នែងទេ គ្រាន់គេបញ្ជាឲ្យអ្នែងកប់ ជួយកប់គ្នា"។

**ស៖** លោកសាក្សី ខ្ញុំស្ដាប់មិនទាន់ច្បាស់។ តើលោកកប់សាកសពហ្នឹង ឬមួយក៏សាកសពហ្នឹងនៅក្នុងរណ្ដៅហ្នឹងស្រាប់ទៅហើយ?

**ឆ៖** ក្នុងរណ្ដៅ។

**ស៖** អ៊ីចឹងលោកចង់ផ្ដល់សក្ខីកម្មថា លោកមិនបានជីករណ្ដៅនោះទេ។ គឺបានន័យថា លោកមិនមែនជាអ្នកជីករណ្ដៅដើម្បីកប់សាកសព ដើម្បីដាក់សាកសពនោះទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំមិនអ្នកជីកទេរណ្ដៅ។ មានតាចិន ហើយ សយ សែន អ្នកជីករណ្ដៅ។

ស៖ បាទ អរគុណលោកសាក្សី។ តើលោកទៅណាដែរ<ក្នុងពេលគេសម្លាប់អ្នកទោស៩៩នាក់ទៀតនោះ?> បន្ទាប់ពីលោកឃើញគេសម្លាប់ម្នាក់ហ្នឹងហើយ តើលោកចេញទៅណាទៀត?

**ឆ៖** ខ្ញុំទៅចងក្របី ចងដាក់ស្មៅ ដាក់ចំបើងឲ្យស៊ី ព្រោះចូលដល់យប់ហើយ។ ដល់ពេលកន្លែងខ្ញុំដេក តែយប់គឺខ្ញុំដេកហើយ គេឲ្យដេកហើយ អត់មានឲ្យដើរទៅណារហេតរហូតទេ។

**ស៖** ខ្ញុំស្ដាប់មិនទាន់យល់។ លោកនិយាយថាលោកឃើញហេតុការណ៍នោះ នៅម៉ោងបី ហើយលោកមើលគេសម្លាប់តែម្នាក់ទេ។ ខ្ញុំគិតថាប្រហែលជាយ៉ាងយូរ គឺម៉ោងបីនិងដប់ប្រាំ លោកដើរចេញទៅក្រៅ។ អ៊ីចឹងបន្ទាប់មក ស្រាប់តែវាងងឹតតែម្ដង មេឃចាប់ផ្ដើមងងឹត។ អ៊ីចឹងយ៉ាងម៉េចដែរ ព្រោះរយៈពេលបីម៉ោងជាងទៀតបានវាងងឹត?

**ឆ៖** ខ្ញុំអត់មាននិយាយមេឃងងឹតទេ ព្រោះខ្ញុំ ពេលខ្ញុំទៅយកខ្សែទៅចាប់គោ ចាប់ក្របីចងក្រោល ហើយដល់ពេលម៉ោងប្រាំល្ងាច គឺត្រូវដល់ពេលខ្ញុំចូលក្នុងបរិវេណគុកហើយ។ គេឲ្យខ្ញុំស៊ីបាយស៊ីអី ចាំតែពេលគេហៅប្រើទៅផ្ទះកង្កែប ផ្ទះសត្វអីទេ យប់ឡើងនោះ។

**ស៖** អ៊ីចឹងនៅពេលដែលលោកត្រឡប់មកវិញ លោកឃើញសាកសពមនុស្សប្រហែលជា ១០០នាក់ជាងហ្នឹងទេ?

**ឆ៖** ពេលគេប្រើឲ្យខ្ញុំទៅកប់ ខ្ញុំទៅកប់ជាមួយតាចិន ទៅ។ តាចិន ហើយនិងខ្ញុំ អ្នកទៅកាយដីកប់។ ខ្ញុំឃើញច្បាស់នឹងភ្នែក។

[១១:០៧:១៥]

**ស៖** ប៉ុន្តែ ខ្ញុំស្ដាប់ទៅថាលោកមិនបានចូលរួមក្នុងការកប់សាកសពទេ។ ខ្ញុំស្ដាប់អត់យល់ទេ

លោកសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំគិតថាជាសំណួរដដែលៗ។ <ការជំទាស់របស់ខ្ញុំគឺ> ថាមេធាវីការពារក្ដីយល់ច្រឡំ<អំពីកំណត់ត្រាដំបូង>។ សាក្សីគាត់និយាយថា គាត់មិនបានចូលរួមក្នុងការជីករណ្ដៅទេ ប៉ុន្តែគាត់ជាអ្នកកប់រណ្ដៅ។ ដូច្នេះ ខ្ញុំគិតថាគួរតែបញ្ជាក់ឲ្យបានច្បាស់ ប្រសិនបើមិនអ៊ីចឹងទេ គាត់នឹងសួរសំណួរដដែលៗ<។ ដូច្នេះ ខ្ញុំស្នើសុំឲ្យគាត់ ត្រូវតែសួរសំណួរជាក់លាក់> ហើយកុំឲ្យមានការយល់ច្រឡំទៅលើសក្ខីកម្ម<ដំបូង>របស់សាក្សី។ គឺថាគាត់មិនមែនជាអ្នកជីករណ្ដៅនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសួរសំណួរ ប្រហែលជា ២០ ទៅ២៥ នាទីអំពីហេតុការណ៍នៃការសម្លាប់រង្គាល <អ្នកទោស១០០នាក់> ដូច្នេះ<ខ្ញុំមិនគិតថា> ខ្ញុំ<>សួរសំណួរដដែលៗនោះទេ។ ប៉ុន្តែខ្ញុំគិតថា ឥឡូវនេះម៉ោងដប់មួយ ដប់នាទីហើយ ដើម្បីជាកំណត់ត្រា ខ្ញុំចង់បង្ហាញថាខ្ញុំមានសំណួរជាច្រើនទៀត ហើយខ្ញុំសុំអនុញ្ញាតថា ខ្ញុំអាចសួរសំណួរបន្ថែមទៀត មិនមែនត្រឹមតែការសម្លាប់រង្គាលនោះទេ ប៉ុន្តែអាចមានការសម្លាប់ដទៃទៀត។ ដូច្នេះលោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរសំណួរបន្តទៅទៀត។

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ លើកលែងតែពេលវេលាសម្រាប់ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន នៅសេសសល់។ តទៅនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១១:០៩:០៨]

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ ភាគីទាំងឡាយ។ សូមជម្រាបសួរលោក មាស សុខា។ ខ្ញុំ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន។ ហើយតទៅនេះ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ដំបូងខ្ញុំសូមឱ្យលោកបញ្ជាក់ពីអាយុរបស់លោក ពីព្រោះមុននេះ ពីថ្ងៃទី០៨ ខែមករា កន្លងទៅ លោកបានឆ្លើយថាលោកកើតនៅឆ្នាំ១៩៦០ ប៉ុន្តែនៅក្នុងអត្តសញ្ញាណប័ណ្ណរបស់លោក លោកដាក់នៅក្នុងឆ្នាំ១៩៦២។ លោកអាចបញ្ជាក់បានទេ ថាហេតុអីបានមានភាពខុសគ្នាបែបនេះ?

**លោក មាស សុខា៖**

**ឆ៖** ជម្រាបរឿងអត្តសញ្ញាណប័ណ្ណ។ ខ្ញុំកាលមុន ខ្ញុំធ្វើទាហាន។ ធ្វើទាហាន ខ្ញុំត្រូវតែដាក់បង្កើនអាយុតិច តិចដើម្បីចាំស៊ីប្រាក់ខែរីត្រែត។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងការបន្ថយអាយុរបស់លោកនោះ គឺក្នុងបំណងមួយដើម្បីឱ្យបានប្រាក់រីត្រែតយូរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតមែន។

**ស៖** លោកអាចពន្យល់យ៉ាងម៉េចដែរពីចំណុចនេះ តើហេតុអីបានជាលោកមានបំណងចង់ស៊ីប្រាក់រីត្រែតយូរនេះ?

**ប្រធានអង្គជំនុំ៖**

សំណួរហ្នឹងមិនពាក់ព័ន្ធទេ ហើយមិនរួមវិភាគទានអ្វីនាំឱ្យរកស្វែងការពិតនៅក្នុងរឿងក្តីនេះទេ។ សាក្សីមិនចាំឆ្លើយនឹងសំណួរនេះឡើយ។

[១១:១១:០១]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមអនុញ្ញាតបន្តសំណួរតទៀត។ ខ្ញុំចង់សួរបញ្ជាក់ទៅលើវ័យរបស់លោក កាលពីឆ្នាំ១៩៧៥ ក្រោយរំដោះ១៧មេសា ដែលលោកបានបញ្ជាក់កន្លងមក ថាលោកបានធ្វើការនៅក្នុងក្រុមកងកុមារ ដែលក្រុមឃ្វាលគោ។ ឥឡូវ ខ្ញុំសូមឱ្យលោកបញ្ជាក់ជាបីដំណាក់កាលខុសគ្នា។ ទី១ ទាក់ទងទៅនឹងដំណាក់ពីឆ្នាំ១៩៧៥ មកដល់ថ្ងៃដែលលោកត្រូវបានគេចាប់យកទៅឃុំនៅក្រាំងតាចាន់ គឺនៅក្នុងខែ៦ ឆ្នាំ១៩៧៦។ មួយទៀត នៅក្នុងចន្លោះពេលប្រហែល២០ថ្ងៃជាង អាចថារយៈពេលបីទៅបួនសប្តាហ៍នៅពេលដែលលោកជាប់ឃុំនៅក្នុងមន្ទីរក្រាំងតាចាន់នោះ ហើយនិងដំណាក់កាលទី៣ គឺក្រោយពេលដែលលោកត្រូវបានដោះលែង។ ខ្ញុំចង់សួរបញ្ជាក់ពីពេលវេលានេះឱ្យច្បាស់លាស់ថាតើនៅក្នុងពេលដែលលោកនៅឃ្វាលគោ ក្នុងដំណាក់កាលទី១ ដែលលោកបានឆ្លើយកន្លងមកនេះ ពេលហ្នឹងលោកស្ថិតក្នុងអាយុប៉ុន្មានដែរ នៅឆ្នាំ១៩៧៥?

**លោក មាស សុខា៖**

**ឆ៖** វ័យអាយុ១៥ឆ្នាំ។

**ស៖** បាទសូមអរគុណ។ លោកបានបញ្ជាក់នៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា កន្លងទៅ នៅម៉ោងដប់និងហាសិបប្រាំនាទី ក្រោយពេលហ្នឹងបន្តិចមក។ ខ្ញុំសូមអានជូន។ លោកឆ្លើយថា "ពេលនោះគេអនុញ្ញាតឲ្យនៅផ្ទះ ឲ្យខ្ញុំនៅ ពីព្រោះខ្ញុំតូចជាងគេ"។ ចំណុចនេះ ខ្ញុំចង់សួរលោកបញ្ជាក់ថា ពាក្យថា "តូចជាងគេនោះ" លោកប្រៀបធៀបទៅនឹងនរណា? ទៅក្នុងក្រុមរបស់លោក ឬក៏មួយនៅក្រុមណាផ្សេងទៀត? សូមលោកបញ្ជាក់ពីពាក្យថា "តូចជាងគេនេះ"។ លោកប្រៀបធៀបទៅនឹងអ្វី?

**ឆ៖** ខ្ញុំអត់ប្រៀបធៀបនរណាទេ គឺខ្លួនខ្ញុំផ្ទាល់តែម្តង ពីព្រោះខ្ញុំតូច ពេលនោះ ខ្ញុំមានជំងឺឈឺនៅជាប់នឹងខ្លួនផង បានគេឲ្យខ្ញុំតែងមកដេកផ្ទះយប់ឡើង។

[១១:១៣:២៦]

**ស៖** សូមលោកបញ្ជាក់ពីក្នុងដំណាក់កាលដំបូង ពេលលោកទៅឃ្វាលគោ មុនពេលចាប់ខ្លួន។ នៅក្នុងក្រុមឃ្វាលគោរបស់លោកហ្នឹង មានគ្នាប៉ុន្មាននាក់?

**ឆ៖** មានប្រាំមួយនាក់។

**ស៖** ក្នុងចំណោមប្រាំមួយនាក់នោះ មានអាយុចាប់ពីប៉ុន្មានទៅ?

**ឆ៖** អាយុប្រហាក់ប្រហែលគ្នា ប៉ុន្តែខ្ញុំវាតូចជាងគេ ព្រោះខ្ញុំតាំងពីតូចមក ម្តាយខ្ញុំថា "អ្អែង! ក្រិន តូចខ្លាំងណាស់"។

**ស៖** លោកអាចបញ្ជាក់បានថា ពាក្យថាលោកនិយាយថា "តូចនេះ" មិនមែនអាយុតិចទេ គឺមានន័យថា "មាឌតូច"។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** ឥឡូវខ្ញុំសូមឲ្យលោកបញ្ជាក់ពីពេលវេលាដែលស្ថិតនៅក្នុងពេលឃុំឃាំង។ លោកបានបញ្ជាក់ថា លោកត្រូវបានគេហៅឲ្យមកមន្ទីរឃុំឃាំងនៅពេលដែលលោកត្រឡប់មកពីឃ្វាលគោវិញ ហើយជួបនៅពេលដែលគេដឹកយកឪពុកម្តាយបងប្អូនរបស់លោកមក ហើយឲ្យលោកមកតាម។ ខ្ញុំចង់សួរបញ្ជាក់ថាពេលដែលលោកធ្វើដំណើរមកហ្នឹងគឺពេលវេលាតែមួយ ឬក៏មុនក្រោយគ្នាជាមួយនឹងម្តាយ ឬក៏បងប្អូនរបស់លោកនោះ?

**ឆ៖** ពេលវេលាតែមួយ ប៉ុនគ្រាន់តែខ្ញុំមកក្រោយ គេចាំយកខ្ញុំតែប៉ុណ្ណឹងដាក់ឡានតែមួយ។

**សៈ** លោកអាចបញ្ជាក់បានទេ ទាក់ទងទៅនឹងស្ថានភាពនៅពេលដែលលោកមកដល់មន្ទីរក្រាំងតាចាន់ដែលលោកបានបញ្ជាក់ថាមានការដាក់អ្នកទោសជាជួរ។ លោកអាចបញ្ជាក់ពាក្យថា "ជាជួរ" ដែលលោកមានប្រសាសន៍ហ្នឹង ចង់និយាយសំដៅយ៉ាងម៉េច ជួរយ៉ាងម៉េច? បានន័យថាតកន្ទុយគ្នារហូត ឬមួយក៏ជាជួរដោយបែបណា លោកអាចពន្យល់បានទេ?

**ឆៈ** ជាជួរតម្រៀបគ្នា ដាក់ខ្នោះជើងដង្ហែគ្នា បណ្ដោយលិចកើត ពីរជួរខាងត្បូង មួយជួរខាងជើង មួយជួរក្នុងអគារ១៥ម៉ែត្រ បណ្ដោយអ៊ីចឹង។

**សៈ** តម្រៀបគ្នាស្មើគ្នារហូតពីចុងម្ខាងទៅចុងម្ខាង ឬមួយក៏មានចន្លោះ មានកន្លែងដែលៗមិនមានដាក់មនុស្សដែរ?

**ឆៈ** មានចន្លោះខ្លះ ពេលណាគេយកមកបន្ថែម គេបន្ថែមឲ្យពេញទៅ។

[១១:១៧:៣៧]

**សៈ** បាទខ្ញុំចង់បញ្ជាក់ពីចន្លោះនេះ គឺបានន័យថាចន្លោះដែលមិនអាចដាក់មនុស្សថែមទេ។ មានន័យថា ឧទាហរណ៍ថាដាក់ បីនាក់ ឬក៏ប្រាំនាក់អ៊ីចឹងទៅ មានចន្លោះមួយ ហើយបានដាក់បីនាក់ ឬក៏ប្រាំនាក់អ៊ីចឹងទៀត។ លោកអាចបញ្ជាក់ចំណុចហ្នឹងបានទេ?

**ឆៈ** អត់មានបន្ទប់ខណ្ឌទេ គឺរនាបគ្រែលាតស្មើទាំងអស់អត់មានបន្ទប់ម្នាក់ពីរនាក់ទេ ដាក់ស្មើរហូត ដូចអស់លោកអង្គុយតម្រៀបគ្នាអ៊ីចឹង។

**សៈ** សូមលោកស្ដាប់សំណួរខ្ញុំ។ ខ្ញុំអត់និយាយអំពីការខណ្ឌជាបន្ទប់ទេ ក៏ប៉ុន្តែខ្ញុំនិយាយអំពីការតម្រៀបជាជួរ អ្នកទោសដែលស្ថិតក្នុងមន្ទីរឃុំឃាំងក្រាំងតាចាន់ដែលលោកបានឃើញ។ ថាតើការដាក់ហ្នឹងជាជួរតគ្នាពីមួយ ដល់ ៥០។ បានន័យថា ពីចាប់ផ្ដើមពីៗជ្រុងម្ខាងទៅដល់ជ្រុងម្ខាងហ្នឹង តរៀបគ្នារដឹកអ៊ីចឹង ឬមួយក៏មានការដាក់ជាដុំៗ?

**ឆៈ** ដាក់តម្រៀបគ្នាជាជួរ អង្គុយនៅតម្រៀបគ្នា អ្នកណាដេកៗទៅ ជើងជាប់ខ្នោះទាំងអស់។

**សៈ** បាទ សូមអរគុណ។

**លោក គង់ សំអុនៈ**

លោកប្រធានខ្ញុំបានសូមអនុញ្ញាត បង្ហាញនៅលើអេក្រង់ នូវឯកសារ D25/30 ត្រង់ ERN ជាភាសាខ្មែរលេខ 00163505, ជាភាសាបារាំង 00178424, ជាភាសារខ្មែរ -- សុំទោស ជាភាសាអង់គ្លេស 00223488។

[១១:១៩:៤៨]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកខាងសោតទស្សន៍បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមអានជូន លោកសាក្សីសូមស្ដាប់ផង។ នេះជាចម្លើយរបស់ម្ដាយរបស់លោកដែលបានឆ្លើយចំពោះចៅក្រមស៊ើបអង្កេត។ "សំណួរ៖ ពេលគេចាប់នាំទៅក្រាំងតាចាន់ មានបានឃើញអ្វីខ្លះនៅក្នុងនោះ នៅក្នុងគុកនោះ? ឆ្លើយ៖ គេយកទៅដាក់ក្នុងគុកវែង មានផ្លូវដើរសងខាង មួយកង់ប្រាំនាក់ជាមួយអ្នកទោសក្នុងបន្ទប់ធំមួយ។ ហើយគេដាក់ខ្នោះស្វូកដែកពីក្រោម"។ តើលោកអាចឆ្លើយបញ្ជាក់ទៅនឹងសក្ខីកម្មនេះយ៉ាងដូចម្ដេចដែរ?

**ឆ៖** ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់<។> ព្រោះខ្ញុំចង់<ឲ្យគាត់សួរ>ជាសំណួរ<>។ <ការដែលនិយាយថា "សូមលោកបញ្ជាក់អំពីរឿងនេះ" គឺមិនមែនជាសំណួរជាក់លាក់នោះទេ។> <ប្រសិនបើគាត់មាន>សំណួរជាក់លាក់<អំពី>សក្ខីកម្ម<របស់ម្ដាយសាក្សីនេះ គឺមិនអីទេ>។ <គាត់ហាក់ដូចជាសួរពីការយល់ឃើញ។> ចំពោះខ្ញុំ ខ្ញុំគិតថាហាក់ដូចជាការសួរដែលមិនត្រឹមត្រូវនោះឡើយ។

**លោក គង់ សំអុន៖**

លោកប្រធាន អង្គជំនុំជម្រះ ខ្ញុំបាទចង់បញ្ជាក់ចំណុចនេះទៅលើភាពខុសគ្នារវាងសក្ខីកម្មពីររបស់សាក្សីរូបនេះ ហើយនិងសាក្សីមួយទៀតដែល -- ដូចបានជម្រាបជូននៅក្នុងឯកសារ D25/30នេះ។

[១១:២១:៤៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២២:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិចំពោះការតាំងសំណួរចុងក្រោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នេះរបស់មេធាវីការពារក្តីលោក ខៀវ សំផន គឺជាការជំទាស់មិនត្រឹមត្រូវទេ។ អង្គជំនុំជម្រះត្រូវការស្តាប់នូវសក្ខីកម្មរបស់សាក្សីឆ្លើយតបទៅនឹងសំណួរនេះ។ ហើយទំនងជាសាក្សីភ្លេចហើយ សូមលោកមេធាវី គង់ សំអុន បញ្ជាក់នូវសំណួរនេះសាឡើងវិញ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំបាទសូមជម្រាបលោកសាក្សីសាឡើងវិញថា នៅក្នុងសក្ខីកម្មរបស់ម្តាយលោកដែលខ្ញុំបានអានជូនលោកអម្បាញ់មិញនេះ គឺគាត់បានមានប្រសាសន៍ថា “ នៅក្នុងបន្ទប់ឃុំឃាំងនោះគឺមានការដាក់អ្នកទោសជាកង់ៗ។ មួយកង់គឺមានគ្នាប្រាំនាក់ មិនមែនមួយជួរវែងហូតដូចលោកមានប្រសាសន៍អម្បាញ់មិញនេះទេ”។ អ៊ីចឹងសូមឲ្យលោកជួយបញ្ជាក់មើល ថាហេតុអីបានមានភាពខុសគ្នាចំពោះសក្ខីកម្មនេះ?

[១១:២៤:០៧]

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំជម្រាបដោយត្រង់ មួយកង់ៗហ្នឹង។ មួយកង់ហ្នឹង ប្រលោះរនុកដែក។ រនុកដែកសម្រាប់សូក។ ហើយក្នុងមួយកង់មានប្រាំនាក់ ហើយក្នុងមួយប្រាំនាក់ មួយចន្លោះទៀតមានប្រាំនាក់ទៀត។ ក្នុងមួយចន្លោះគេដាក់មនុស្សប្រាំនាក់។ ហើយក្នុងៗប្រាំនាក់ជួរតទៅទៀតទៅ។

**ស៖** បាទ អ៊ីចឹងលោកផ្លាស់ប្តូរសក្ខីកម្មរបស់លោកដែលលោកបានឆ្លើយពីមុនថាដាក់អ្នកទោសតម្រៀបគ្នាតគ្នារហូតពីចុងម្ខាងដល់ចុងម្ខាង។ ដោយលោកយល់ព្រមថា ឥឡូវនេះគឺការដាក់ហ្នឹងគឺមានមួយកងប្រាំនាក់អ៊ីចឹង។ តើមែនទេ?

**ឆ៖** ខ្ញុំមិន--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ កុំអាលឆ្លើយ! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

[១១:២៥:០០]

**ឆ៖** ខ្ញុំមិនផ្លាស់ប្តូរទេពាក្យហ្នឹង ប៉ុន្តែខ្ញុំឃើញគេដាក់តម្រៀបគ្នា បើក្នុងកង់ ក្នុងមួយកង់មួយចន្លោះគេដាក់ប្រាំនាក់ ក្នុងប្រាំនាក់ជាជួរតែម្តង គេអត់មានដាក់មួយចន្លោះហ្នឹង កន្លែងត្រយូវគុក ត្រយូវ

ខ្នោះ ត្រយូវអ៊ីចឹងគេស៊កដែកអ៊ីចឹងមក មួយចន្លោះត្រយូវមួយទៅៗ ហើយតម្រៀបគ្នា ហែគ្នាហ្នឹង។

**ស៖** បាទ ក្នុងពីចន្លោះពីប្រាំ –ដែលលោកបញ្ជាក់អំមិញនេះ– ក្នុងមួយចន្លោះប្រាំនាក់ហ្នឹង មានប្រវែងប៉ុន្មានពីកង់ទី១ ទៅកង់ទី២?

**ឆ៖** អត់ដល់ពីរម៉ែត្រទេ មួយចន្លោះ យ៉ាងច្រើនមួយម៉ែត្រកន្លះចុះ។

**ស៖** បាទ សុំអរគុណ។ ចុះចន្លោះពីមនុស្សម្នាក់ ពីអ្នកទោសម្នាក់ទៅមនុស្សម្នាក់ទៀតនៅក្នុងកង់តែមួយនុ៎ង ចន្លោះប្រវែងប៉ុនណាដែរ?

**ឆ៖** គេអត់មានដាក់អ្នកទោសមួយចន្លោះម្នាក់ឯងផង ដាក់ គឺដាក់កៀបតម្រៀបគ្នាកៀប មួយចន្លោះប្រាំនាក់ហ្នឹងដាក់ឲ្យណែនតែម្តង អត់មានដាក់ទូលាយ អត់មាន អាចនឹងទូលាយបានទេ។

**ស៖** បាទ សូមលោកស្តាប់សំណួររបស់ខ្ញុំ។ ខ្ញុំចង់និយាយថា ក្នុងមួយកង់ –ដែលលោកមានប្រសាសន៍ថាមានប្រាំនាក់ហ្នឹង– ខ្ញុំចង់បញ្ជាក់ថា ពីមនុស្សម្នាក់ទៅមនុស្សម្នាក់នោះ មានចន្លោះប៉ុន្មាន? ឬក៏អាចលោកបញ្ជាក់ថា ក្នុងចំនួនប្រាំនាក់នោះ មានប្រវែងប៉ុន្មានម៉ែត្រ?

**ឆ៖** ក្នុងចន្លោះហ្នឹង គេអត់មានដាក់វាស់ម៉ែត្រវាស់តឹកទេ ព្រោះគេដាក់មួយចង្អៀត និយាយមួយចង្អៀតហ្នឹងតែម្តង គ្នាប្រាំនាក់ហ្នឹង។ បើខ្វះពីប្រាំនាក់ គេយកមកដាក់ថែមទៀត អត់មានវាស់មានតឹកអីទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា អ្នកក្នុងចំណោមប្រាំនាក់ដែលគេដាក់ហ្នឹង គឺបានន័យថាគេប្រជ្រៀតគ្នា ពីមួយដល់ប្រាំជាប់ៗគ្នា អត់មានចន្លោះទេ ក៏ប៉ុន្តែពីក្នុងចន្លោះពីប្រាំនាក់ទៅប្រាំនាក់ផ្សេងទៀតគឺមានចន្លោះពីមួយម៉ែត្រកន្លះទៅពីរម៉ែត្រកន្លះ តាមប្រសាសន៍របស់លោក។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំអត់មានថាពីរម៉ែត្រកន្លះទេ ខ្ញុំប៉ាន់ស្មានថាមួយម៉ែត្រកន្លះទេ ប្រាំនាក់ហ្នឹង។ ការប៉ាន់ស្មានរបស់ខ្ញុំ ព្រោះខ្ញុំគ្មានម៉ែត្រវាស់ផង។

[១១:២៨:០៩]

**ស៖** បាទ ខ្ញុំយល់ពីការប៉ាន់ស្មានរបស់លោក សុំលោកបញ្ជាក់សាឡើងវិញ ព្រោះចម្លើយរបស់លោកអាចយល់ច្រឡំអម្បាញ់មិញនេះ។ ព្រោះខ្ញុំសួរពីចន្លោះ ខ្ញុំអត់សួរពីក្នុងរង្វង់ចំណោមអ្នកជាប់ទោសប្រាំនាក់នោះទេ គឺខ្ញុំសួរពីចន្លោះ ពីរវាងអ្នកប្រាំនាក់ទី១ ទៅអ្នកប្រាំនាក់ទី២ទៀតនោះ ដែលលោកឆ្លើយពីដើមមកថា មិនលើសពីពីរម៉ែត្រ ហើយខ្ញុំចង់បញ្ជាក់ឡើងវិញជូនអង្គជំនុំជម្រះថា អ្នកទោស

ដែលគេដាក់ក្នុងចន្លោះប្រាំនាក់ហ្នឹង គឺគេដាក់បញ្ចៀតគ្នាគឺថា អត់មានចន្លោះទេតែនៅពេលដែលគ្រប់ប្រាំនាក់ហើយ ត្រូវដាក់ប្រាំនាក់ទៀត គឺអាចមានចន្លោះពីមួយម៉ែត្រកន្លះ ឬក្រោមពីរម៉ែត្រ ហ្នឹងតាមសក្ខីកម្មរបស់លោក។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ប្រធានអង្គជំនុំ៖**

បន្តទៀត! មិនបាច់ឆ្លើយតបទេ។ តសំណួរផ្សេងទៀត! សំណួរច្រំដែល សំណួរដឹកមុខថែមទៀតផង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសុំឲ្យលោកបញ្ជាក់ពីរឿងពេលវេលាដែលលោកបានបញ្ជាក់ពីការចាប់ខ្លួនឪពុករបស់លោក ហើយលោកបានរៀបរាប់ថា ការចាប់ខ្លួនរបស់ឪពុកលោកហ្នឹង ដោយសារតែមានការរៀបចំឲ្យមានការប្រជុំមួយ ជាមីទ្ទិងមួយទម្លាក់មេភូមិដែលលោកប្រើពាក្យថា “រដ្ឋប្រហារមេភូមិ”។ តើចំណុចនេះលោកអាចបញ្ជាក់ពីពេលវេលាថា ពេលវេលានៃការកើតឡើង នៃការប្រជុំ និងមកដល់ពេលចាប់ខ្លួននេះមានរយៈពេលប៉ុន្មានថ្ងៃ? ឬក៏ប៉ុន្មានអាទិត្យដែរ?

**ឆ៖** រយៈពេលធ្វើរដ្ឋប្រហារចាប់ខ្លួន អត់រំលងពីរថ្ងៃទេ ក្នុងមួយថ្ងៃ ស្អែកឡើងគេចាប់ឪពុកខ្ញុំ បងថ្លៃខ្ញុំ គេចាប់ថ្ងៃទី១ហ្នឹងតែម្តង។

**ស៖** បាទ សូមអរគុណ។ លោកដឹងថាអ្នកណាជាអ្នកនាំឲ្យមានការចាប់ខ្លួននេះទេ? បានន័យថាអ្នកបង្កើតឲ្យមានការចាប់ខ្លួននេះ។

[១១:៣១:០១]

**ឆ៖** ខ្ញុំគ្រាន់តែដឹង គេប្រាប់ខ្ញុំថា មានពីឃុំពីថ្នាក់លើមកឲ្យសំបុត្រ អាបឿន – បងថ្លៃខ្ញុំហ្នឹង។ គេថា អាបឿន វាចាញ់បោកគេហើយ គេឲ្យធ្វើមីទ្ទិងផ្តិតមេដៃសម្រាប់ចាប់មេភូមិឲ្យនៅខាងកើតត្រពាំង។

**ស៖** សូមលោកបញ្ជាក់ លោកដឹងថាមេឃុំ ហើយលោកថាមេឃុំជាថ្នាក់លើ។ តើនេះជាសក្ខីកម្មរបស់លោក អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ។

**ស៖** ចុះអ្នកដែលចូលរួមមកចាប់ លោកស្គាល់ថាអ្នកណាខ្លះដែលចូលរួមចាប់ ឬក៏អ្នកអនុវត្តការបញ្ជារបស់មេឃុំហ្នឹង?

**ឆ៖** អ្នកចាប់ខ្លួនងាប់បាត់ហើយ។ ខ្ញុំមិនអាចប្រាប់បាន ឈ្មោះអ្នកស្លាប់ជីវិតបាត់ហើយ។

**ស៖** ចង់និយាយថា លោកស្គាល់ឈ្មោះទេ អ្នកដែលចាប់ហ្នឹង?

**ឆ៖** --

**ស៖** សូមលោកឆ្លើយ--

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយតប ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណ៎ះ!

**លោក មាស សុខា៖**

**ឆ៖** ស្គាល់។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកអាចរៀបរាប់បានទេ?

**ឆ៖** រៀបរាប់បញ្ជាចាប់ខ្លួនឪពុកខ្ញុំអ្នេស! តើយ៉ាងម៉េច?

**ស៖** រៀបរាប់ឈ្មោះអ្នកដែលលោកថាស្គាល់ អ្នកដែលមកចាប់ខ្លួនឪពុករបស់លោក។

**ឆ៖** រៀបរាប់ -- ឈ្មោះ ជា ជាមេល្ខបឃុំ។ បន្ទាប់មក រុំ ប៉ុន្តែស្លាប់បាត់ហើយពីរនាក់ហ្នឹង។

**ស៖** លោកស្គាល់ពីអ្នកទាំងអស់នោះដែរទេ ក្នុងសម័យដែលលោករស់នៅក្នុងរបបនុ៎ង?

**ឆ៖** របបហ្នឹងខ្ញុំស្គាល់អ្នកចាប់ឪពុកខ្ញុំ គឺខ្ញុំស្គាល់ច្បាស់ ប៉ុន្តែស្លាប់បាត់អស់ហើយ។

**ស៖** លោកអាចបញ្ជាក់ថាអ្នកទាំងអស់នោះជាមនុស្សយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំម៉េចមិនដឹង ព្រោះគេអ្នកបញ្ជាឲ្យមកចាប់ហើយ ខ្ញុំអត់ដឹងដែរ តើគេអាចធ្វើទុក្ខ ធ្វើទោសឪពុកខ្ញុំ ក៏ខ្ញុំអត់ដឹង។

[១១:៣៣:៥៦]

**ស៖** បាទ ដោយសារអម្បាញ់មិញនេះ លោកបានឆ្លើយថាលោកស្គាល់អ្នកទាំងអស់នោះ អ្នកចាប់ខ្លួនឪពុកលោកច្បាស់ណាស់។ ហើយអ៊ីចឹងបានខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ជូនអង្គជំនុំជម្រះថា តើលោកស្គាល់ពីអត្តចរិត ឬក៏ពីលក្ខណៈរបស់បុគ្គលទាំងអស់នោះយ៉ាងម៉េចដែរ។ តើលោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំមិនអាចដឹងទេ រឿងអត្តចរិតគេ។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរសំណួរទូទៅវិញ។ ទាក់ទងទៅនឹងព័ត៌មានដែល--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលបញ្ហា *(ឮមិនច្បាស់)*។

*(មានបញ្ហាបច្ចេកទេស)*

[១១:៣៧:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមសួរបន្តទាក់ទងទៅនឹងព័ត៌មានខ្លះៗ។ ថាតើក្នុងរយៈពេលពីឆ្នាំ១៩៧៩ រហូតមកដល់ ពេលដែលមានការិយាល័យសហចៅក្រមស៊ើបអង្កេតទៅសាកសួរលោក ។មានបានធ្លាប់ពិភាក្សា ឬក៏និយាយពីបញ្ហាមន្ទីរឃុំឃាំងក្រាំងតាចាន់នោះជាមួយអ្នកណាខ្លះទេ?

**លោក មាស សុខា៖**

**ឆ៖** មានក្រុមស្រាវជ្រាវឯកសារ ក្លួយ ភារិទ្ធិ, អ្នកស្រី កល្យាណ។

**ស៖** បាទ សូមអរគុណ។ ម៉េចបានគេដឹងថាលោកធ្លាប់ជាប់នៅមន្ទីរក្រាំងតាចាន់?

**ឆ៖** គេស្រាវជ្រាវពីត្រាំកក់ ពីមន្ទីរស្រុកត្រាំកក់ ព្រោះខ្ញុំធ្លាប់និយាយពីរឿងប្រវត្តិខ្ញុំ។

**ស៖** បាទ ទាក់ទងទៅនឹងព័ត៌មានរបស់លោក ដែលលោកបានពិភាក្សាជាមួយអ្នកដទៃវិញ។ ខ្ញុំអត់និយាយពីអ្នកដែលទៅចុះស្រាវជ្រាវទេ។ តើលោកមានបានពិភាក្សាជាមួយអ្នកណា ។ខ្លះដែលបានផ្តល់ព័ត៌មានឲ្យលោក? ឬក៏លោកបានផ្តល់ព័ត៌មានទៅគេវិញទាក់ទងនឹងក្រាំងតាចាន់នេះ?

**ឆ៖** ពេលខ្ញុំ-- កាលខ្ញុំនៅធ្វើទាហានស្រុកត្រាំកក់ ខ្ញុំនិយាយទៅដល់កន្លែងណា គឺខ្ញុំនិយាយរឿងហ្នឹងកន្លែងហ្នឹង កន្លែងតំបន់ស្រុកត្រាំកក់ហ្នឹងតែម្ដង ព្រោះអ្នកណាក៏ស្គាល់ខ្ញុំដែរ។ ក្នុងបរិវេណស្រុកត្រាំកក់ឱ្យតែអ្នកធំ គឺស្គាល់ខ្ញុំទាំងអស់ ព្រោះខ្ញុំនិយាយប្រវត្តិខ្ញុំថាខ្ញុំជាប់គុកនៅក្រាំងតាចាន់រយៈជិត បីឆ្នាំ។ ទោះបីមេឃុំណាក៏ស្គាល់ខ្ញុំថាខ្ញុំជាប់នៅហ្នឹងដែរ។

[១១:៣៩:៤៨]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា លោកតែងតែដើរនិយាយប្រាប់ពីបញ្ហាហ្នឹងទៅគេរហូត។ ហើយចុះលោកមានដែលទទួលព័ត៌មានពីគេវិញថា ក្រាំងតាចាន់ហ្នឹងយ៉ាងម៉េចដែរទេ?

**ឆ៖** អត់ដែលបានព័ត៌មានទេ។

**ស៖** បាទ សូមបញ្ជាក់មកវិញ។ ចុះម្ដាយរបស់លោក លោកដែលបានទទួលព័ត៌មានពីម្ដាយរបស់លោកទេ?

**ឆ៖** ខ្ញុំអត់ដែលបាននិយាយជាមួយម្ដាយ ឬទទួលព័ត៌មានអ្វីពីម្ដាយ។

**ស៖** បាទសូមអរគុណ។ ចុះបងប្អូនឬក៏មិត្តភក្តិដទៃទៀតក៏លោកអត់ដែលបានទទួលដែរមែនទេ?

**ឆ៖** គេគ្រាន់តែទទួលព័ត៌មានពីខ្ញុំ ខ្ញុំនិយាយគេមិនបាន គេយកចិត្តទុកដាក់ស្ដាប់តែប៉ុណ្ណឹង គេគ្រាន់តែថា "អឺ! អ្នែងកំសត់ណាស់" តែប៉ុណ្ណឹង "ក្រុមគ្រួសារអ្នែង" និយាយតែប៉ុណ្ណឹង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន សូមអនុញ្ញាតឱ្យសហមេធាវីដៃគូបន្តបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ អង់តា ហ្គិសសេ!

[១១:៤១:២២]

**សួរដោយកញ្ញា អង់តា ហ្គិសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក មាស សុខា ខ្ញុំឈ្មោះ អង់តា ហ្គិសសេ។ ខ្ញុំមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ យើងមិនមានពេលវេលាច្រើនទេ ដូច្នេះខ្ញុំសូមចោទសំណួរច្បាស់លាស់ ហើយនិងខ្ញុំសូមឱ្យលោកឆ្លើយខ្លីៗ ហើយច្បាស់លាស់ដែរ។

**ស៖** ជាបឋម ខ្ញុំសូមចាប់អារម្មណ៍ទៅលើការរស់នៅរបស់លោក មុនឆ្នាំ១៩៧៥ នៅក្នុង សហ

ករណ៍របស់លោក។ លោកបាននិយាយអំពីប្រធានសហករណ៍ ឈ្មោះ អ៊ុន ណុប។ តើលោកដឹងថា អ៊ុន ណុប នោះគាត់ក្លាយជាប្រធានសហករណ៍ហ្នឹងនៅពេលណាដែរ?

**លោក មាស សុខា៖**

**ឆ៖** គាត់ក្លាយខ្លួនជាមេភូមិតាំងពីឆ្នាំ៧០ ដល់ឆ្នាំ៧៥, ៧៦ ដល់ខ្ញុំបែកពីគ្នាគាត់។ ខ្ញុំអត់ដឹងទៅណា ដល់បែកពីគ្នា ខ្ញុំអត់ដឹងទៅណា។ ដឹងតែថាទៅនៅបាត់ដំបង តែប៉ុណ្ណឹងទេ។

**ស៖** កាលបរិច្ឆេទហ្នឹងជាការគ្រប់គ្រាន់ហើយ។ ខ្ញុំដឹងថាលោកនៅក្មេងកាលណោះ តើលោកដឹងថា អ៊ុន ណុប ហ្នឹងមានបញ្ហាអីច្បាស់ជាក់លាក់ទេ ជាមួយនឹងឪពុកលោក ហើយនិងបងថ្លៃរបស់លោក មុនពេលមានការប្រជុំមួយដែលលោកបានឆ្លើយចំពោះមុខតុលាការអម្បាញ់មិញនេះថាមានការប្រជុំមួយ?

**ឆ៖** ខ្ញុំដឹងច្បាស់លាស់តែត្រង់គេឲ្យបងថ្លៃខ្ញុំ ហើយនិងឪពុកខ្ញុំធ្វើជាមីទ្ទិងហ្នឹង។ ហើយពីមុនមកកាលពី -- និយាយរួមកាលពីអតីតកាលគាត់មានទាស់ទែងគ្នាខ្លះ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** បាទ ខ្ញុំសូមអរគុណដែលបានបំភ្លឺ។ លោកក៏បាននិយាយផងដែរ នៅទីនេះ គឺថាក្រោយពីកិច្ចប្រជុំដែលជាមូលហេតុនៃការចាប់ខ្លួនឪពុកលោក ហើយនិងបងថ្លៃរបស់លោកហ្នឹង គឺថារយៈពេលខ្លីមក បន្ទាប់មកទៀតហ្នឹង ឪពុកលោកហើយនិងបងថ្លៃរបស់លោកត្រូវបានអង្គការកោះហៅ។ លោកបានប្រើពាក្យ "អង្គការ"ហ្នឹង។ តើលោកអាចបញ្ជាក់បានទេក្នុងបរិបទនេះ តើអង្គការហ្នឹងជាអ្នកណា? ហើយអ្នកទទួលខុសត្រូវនៅក្នុងឃុំនោះ អ្នកដែលកោះហៅឪពុកលោក ហើយបងថ្លៃលោកហ្នឹងជាអ្នកណាដែរ?

**ឆ៖** ខ្ញុំដឹងតែមេឃុំឈ្មោះ ហឿន តែប៉ុណ្ណឹង ខ្ញុំដឹងតែឈ្មោះ ហឿន។ ក្រៅពីនោះ ខ្ញុំអត់ដឹង ហឿន (ស្រី)។

[១១:៤៥:២២]

**ស៖** សវនាការថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ម៉ោង ១០:៥៩:០៥ វិនាទី ខាងមេធាវី នួន ជា បានសួរលោក ហើយលោកបានឆ្លើយថា "ខ្ញុំមិនបានចូលរួមក្នុងការជីកប្រឡាយទេ ខ្ញុំគ្រាន់តែមើលគោក្របីទេ ព្រោះខ្ញុំនៅជាកុមារ"។ ហើយមេធាវី នួន ជា ក្នុងពេលនោះបានសួរបញ្ជាក់មួយអំពីចម្លើយរបស់លោក លោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេត គឺឯកសារ D25/3។ ខ្ញុំសូមរាប់លេខ ERN ជាភាសាបារាំង គឺ 00178111, ERN ជាភាសាអង់គ្លេសគឺ 00223494, ERN ជាភាសាខ្មែរគឺ

00163511។ នៅក្នុងចម្លើយនេះលោកបានឆ្លើយថា៖ “គេបានឱ្យខ្ញុំប្រមូលអាចម៍គោ ហើយនិងជីកប្រឡាយនៅក្នុងកងចល័ត<កុមារ>”។ <> អ៊ីចឹង សំណួរខ្ញុំសួរថាតើលោកបានជីកប្រឡាយដែរឬទេ? បានចូលរួមជីកប្រឡាយនេះទេ? ពីព្រោះថាខ្ញុំឃើញថា<លោកបានផ្តល់>ចម្លើយពីរខុសគ្នា<>។ តើលោកអាចបញ្ជាក់ជូនតុលាការបានទេ? ម្តងថាជីកប្រឡាយ ម្តងថាអត់បានជីកទេ។

**ឆ៖** ខ្ញុំជម្រាបដល់តុលាការ ពេលណា ខ្ញុំចប់កិច្ចការរើសអាចម៍គោ គេឱ្យទាំងចូលរួមជីកប្រឡាយបានតិចតួច។ ខ្ញុំជម្រាបប្រាប់លោកតុលាការអ៊ីចឹង។ ព្រោះតិចតួចណាស់ ខ្ញុំបានជីកប្រឡាយនោះ។ ពេលនោះគេថា “បើអ្នែង ពេលណាកើបអាចម៍គោហ្នឹងហើយ ទៅជួយរែកប្រឡាយគេខ្លះផង”។

[១១:៤៧:០០]

**ស៖** ក៏ប៉ុន្តែនៅសវនាការនៅថ្ងៃទី០៨ មករា នៅម៉ោងដប់មួយបីនាទី <>លោកបានឆ្លើយយ៉ាងដូច្នេះ៖ “ខ្ញុំមិនបានចូលរួមក្នុងការជីកប្រឡាយទេ ក៏ប៉ុន្តែខ្ញុំ គេឱ្យខ្ញុំមើលគោក្របី ព្រោះថាខ្ញុំនៅតូច។ ដូច្នេះ គេមិនឱ្យជីកប្រឡាយទេ”។ សូមបញ្ចប់ការដកស្រង់។ តើខ្ញុំត្រូវយល់យ៉ាងម៉េច? ខ្ញុំត្រូវយល់ថាលោកផ្លាស់ប្តូរចម្លើយរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំអត់ផ្លាស់ប្តូរ ព្រោះខ្ញុំចូលរួមខ្លះៗដែរ ព្រោះប្រឡាយនោះគឺជីក ខ្ញុំជីកតិច។ ខ្ញុំមិនមែនជីកច្រើនរាប់ថ្ងៃរាប់ខែដូចគេទេ។ ព្រោះកូនប្រឡាយតូចៗសម្រាប់កុមារ។ ហើយកាលណាខ្ញុំទំនេរ គេត្រូវប្រើឱ្យទៅរែក មួយថ្ងៃបានយ៉ាងច្រើនបីបួនអម្រែកអ៊ីចឹង។ ដល់ពេលម៉ោង យើងត្រឡប់មកហូបបាយវិញ។ ហ្នឹង ខ្ញុំមិនសន្មតថាខ្ញុំនៅជីកថិតថេរជាប់ ថេរកាលជាប់ជួនណា។

**ស៖** ខ្ញុំថាទទួលយកចម្លើយហ្នឹងទៅចុះ។ ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយពីការរស់នៅរបស់លោកនៅមន្ទីរក្រាំងតាចាន់។ លោកនិយាយថា នៅមន្ទីរសន្តិសុខនោះ លោកបានបន្តធ្វើការ គឺថាមើលគោក្របីដែរ។ សំណួរទី១ គឺថាតើការងារហ្នឹងគឺជាការងារលោកដែលធ្វើប្រចាំថ្ងៃ ឬក៏យ៉ាងម៉េច មើលគោក្របីហ្នឹង?

**ឆ៖** គោក្របីគឺប្រចាំថ្ងៃ។ ទោះដល់ថ្ងៃ ខ្ញុំវិលត្រឡប់កន្លែងត្រៀម គេយកមកដាក់នៅភូមិតារាបនោះ ទាល់តែថ្ងៃឈប់នៅកន្លែងហ្នឹង។

[១១:៤៩:០០]

**ស៖** <> លោកបានរៀបរាប់អង្គហេតុមួយចំនួននៅតុលាការទាក់ទងទៅនឹងការសួរចម្លើយដែលលោកបានធ្វើជាសាក្សី លោកបានឃើញ ហើយនិងការសម្លាប់មនុស្ស ដែលលោកបានឃើញដែរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឬក៏បានឃើញដោយផ្ទែក។ តើលោកអាចបញ្ជាក់បានទេ ថាគឺជារយៈពេលដែលគេឲ្យលោកឃ្វាលគោនៅពេលហ្នឹង? <>

**ឆ៖** ឃ្វាលគោ ពេលហេតុការណ៍ គេធ្វើហេតុការណ៍សម្រាប់ឲ្យមនុស្សអ្នកជាប់ក្នុងហ្នឹង អ្នកធ្វើការក្រៅម៉ោងហ្នឹងគេបញ្ជូនហើយ។ គ្រាន់តែខ្ញុំមួយប៉ុន្មាននាក់ គឺគេឲ្យដើរឃ្វាលគោខាងក្រៅ ហើយពេលឃើញហេតុការណ៍ យើងចង់មើល យើងទៅលបមើលបន្តិចទៅ។ ពេលល្ងាចម៉ោងបួន ម៉ោងបីអីហ្នឹង។ ទៅមើលឲ្យគេឃើញអី ឲ្យគេឃើញ នាំរឿង។

**ស៖** លោកបានរៀបរាប់អំពីជីវិតប្រចាំថ្ងៃរបស់លោកនៅមន្ទីរសន្តិសុខនោះ ថាក្រោយពីឆ្នាំ៧៦ លោកមានសិទ្ធិសេរីភាពក្នុងការផ្លាស់ទី<>នៅក្នុងពេលថ្ងៃ។ តើជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថាលោកមិន<រីករាយនឹងតួនាទី>ស្មើនឹងអ្នកទោសផ្សេងទៀតទេ<>?

**ឆ៖** ពិតមែនហើយ។

[១១:៥០:៥២]

**ស៖** តើឋានៈរបស់លោកហ្នឹង<ការ>ហូបចុកហ្នឹងក៏ខុសគ្នាដែរ<ទេ? លោកបាននិយាយថា> លោកបានចំណីអាហារពីរពេលក្នុង<មួយថ្ងៃ តើអាហារទាំងនោះដូចគ្នា ឬក៏ខុសគ្នាពី>អ្នកទោសផ្សេងទៀត<>?

**ឆ៖** ខ្ញុំចំណែកពួកអ្នកទោស គេអត់ដែលឲ្យហូបចុកក្រៅពីពីរពេលហ្នឹងទេ ពីរពេលអ្នកទោសក្នុងអគារក៏ដូចខ្ញុំអ្នកខាងក្រៅដែរ ប៉ុន្តែគ្រាន់តែខ្ញុំលើសបបរវែកធំជាងគេបន្តិច អ្នកនៅក្នុងពន្ធនាគារគេឲ្យហូបមួយវែកតូច។

**ស៖** ហេតុអ្វីក៏លោកបានរបបអាហារច្រើនជាងគេអ៊ីចឹង?

**ឆ៖** គេថា ឲ្យវាមានកម្លាំងឲ្យដើរមើលគោមើលក្របី។

**ស៖** មិនមែនទាក់ទងទៅនឹងការដែលថាម្ដាយលោកហ្នឹងធ្វើការនៅចង្ក្រានបាយ <>បានជាឲ្យលោកហូបចុកច្រើនជាងគេបន្តិចនោះ?

**ឆ៖** អត់ទាក់ទងជាមួយម្ដាយទេរឿងហូបចុក យើងអ្នកទោសតើមាន មិនយុត្តិធម៌គឺគេធ្វើបាបដល់ម្ដាយខ្ញុំទៀត។ ស្រេចតែអង្គការគេមកចាត់ចែងទេរឿងហ្នឹង។

[១១:៥២:៤០]

**ស៖** ឥឡូវនេះខ្ញុំសូមនិយាយាអំពីចម្លើយរបស់ម្ដាយរបស់លោក។ <>សហចៅក្រមស៊ើប

អង្កេត<បានសម្ភាស>គាត់ គឺឯកសារ D25/30 ក៏ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺខ្សែអាត់នៃចម្លើយរបស់គាត់។ ខ្ញុំសូមដកស្រង់មួយផ្នែកទេ។ ឯកសារយោងគឺ ERN ជាភាសាបារាំង <0105 6616> រហូតដល់ 17, ERN ជាភាសាខ្មែរគឺ 01056208 រហូតដល់ 09, ERN ជាភាសាអង់គ្លេស 01056614 ទៅដល់ 15។ ជាបឋមខ្ញុំសូមចោទសំណួរដូចតទៅនេះ គឺថានៅម៉ោង <០០:៣០:៥៧> អ្នកស៊ើបអង្កេត៖ “ពេលដែលលោក<ស្រីនៅក្នុងគុក> តើគេបានប្រព្រឹត្តអាក្រក់លើលោកទេ?” ចម្លើយរបស់ម្ដាយរបស់លោកគាត់ឆ្លើយថា៖ “មកខ្ញុំអ្ហ៎?” <សំណួរ៖> “ហ្នឹងហើយ” ចម្លើយ<ពីម្ដាយលោក> ឆ្លើយថា៖ “ទេគេមិនដែលបានធ្វើបាបខ្ញុំទេ ដោយសារខ្ញុំអាចធ្វើការឲ្យគេបានទាំងអស់ ដូចខ្ញុំត្រូវការមើលការខុសត្រូវលើអ្នកទោសពី២០០<នាក់> ៥០នាក់ <ឬ៦០នាក់>”។ សំណួរបន្តទៀត៖ “ហើយកូនៗរបស់លោកស្រី?” ចម្លើយ “<>កូនរបស់ខ្ញុំគឺធ្វើការនៅខាងក្រៅ ព្រោះគេធ្វើការខាងឃ្វាលគោឃ្វាលក្របី” ហើយចម្លើយ “អ៊ីចឹងហ៎?” ចម្លើយរបស់គាត់ថា “ហ្នឹងហើយ”។ <>សំណួរ៖ <“>គេអត់ធ្វើបាបពួកគាត់ទេហី?” ចម្លើយរបស់ម្ដាយលោកស្រីថា “អត់ទេ គេមិនធ្វើបាបពួកវាទេ អត់ធ្វើបាបពួកវាទាល់តែសោះ”។ បាទសូមបញ្ចប់ការដកស្រង់។

[១១:៥៥:០៧]

ហើយខ្ញុំសូមដកស្រង់ផ្នែកមួយទៀតនៃខ្សែអាត់ស្ដាប់ចម្លើយរបស់ម្ដាយលោក <ដែលគាត់និយាយអំពីរបបអាហារ>។ <>លេខយោងដដែលគឺថាមុនហ្នឹងបន្តិច គឺម៉ោង <០០:៣០:៥៧> <គេបានសួរ>គាត់ទាក់ទងទៅនឹងរបបអាហាររបស់អ្នកទោស។ ម្ដាយរបស់លោកឆ្លើយដូចតទៅនេះគឺ ថាប្រធាន<បាន>ប្រាប់គាត់ថា<>៖ “<មេឃុំបានប្រាប់ខ្ញុំថា> មិនចាំបាច់ទៅឲ្យវាស៊ីគ្រប់គ្រាន់ទេ ឲ្យពួកវាស៊ីម៉ាល្មមៗបានហើយ<។ តែប៉ុណ្ណឹង។ នេះជាអ្វីដែលមេឃុំប្រាប់ខ្ញុំ។>”។ សំណួរបន្តទៀត៖ “អ៊ីចឹងអ្ហ៎? ចម្លើយរបស់<ម្ដាយ>លោកគឺថា៖ “ហ្នឹងហើយគេប្រាប់ខ្ញុំអ៊ីចឹង”។ ហើយគាត់បន្តទៀតថា៖ “គេប្រាប់ខ្ញុំថាមិនចាំបាច់ឲ្យវាស៊ីឆ្អែតទេ តិចៗបានហើយ ហើយទុកនៅសល់ទាំងប៉ុន្មានឲ្យកូនខ្លួនឯងស៊ីទៅស៊ីឲ្យឆ្អែតទៅ”។ អ៊ីចឹងសំណួរ បន្ទាប់ពីបានស្ដាប់ចម្លើយរបស់ម្ដាយរបស់លោកនេះ តើលោកចាំទេ<> ថាដោយសារគាត់ធ្វើការនៅខាងចង្ក្រានបាយហ្នឹងហើយបានលោកហ្នឹងបានហូបចុកឆ្អែតច្រើនជាងគេ។ អ៊ីចឹងឬក៏មិនមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតប។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ <> ខ្ញុំមិនដឹង<>ថាមានបញ្ហាបកប្រែឬអត់ទេ ប៉ុន្តែចម្លើយគឺថាប្រធានគុកទេដែលបញ្ជា គឺមិនមែនមេឃុំទេ <ខ្ញុំមិនដឹងថាជាកំហុសខាងការបកប្រែ ឬយ៉ាងណានោះទេ> ប៉ុន្តែជាអង់គ្លេសដែលមេធាវីការពារក្តីអានដូចជាចេញមកថាជាមេឃុំ ប៉ុន្តែតាមពិតគឺប្រធានគុកទេ ដែលនិយាយរឿងនោះ។ <ដូច្នេះកំណត់ត្រាត្រូវតែច្បាស់លាស់ចំពោះរឿងនេះ។>

[១១:៥៧:៣៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជាភាសាបារាំងអម្បាញ់មិញ ដែលខ្ញុំអានអំមិញ ខ្ញុំនិយាយគ្រាន់តែប្រធានទេ <ហើយនៅក្នុងសម្រង់ដែលខ្ញុំបានអាន ក៏មិនច្បាស់លាស់ដែរ>។ ក៏ប៉ុន្តែ<វាអាចយល់បានថា> <ខ្ញុំសំដៅទៅលើ> ប្រធានគុកហើយ។ <ដូច្នេះគ្មានបញ្ហាអីទៅលើចំណុចនេះទេ។> អ៊ីចឹងសួរថាសាក្សីអាចឆ្លើយនឹងខ្ញុំបានទេថាដោយសារតែម្តាយខ្លួនហ្នឹងធ្វើជាចុងភៅ -- មានបញ្ហាបកប្រែឬក៏ខ្ញុំអាចនិយាយបន្តទៀតបាន? -- លោកសាក្សីខ្ញុំសួរលោកគឺថាតើដោយសារតែម្តាយលោកធ្វើការនៅចង្ក្រានបាយនៃមន្ទីរសន្តិសុខហ្នឹង ហើយបានជាលោកបានការហូបចុកបន្ថែមនោះ <ហើយលោកក៏រីករាយនឹងឋានៈពិសេសនេះនៅមន្ទីរឃុំឃាំងនោះដែរ>?

**<លោក មាស សុខា៖>**

**ឆ៖** ខ្ញុំជម្រាបដល់បញ្ហាអាហារហ្នឹងដល់អស់លោក។ បញ្ហាអាហារហូបចុករបស់ក្រុមគ្រួសារខ្ញុំ គេឲ្យថាគេឲ្យហូបចែក ក៏ប៉ុន្តែបបរនោះគឺមិនមែនឆ្អែតទេ គ្រាន់តែលើសគេៗមួយវែកធំ តែបបររាវៗអត់មានកាកអង្ករទេ មានតែតិចៗ ហើយនិងមានដំឡូងបួនប្រាំដុំតែប៉ុណ្ណឹងទេ ឬលើសតែប្រាំដុំចុះ ប្រាំដុំៗមិនមែនធំទៀត ដុំប៉ុនៗមេដៃ។ ហើយឲ្យមានជីវជាតិអី អត់មានជីវជាតិទេ--

**ស៖** លោកសាក្សីខ្ញុំសូមកាត់ផ្តាច់លោក ពីព្រោះថាយើងមិនមានពេលវេលាច្រើនទេ។ ខ្ញុំសុំសួរសំណួរលោកច្បាស់លាស់ ហើយអ៊ីចឹងសុំឲ្យលោកឆ្លើយខ្លីៗច្បាស់ៗដែរ បើមិនអ៊ីចឹងទេ ខ្ញុំមិនអាចសួរសំណួរលោកចប់បានទេ។ ទាក់ទងទៅនឹងដំណើរការនៃមន្ទីរសន្តិសុខហ្នឹង លោកបានឆ្លើយពាក់ព័ន្ធនឹងឈ្មោះអ្នកធ្វើការនៅទីនោះមួយចំនួនដូចជាអ្នកយាម ឬក៏អ្នកទទួលខុសត្រូវនៅទីនោះជាដើម<។> ដើម្បីកុំឲ្យៗ ច្រលំឬមានបញ្ហាអ្នកអានឈ្មោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន គឺសូមបញ្ចាំងចម្លើយនៅលើឯកសារ D25/31 នេះទៅសាក្សីគឺ លេខ ERN គឺលេខជាភាសាបារាំងគឺ 00178116 ជាភាសាខ្មែរគឺ 00163517, ជាភាសាអង់គ្លេស 00223500។ នេះគឺជាផ្នែកនៃចម្លើយរបស់លោកសាក្សីដែលក្នុងផ្នែកនោះគាត់រៀបរាប់ឈ្មោះមនុស្សមួយចំនួន ដែលជាបុគ្គលិកនៃមន្ទីរសន្តិសុខនោះ។

លោកប្រធានខ្ញុំសុំអនុញ្ញាតបញ្ចាំងឈ្មោះនេះទៅឲ្យលោកសាក្សីមើលលោកប្រធាន។

*(ការបង្ហាញឯកសារជារូបភាព)*

**<ប្រធានអង្គជំនុំ៖>**

<អង្គជំនុំជម្រះអនុញ្ញាត។>

[១២:០០:៥៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីផ្អែកហ្នឹងខ្ញុំបញ្ចាំងទៅលើអេក្រង់ហើយ ខ្ញុំសុំសង្ខេបជាមួយលោកបន្តិច។ ឈ្មោះដែលលោកបានរៀបរាប់នោះ គឺមានឈ្មោះលោក អាន់ មានឈ្មោះអាន់មួយ, បន្ទាប់មកមាន ពេញ, បន្ទាប់មកឈ្មោះ ឌុច, បន្ទាប់មកទៀត ចេង, បន្ទាប់មកទៀត មឿន, បន្ទាប់មកទៀតឈ្មោះ អ្នក , បន្ទាប់មកទៀតមាន ឌុច មួយទៀត, បន្ទាប់មក ស៊ឹម, ហើយបន្ទាប់មក សាំង, ហើយបន្ទាប់មកទៀត មានឈ្មោះ ស៊ាន់, ហើយ ឈឿន បន្ទាប់មកទៀត ហើយនៅចុងក្រោយគេឈ្មោះ ទូច។

តើត្រឹមត្រូវទេលោកបានរៀបរាប់ឈ្មោះទាំងអស់នេះទៅសហចៅក្រមស៊ើបអង្កេត?

**លោក មាស សុខា៖**

**ឆ៖** អត់ទាន់ត្រឹមត្រូវទេ។ ខ្វះមនុស្សម្នាក់ទៀត សៀង។ សៀង អ្នកឃាតកម្ម។

**ស៖** អរគុណ។ ខ្ញុំគិតថាប្រហែលជាឈ្មោះគាត់ហ្នឹងប្រហែលជាមាននៅ<>ខាង ក្រោមទៀតមានឈ្មោះគាត់។ សំណួរខ្ញុំស្រួលទេ លោកបាននិយាយថា លោកបានឃើញមានការសម្លាប់មនុស្សជាង១០០នាក់ អ្នកទោសជាង ១០០នាក់នៅឆ្នាំ១៩៧៧។ អ៊ីចឹង ខ្ញុំចង់ដឹងថាក្នុងចំណោមបុគ្គលិកដែលលោកបានរៀបរាប់នៅក្នុងចម្លើយលោកនេះ តើមានពួកគាត់ប៉ុន្មាននាក់<មានវត្តមាន>នៅថ្ងៃដែលលោករៀបរាប់ថាមានការសម្លាប់មនុស្សនោះ? <>ហើយបើសិនជាមាន អ្នកណាខ្លះ?

**ឆ៖** វត្តមានអ្នកសម្លាប់ គឺដកតែ ឌុច ធំមួយ ហើយនិងអ្នកធ្វើបាយចង្ក្រានមួយ តែពីរនាក់ហ្នឹង។ ឌុច ធំគាត់ដកខ្លួនចេញទៅក្រៅ ស្រុកក្រៅហើយ។

**ស៖** អ៊ីចឹងខ្ញុំអរគុណ។ អ៊ីចឹង ពេញ ហើយនិង ស៊ាន់ អីហ្នឹងមានវត្តមាននៅទីហ្នឹងដែរ។ អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន។

[១២:០៣:៤៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឃើញថាម៉ោងដប់ពីរហើយ ខ្ញុំមិនទាន់បានសួរចប់ទេលោកប្រធាន ខ្ញុំព្យាយាមសួរលឿនដែរ ប៉ុន្តែដោយសារមានបញ្ហាបច្ចេកទេសផង តើអង្គជំនុំជម្រះអាចអនុញ្ញាតឲ្យខ្ញុំមានពេល ១០នាទីទៀតទេ ដើម្បីសួរបញ្ចប់?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត អញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បុគ្គលិកមន្ទីរសន្តិសុខហ្នឹងដដែល លោកបាននិយាយអំពីការចាក់មីក្រូនៅក្នុង<មន្ទីរសន្តិ-សុខ>។ លោកថា<ពួកគេនៅក្នុងមន្ទីសន្តិសុខ។> <តើ>លោក<អាចប្រាប់យើងឲ្យច្បាស់បានទេ តើពួកគេនៅ>កន្លែងណា? <តើពួកគេនៅក្នុងអគារឬ? ហើយតើនៅក្នុងអគារមួយណា?> លោកនិយាយថាមានអគារដល់ទៅបីឯណោះ អ៊ីចឹង<តើលោកអាចប្រាប់ឲ្យច្បាស់លាស់បានទេ ថាតើមីក្រូទាំងអស់នោះនៅ>កន្លែងណា<>?

**<លោក មាស សុខា៖>**

**ឆ៖** គេដាក់ចំបុកទៅអគារ ឲ្យកន្លែងណាមានមនុស្សនៅ គេដាក់ធុងបះប៉ុនៗនេះ មួយកន្លែងមួយៗ ហើយមីក្រូមួយ។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថាធុងបាស ឬមីក្រូហ្នឹង<បែរមុខទៅអគារ ប៉ុន្តែ>នៅខាង<>ក្រៅ<>ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** នៅខាងក្រៅ គេដាក់អែបនឹងជញ្ជាំង។

**ស៖** សូមអរគុណដែលបានបំភ្លឺ។ អ៊ីចឹង អ្នកណាជាអ្នក<>ចាក់មីក្រូ<នៅពេលសួរចម្លើយ

និងសម្លាប់មនុស្សនោះ>? ឈ្មោះអី អ្នកចាក់មីក្រូហ្នឹង<>?

ឆ៖ អ្នកណាបើកក៏បើកទៅ ក្នុងបុគ្គលិកគេ១២នាក់ហ្នឹង អត់មានចាំបាច់ឈ្មោះណាៗ។

ស៖ បើអ៊ីចឹងលោកចង់និយាយថា គេអត់មានបានចាត់តាំងអ្នកណាឲ្យធ្វើការងារខាងចាក់មីក្រូហ្នឹងច្បាស់លាស់ទេ។ អ៊ីចឹងទេ?

ឆ៖ អត់ពិតប្រាកដទេ រឿងចាក់មីក្រូ អត់ចាំបាច់មានអ្នកណាម្នាក់កាន់កាប់ទេ អត់មានទេ។ អ្នកណាបើកៗទៅ ឲ្យពេលគេធ្វើការ។

[១២:០៦:៥៥]

ស៖ នៅសវនាការថ្ងៃទី២១ ខែ១ <ឆ្នាំ២០១៥> ម៉ោង ១១:១៩:២៣ លោកបាននិយាយអំពីអ្នកដែលត្រូវបានគេសម្លាប់ ថាចំនួនហ្នឹងវាប្រែប្រួលអាចថា៥០ - ៧០ ទៅ ១០០ អី<។> ហើយរាល់ថ្ងៃនោះ មាន<>អ្នកទោស<យ៉ាងតិច>២០នាក់<។ ហើយអ្នកទោសទាំងអស់នោះ>មកដល់មន្ទីរសន្តិ-សុខហ្នឹង មកដល់ពេលយប់។ បើអ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ។ លោកបានឆ្លើយផងដែរ ដើម្បីឲ្យគ្រប់គ្រាន់តែម្តង គឺថានៅថ្ងៃទី២១ ខែ១ <ឆ្នាំ២០១៥> ប្រហែលជាម៉ោង ១០:២២:៤៨ លោកនិយាយថា៖ “អគារហ្នឹង<មិន>អាចទទួលអ្នកទោសបាន<>ជាង១០០នាក់<ទេ ក្នុងពេលម្តងៗ>។ ខ្ញុំសូមឲ្យលោកឆ្លើយប្រាប់តុលាការថាតើជាមធ្យមនៅក្នុងមន្ទីរឃុំឃាំង ហ្នឹងមានអ្នកទោសមកដល់ប្រហែលប៉ុន្មាននាក់ក្នុងមួយខែ? <>ព្រោះថាចំនួនតួលេខដែលលោកឲ្យហ្នឹង យើងមិនអាចដឹងថាអ្នកទោសមានប៉ុន្មាននាក់ទេនៅក្នុងមន្ទីរសន្តិសុខហ្នឹង។ កាលនុ៎ង លោកថាលោកមានអាយុ១៥ឆ្នាំហើយ។ អ៊ីចឹងបើតាមការចងចាំរបស់លោកនោះមានប្រហែលជាប៉ុន្មានជាមធ្យមក្នុងមួយខែ?

ឆ៖ ខ្ញុំអត់ចងចាំទេ រឿងមួយខែហ្នឹង ខ្ញុំដឹងតែយប់ឡើង ព្រោះខ្ញុំនៅដេកខាងក្រៅ គេនាំមកយប់ឡើងមានជួន១០នាក់ ២០នាក់ ៣០នាក់អ៊ីចឹងទៅ។ មួយយប់នាំមកបីដងអ៊ីចឹងទៅ។ ដល់ពេលអគារមួយ ដាក់ទៅអគារមួយទៅ។ យប់ស្អែកឡើងគេនាំបន្តទៀតមក ដល់ពេញអគារហ្នឹង បានគេបន្តសម្លាប់ ឬអត់ពេញក៏គេត្រូវតែសម្លាប់ដែរ។

ស៖ បើអ៊ីចឹងបានន័យថា បើតាមលោកដឹងនោះពីចន្លោះពី១០ ទៅ២០នាក់ដែលមកដល់មន្ទីរសន្តិសុខហ្នឹងក្នុងមួយយប់។ អ៊ីចឹងមែនទេ?

ឆ៖ ពិតមែនហើយ។

ស៖ អ៊ីចឹងគឺថាមួយយប់ប្រហែល១០ទៅ២០នាក់។ អ៊ីចឹងបើគុណនឹង៣០ទៅ យើងបាន

E1/250.1

ប្រហែល ទៅដល់វា៣០០នាក់ លើសពី៣០០នាក់។ បើអ៊ីចឹងបើតាមការប៉ានស្មានហ្នឹង <> មួយខែ ប្រហែលជាង៣០០នាក់?

**ឆ៖** ខ្ញុំថាមានពីលើសពី៣០០។

[១២:១០:00]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសាក្សី ឥឡូវខ្ញុំសូមដកស្រង់នៃចម្លើយរបស់បុគ្គលិកម្នាក់ដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខហ្នឹង ដែលឲ្យតួលេខមួយដែលមិនត្រូវគ្នានឹងតួលេខរបស់លោកទេ គឺជារបស់សាក្សី TCW-847 នេះជារហស្សនាមទេ ហើយគឺជាចម្លើយរបស់ D40/23។ បុគ្គលនោះគាត់បានឆ្លើយដូចតទៅនេះ គាត់បានធ្វើការនៅមន្ទីរសន្តិសុខនុ៎ងដែរ។ ERN ជាភាសាបារាំងគឺ <00490901>, ERN ជាភាសាខ្មែរគឺ 00165355, ERN ជាភាសាអង់គ្លេសគឺ 00223211 ជាភាសាអង់គ្លេស។ សំណួរសួរដូចតទៅនេះ អ្នកស៊ើបអង្កេតសួរទៅសាក្សីហ្នឹង <“>ទាក់ទងទៅនឹងអ្នកទោសដែលគេនាំទៅមន្ទីរសន្តិសុខក្រាំងតាចាន់ <ជាទូទៅ>តើរាល់ដងហ្នឹងគេនាំប៉ុន្មាននាក់<?> <តើគេយកអ្នកទាំងនោះមកយ៉ាងម៉េច>? ហើយដោយមធ្យោបាយអី?” ចម្លើយរបស់គាត់៖ “រាល់ដងគេនាំមកតែពីរបីនាក់ទេម្តង ហើយមានអ្នកទោសប្រហែលជា ២០ ទៅ ២៥នាក់ក្នុងមួយខែ ហើយគេនាំមកហ្នឹង<ដោយដើរ> ប្រហែលជាខ្ទង់ម៉ោង <ប្រាំពីរ ឬ>ប្រាំបីយប់។ លោកសាក្សី បុគ្គលរូបនេះ<ធ្វើការ>នៅមន្ទីរសន្តិសុខក្រាំងតាចាន់ដែរ គាត់ថាមានអ្នកទោសប្រហែលជា ២០ ទៅ២៥នាក់ទេក្នុងមួយខែ។ ហើយរីឯលោកវិញ លោកនិយាយថាពី ២០០ ទៅ ៣០០នាក់ក្នុងមួយខែ។ តើលោកអាចបញ្ជាក់បានទេ? ពន្យល់ពីភាពខុសគ្នាទាំងនេះបានទេលោកសាក្សី?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំ<មានសំណូមពរ ប្រសិនបើសាក្សីរូបនេះត្រូវបានសួរឲ្យបញ្ចេញយោបល់អំពីបញ្ហា>នេះ<>។ <មេធាវីការពារក្តីត្រូវផ្តល់ឯកសារចម្លង នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីផ្សេងទៀត ទៅឲ្យសាក្សីនេះ ដូច្នេះយើងអាចមើលឃើញថា តើបុគ្គលម្នាក់នេះជានរណា។ សាក្សីនេះមិនស្គាល់រហស្សនាមនោះទេ។ ប្រសិនបើសួរគាត់ឲ្យបញ្ចេញយោបល់ទៅលើកំណត់ហេតុស្តាប់ចម្លើយ

សាក្សីផ្សេងទៀត ខណៈយើងរក្សាការសម្ងាត់បែបនេះ សាក្សីនេះគួរតែមានសិទ្ធិដឹងថា តើនរណាដែលជាអ្នកបានផ្តល់ចម្លើយនោះ។ ដូច្នេះខ្ញុំជឿថា នោះជាការអនុវត្តដែលធ្វើតាមសវនាការដំបូង។ វាគួរតែត្រូវបានអនុវត្តនៅទីនេះ ដូច្នេះហើយ សាក្សីរូបនេះយល់បានថា តើចម្លើយនេះចេញមកពីអ្នកណា។ ជាការពិត សាក្សីនេះក៏គួរតែត្រូវបានណែនាំផងដែរ គឺកុំឱ្យនិយាយឈ្មោះសាក្សីផ្សេងទៀត ប្រសិនបើសាក្សីផ្សេងទៀតនោះ ជាសាក្សីដ៏មានសក្តានុពលរបស់អង្គជំនុំជម្រះ។>

[១២:១២:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនមានបញ្ហាអីទេ ខ្ញុំអាចប្រាប់ឈ្មោះគាត់បាន ដោយសារខ្ញុំចង់ធ្វើឱ្យលឿន កុំឱ្យខាតពេលវេលា ប្រសិនជាអង្គជំនុំជម្រះ<អនុញ្ញាត>ឱ្យខ្ញុំ<មាន>ពេលពីរបីនាទីបន្ថែមទៀត។ អត់មានបញ្ហាអីទេខាងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានសូមឱ្យមន្ត្រីតុលាការយកឯកសារនេះទៅឱ្យគាត់ ព្រោះមានឈ្មោះសាក្សីនោះនៅក្នុងហ្នឹង។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីការពារក្តីយកទៅជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១២:១៤:២៤]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំ<នឹង>ផ្តល់ឯកសារហ្នឹង ប៉ុន្តែដើម្បីកុំឱ្យខាតពេលវេលា ខ្ញុំសូម<ព្យាយាមសួរបញ្ចប់សំណួរទាំងនេះ។ លោកសាក្សី ឯកសារដែលខ្ញុំនិយាយថា សាក្សីផ្សេងទៀតបានផ្តល់តួលេខខុសពីលោកនោះ គេបាននាំយកទៅឱ្យលោកហើយ>។

កុំឱ្យប្រាប់ឈ្មោះសាក្សីហ្នឹង ព្រោះគាត់មិនទាន់បានមកផ្តល់សក្ខីកម្មនៅទីនេះ ព្រោះជាសាក្សីដែលត្រូវលាក់ឈ្មោះ។ ដូច្នេះខ្ញុំសូម<ឱ្យលោក>មើលឈ្មោះគាត់ហ្នឹង ឃើញមានគូសពីក្រោមឈ្មោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

E1/250.1

គាត់ហើយ។

**សួរដោយ កញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងៗសូមលោកបញ្ជាក់មើល តើគាត់ហ្នឹង? លោកស្គាល់គាត់ទេ? ហើយគាត់ពិតជាធ្វើការនៅមន្ទីរសន្តិសុខហ្នឹងមែនទេ? លោកសាក្សីលោកឃើញឈ្មោះហ្នឹងទេ ដែលមានគូសពីក្រោម ហើយសូមកុំប្រាប់ឈ្មោះហ្នឹង។

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំស្គាល់។ ប៉ុន្តែការបិទបាំងរបស់គេ។

**ស៖** ខ្ញុំសួរថាតើ បុគ្គលនោះគាត់ធ្វើការនៅមន្ទីរសន្តិសុខហ្នឹងមែនទេ?

**ឆ៖** គាត់ធ្វើនៅហ្នឹង។

**ស៖** ដល់អ៊ីចឹង តើលោកអាចពន្យល់ពីភាពខុសគ្នាបានទេ ថាតួលេខ ខុសគ្នា គាត់និយាយថា ពី២០ទៅ២៥ក្នុងមួយខែ ហើយលោក លោកនិយាយថា ពី២០០ទៅ២៣០នាក់ ក្នុងមួយខែឯណាឯណោះ។

**ឆ៖** ការបិទបាំងរបស់គេ រឿងនេះ ព្រោះគេអ្នកនៅធ្វើហ្នឹង គេមិនអាចចំហពាក្យសម្តីថា ក្នុងមួយខែ ១០០នាក់ ២០០នាក់ ៣០០នាក់ជាងទេ គេមិនចំហ ព្រោះគេនៅធ្វើការបុគ្គលិកនៅហ្នឹង។

[១២:១៧:៣១]

**ស៖** ហេតុអីបានទៅជាអ៊ីចឹង បិទបាំងអីហ្នឹង?

**ឆ៖** ព្រោះខ្លាចថា គេជាអ្នកដែលដល់នៅកន្លែងនោះដែរ។

**ស៖** ហើយចារី ដែលគេចោទប្រកាន់នោះ តើគាត់ទៅធ្វើការជាពេជ្ឈឃាដ ឬក៏គាត់មានមុខងារអីផ្សេងទេ នៅក្នុងមន្ទីរសន្តិសុខហ្នឹង?

**ឆ៖** គាត់នីរសារ។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនខុសទេ បើតាមលោកហ្នឹង គឺថាគាត់អត់មានបានចូលរួមសួរចម្លើយ ហើយនិងសម្លាប់ទេ អ៊ីចឹងមែនទេ?

**ឆ៖** អត់ទេ។

**ស៖** លោកបានឆ្លើយផងដែរថា លោកគេងហើយនៅពេលដែលអ្នកទោសមកដល់ អ៊ីចឹងហើយលោកមិនបានដឹងចំនួនច្បាស់ទេ។ អ៊ីចឹងសំណួរខ្ញុំសួរថា <ពាក់ព័ន្ធនឹងជនដែលដល់ ឬមិនមែននោះ លោកនិយាយថា> គាត់ហ្នឹងមិនពាក់ព័ន្ធទៅនឹងការកាប់សម្លាប់មនុស្សទេ ឬក៏ការសួរចម្លើយអ្នកទោសទេ។

អ៊ីចឹងខ្ញុំសួរថា មានហេតុផលអីដែលគាត់ត្រូវកុហកអំពីតួលេខការសម្លាប់មនុស្សនៅពេលនោះនុះ?

**ឆ៖** គាត់អៀនខ្មាសខ្លួនគាត់ ព្រោះខ្លួនគាត់នៅកន្លែងហ្នឹងដែរ ប៉ុន្តែគាត់ត្រូវការបិទបាំងខ្លះអ៊ីចឹង។ ខ្ញុំសន្និដ្ឋានខ្លួនខ្ញុំអ៊ីចឹង ព្រោះគាត់មិនហាន សូវហ៊ានចេញចំហាមុខ។

**ស៖** អ៊ីចឹងនេះគឺ<ជំហររបស់លោក ហើយនេះគឺជាការពន្យល់តែមួយគត់ ដែលលោកអាចពន្យល់បានទាក់ទងទៅនឹងតួលេខដែលលោកប្រាប់យើងនោះ>។ អ៊ីចឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអា<ល>ទាន់ឆ្លើយតប។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ជាច្រើនដងទេ ប៉ុន្តែសំណួរនេះ សួរឲ្យសាក្សីសន្និដ្ឋាន <អំពីសាក្សីផ្សេងទៀត។ ការឆ្លើយតបរបស់គាត់ទៅនឹងសំណួរ គឺល្អបំផុតតាមដែលគាត់អាចធ្វើបាន>។ ហើយខ្ញុំមិនឃើញមានគោលបំណងឲ្យសួរសំណួរដដែលៗនេះ ហើយសូមឲ្យសាក្សីឆ្លើយដោយសន្និដ្ឋានអំពីចេតនាគាត់ទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំគិតថា ខ្ញុំដូចជាមិនសួរដដែលៗទេ។ ខ្ញុំគ្រាន់តែលើពីភាពផ្ទុយគ្នាទេ។ <> ខ្ញុំគិត <វាសមរម្យហើយចំពោះសាក្សីដែលគេអនុញ្ញាតឲ្យ>ធ្វើអត្ថាធិប្បាយ មុននឹង<>កោះហៅ<សាក្សីមួយទៀត>មក<បំភ្លឺ>នៅពេលក្រោយ។ អ៊ីចឹង <ខ្ញុំ>ផ្ដល់ឱកាសឲ្យសាក្សីនេះ ធ្វើការកត់សម្គាល់ទៅលើ<អ្វីដែលគាត់បាននិយាយ>។ អ៊ីចឹង បើមើលទៅឃើញថាម៉ោងនោះវាច្រើនណាស់ទៅហើយ ហួសម៉ោងពេលបាយទៅហើយ។ អ៊ីចឹង ខ្ញុំសូមអរគុណលោកប្រធាន ដែលបានផ្ដល់ពេលវេលាបន្ថែមឲ្យខ្ញុំ។ សូមបញ្ចប់ត្រឹមណេះលោកប្រធាន។

[១២:២១:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ អង្គជំនុំជម្រះសូមអរគុណចំពោះលោក មាស សុខា ដែលបានលោកចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងប៉ុន្មានថ្ងៃប៉ុន្មានសាកន្លងមកនេះ។ ហើយការស្ដាប់សក្ខីកម្មរបស់លោកក្នុងនាមជាសាក្សី រហូតមកដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅបន្ទប់សវនាការនេះ លែងមានភាពសំខាន់ និងចាំបាច់ទៀត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយ ហើយលោក មាស សុខា អាចវិលត្រឡប់ទៅលំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅវិញបានហើយ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការជូនលោក មាស សុខា វិញត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់ចង់ទៅវិញចុះ។

ហើយឥឡូវនេះ ដល់ពេលថ្ងៃត្រង់ សម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការ ហើយយើងស្ដាប់សក្ខីកម្មសាក្សី អ៎! ស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប ដែលមានរហស្សនាម 2-TCCP-296។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:២២ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនា 2-TCCP-296។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីមានឈ្មោះថា អ៊ុំ សុផានី អ៊ីចឹងពិតមែនដែរទេ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ចាស សូមគោរពលោកប្រធាន ខ្ញុំឈ្មោះ អ៊ុំ សុផានី មែន។

**ស៖** តើលោកស្រីអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ ថាលោកស្រីកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំកើតនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៤៦។

**ស៖** បាទអរគុណ ហើយតើលោកស្រីមានទីកន្លែងកំណើតនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំមានទីកំណើតនៅសង្កាត់លេខ៤ ទីក្រុងភ្នំពេញ។

**ស៖** ចុះសព្វថ្ងៃនេះ តើលោកស្រីមានទីលំនៅនៅកន្លែងណា?

**ឆ៖** ខ្ញុំនៅផ្ទះលេខ១២០បេ ផ្លូវ១០៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ទីក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ ហើយចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ ៧៩ តើលោកស្រីរស់នៅទីកន្លែងណា? ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧០ -- សូមៗសួរម្ដងទៀត។

**ស៖** បាទ ពី១៧មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩ តើលោកស្រីរស់នៅទីកន្លែងណា ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** ពេលនោះខ្ញុំរស់នៅឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ភូមិត្រពាំងជម្រៅ នៅទីក្រុងតាកែវ ឥឡូវខេត្តតាកែវ។

**ស៖** កាលនោះ គេឲ្យលោកស្រីធ្វើអ្វី?

**ឆ៖** ខ្ញុំធ្វើជាកសិករ។

**ស៖** បាទអរគុណ។ ហើយតើឪពុកលោកស្រីឈ្មោះអ្វី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ អ៊ុំ សាមឿន។

**ស៖** ចុះម្ដាយរបស់លោកស្រី គាត់ឈ្មោះអី?

**ឆ៖** ម្ដាយខ្ញុំឈ្មោះ ធូ សំបូរ។

**ស៖** អរគុណ។ ហើយចុះប្ដីលោកស្រីវិញ គាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីខ្ញុំឈ្មោះ ស៊ូ ណន។ ខ្ញុំមានកូនពីរនាក់។ កូនស្រីឈ្មោះ ស៊ូ បុទុម កូនប្រុសឈ្មោះ ស៊ូ អម្រិត។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយលោកស្រី អ៊ុំ សុផានី ជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកស្រីក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ ហើយដោយអនុវត្តនូវបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតលើរឿងក្ដី។ ហើយសូមបញ្ជាក់ផងដែរថា មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីរួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលកន្លះថ្ងៃក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

[១៣:៤២:២៤]

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សម្រាប់ការសួរ សាកសួរសំណួរទៅលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីនេះ មេធាវីនាំមុខសុំផ្ទេរ -- អនុញ្ញាតលោកប្រធានផ្ទេរសិទ្ធិនេះជូនលោក យីគាំង លូ ដើម្បីសួរសំណួរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញបាទ!

**លោក យីគាំង លូ៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោក លោកស្រីទាំងអស់។ ខ្ញុំឈ្មោះ ម៉ៃយ៉ែរ គាំងលូ ហើយខ្ញុំជាមេធាវីរបស់លោកស្រី សុផានី។ នៅរសៀលនេះ ខ្ញុំនឹងចំណាយពេលប្រហែលមួយម៉ោងកន្លះដើម្បីសួរសំណួរទៅលោកស្រី សុផានី។ មុនពេលដែលខ្ញុំផ្ដល់ឱកាសជូនលោកស្រី<>ថ្លែង<>រៀបរាប់ទុក្ខសោក <និងសំណួររបស់គាត់ទៅកាន់ជនជាប់ចោទ>។ ឥឡូវនេះ ខ្ញុំសូមចាប់ផ្ដើម។

ដូច្នេះជាដំបូងខ្ញុំសូមជម្រាបសួរលោកស្រី សុផានី។ លោកស្រីស្ដាប់ខ្ញុំឮដែរទេ? ខ្ញុំឃើញលោកស្រីងក់ក្បាលហើយ។ ដូច្នេះ មុនពេលដែលខ្ញុំចាប់ផ្ដើមជម្រាបសួរលោកស្រី ខ្ញុំចង់ជម្រាបលោកស្រីបី

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ចំណុច។

ទី១ ប្រសិនបើលោកស្រីមិនយល់សំណួរខ្ញុំ ឬក៏ដោយសារលោកស្រីស្តាប់មិនច្បាស់ ឬក៏ដោយសារការបកប្រែមិនច្បាស់ លោកស្រីអាចសួរខ្ញុំ។ នៅក្នុងពេលសួរសំណួរ ខ្ញុំនឹងបង្ហាញឯកសារមួយចំនួន។ ប្រសិនបើលោកស្រីមើល ឬក៏ឃើញឯកសារហ្នឹងមិនច្បាស់ សូមប្រាប់ខ្ញុំផង ខ្ញុំនឹងព្យាយាមជួយពន្យល់លោកស្រី។ ហើយនៅពេលដែលលោកស្រីឆ្លើយសំណួរ សូមលោកស្រីពិនិត្យមើលទៅលើពណ៌ភ្លើងពណ៌ក្រហមនៅលើមីក្រូហ្វូន។ ប្រសិនបើភ្លើងក្រហមបើក សូមលោកស្រីនិយាយ ប្រសិនបើភ្លើងក្រហមមិនទាន់ឆេះទេ សូមលោកស្រីកុំទាន់ឆ្លើយ។ លោកស្រីយល់នូវអ្វីដែលខ្ញុំបញ្ជាក់ដែរឬទេ?

**លោកស្រី អ៊ុំ សុផានី៖**

ចាស ខ្ញុំយល់លោកមេធាវី។

**លោក យីគាំង លូ៖**

សូមអរគុណលោកស្រី។

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមចាប់ផ្តើមសួរដោយបង្ហាញឯកសារមួយជូនទៅលោកស្រី សុផានី។ ឯកសារនេះគឺនៅក្នុងសំណុំរឿង ខ្មែរ ERN មានលេខ 01032943, ភាសាអង់គ្លេសមានលេខ 01036454, ចំណែកភាសាបារាំង គឺមានលេខ 01036470។

ខ្ញុំសូមអនុញ្ញាតលោកប្រធានប្រគល់ឯកសារនេះ ជូនទៅលោកស្រី អ៊ុំ សុផានី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យ!

[១៣:៤៥:៤១]

**លោក យីគាំង លូ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់ទាំងអស់ ដើម្បីឱ្យអ្នកទាំងអស់គ្នាបានមើលឃើញ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក យីគាំង លូ៖**

**ស៖** ឥឡូវនេះ យើងឃើញឯកសារនៅលើអេក្រង់ លោកស្រី សុផានី តើលោកស្រីអាចប្រាប់យើងបានដែរឬទេ ថាឯកសារនេះជាឯកសារអ្វី?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ចាសលោកមេធាវី ឯកសារនេះជាកំណត់ហេតុដែលខ្ញុំបានសរសេរនៅសម័យ ប៉ុល ពត។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកស្រីសរសេរកំណត់ហេតុនេះនៅក្នុងរបបខ្មែរក្រហម?

[១៣:៤៧:២៤]

**ឆ៖** បានជាខ្ញុំសរសេរកំណត់ហេតុនេះនៅក្នុងសម័យខ្មែរក្រហម ពីព្រោះខ្ញុំមានបងស្រីម្នាក់ បងស្រីទី២របស់ខ្ញុំ ពីព្រោះខ្ញុំមានបងប្អូនប្រាំពីរនាក់។ បងស្រីទី២របស់ខ្ញុំឈ្មោះ អ៊ុំ ណារ៉ាត លោកបានទូន្មានខ្ញុំថា បើប្អូនចង់ក្លាយទៅជាអ្នកនិពន្ធ ចូលប្អូនសរសេរកំណត់ហេតុតាំងពីថ្ងៃនេះទៅ។ ពេលនោះ-- ដែលគាត់ពន្យល់ខ្ញុំគឺនៅក្នុងឆ្នាំ១៩៦៤ -- ពេលនោះ ខ្ញុំមិនដឹងជាថាត្រូវសរសេរពីអ្វី គាត់ប្រាប់ខ្ញុំថា សូមប្អូនសរសេរពីអ្វីដែលរៀងរាល់ថ្ងៃ។ ហើយខ្ញុំអត់ទាន់យល់ពីបំណងរបស់បងស្រីខ្ញុំឲ្យខ្ញុំសរសេរទេ។ ខ្ញុំក៏ចាប់ផ្ដើមសរសេរៗរហូតៗដល់ឆ្នាំ១៩៧៥។ ដល់ពេលគេជម្លៀសខ្ញុំទៅ ខ្ញុំគ្មានបានយកឯកសារទេ គឺថាពីឆ្នាំ១៩៦៤ រហូតដល់ឆ្នាំ១៩៧៥ហ្នឹង គឺឯកសារនៅក្នុងផ្ទះខ្ញុំទាំងអស់ ហើយខ្ញុំទៅតែខ្លួន។ ប៉ុន្តែដោយសារតែខ្ញុំមានទម្លាប់សរសេរ ពេលដែលខ្ញុំបានក្រដាស បានឃើញក្រដាស ឃើញប៊ិក ខ្ញុំចាប់ផ្ដើមសរសេរកំណត់ហេតុនេះទៀតទៅ។

**ស៖** សូមអរគុណអ្នកស្រី។ តើអ្នកស្រីមានអារម្មណ៍យ៉ាងដូចម្ដេចដែរ នៅពេលដែលអ្នកស្រីសរសេរកំណត់ហេតុបែបនេះ?

[១៣:៤៨:៥៥]

**ឆ៖** ពេលដែលខ្ញុំសរសេរកំណត់ហេតុ គឺខ្ញុំមាន ខ្ញុំ អ្វីដែលខ្ញុំលាក់នៅក្នុងចិត្ត ខ្ញុំបាននិយាយចេញមកតាមកំណត់ហេតុ ធ្វើឲ្យខ្ញុំបានធូរស្រាលក្នុងអារម្មណ៍។

**ស៖** ដូច្នេះខ្ញុំចង់សួរលោកស្រីបន្តិច នៅក្នុងរបបខ្មែរក្រហម តើមានអ្នកណាម្នាក់ដឹងថា លោកស្រីសរសេរកំណត់ហេតុបែបនេះទុកដែរឬទេ?

**ឆ៖** ដោយសារតែនៅក្នុងសម័យខ្មែរក្រហម ពេលដែលយើងចេញពីភ្នំពេញទៅ គេចេះតែប្រាប់ថាខ្មែរក្រហមសាហាវណាស់ ប៉ុន្តែខ្ញុំអត់ទាន់បានដឹងថាសាហាវរបៀបម៉េចទេ គ្រាន់តែពេលចេញទៅឃើញមនុស្សស្លាប់អីៗអ៊ីចឹង ហើយគេ ទៅតាមផ្លូវគេប្រមូលមនុស្ស ថាយកទៅរៀនសូត្រអ៊ីចឹង។ ចេះតែដឹងឮតិចៗ ហើយពេលជួបអ្នកណាគេថា "ប្រយ័ត្នណា ប្រយ័ត្នដែលគេសម្លាប់" ចេះតែឮអ៊ីចឹង។ អ៊ីចឹងខ្ញុំត្រូវតែមានការប្រយ័ត្នប្រយែង ពីព្រោះខ្ញុំត្រូវគិតពីអាយុជីវិតខ្ញុំដែរ ខ្ញុំមិនឲ្យអ្នកណាដឹងទេ។ សូម្បីតែឪពុកម្តាយក្មេករបស់ខ្ញុំ និងប្តីរបស់ខ្ញុំក៏គាត់មិនដឹងថាខ្ញុំសរសេរកំណត់ហេតុដែរ។ ដូច្នេះ ខ្ញុំលាក់។

**ស៖** សូមអរគុណអ្នកស្រី។ តើជាមធ្យមក្នុងមួយថ្ងៃ អ្នកស្រីចំណាយពេលប្រហែលជាប៉ុន្មាននាទី ប៉ុន្មានម៉ោង ដើម្បីសរសេរកំណត់ហេតុនេះ?

**ឆ៖** ខ្ញុំសរសេរកំណត់ហេតុនេះ ពីពីរទៅបីនាទី ពីព្រោះជាកំណត់ហេតុខ្លីៗ។

**ស៖** អ្នកស្រីនៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ អ្នកស្រីបានដាក់នូវសៀវភៅមួយដែលមានចំណងជើងថា <"កាលណាយើងជួបគ្នា"> តើអ្នកស្រីអាចពន្យល់បានទេ ថាតើសៀវភៅនេះ និងកំណត់ហេតុហ្នឹង គឺវាមានទំនាក់ទំនងគ្នាបែបណា?

[១៣:៥១:១៣]

**ឆ៖** សៀវភៅៗដែលខ្ញុំសរសេរ "កាលណាយើងជួបគ្នា"នេះ គឺខ្ញុំយោងទៅលើកំណត់ហេតុដែលខ្ញុំសរសេរខ្លីៗ ពីព្រោះខ្ញុំសរសេរនៅក្នុងឆ្នាំ១៩៨០។ ដូច្នេះ ខ្ញុំមិនទាន់ភ្លេចអ្វីៗដែលកន្លងផុតមកទេ។ ពេលដែលខ្ញុំសរសេរកំណត់ហេតុខ្ញុំសរសេរខ្លីៗ ដល់ពេលខ្ញុំយកមកក្នុងសៀវភៅ "កាលណាយើងជួបគ្នា" គឺខ្ញុំនឹកពីអ្វីដែលខ្ញុំបានជួបប្រទះ។ ហ្នឹងខ្ញុំអត់សរសេរអស់ផង បើសិនជាខ្ញុំសរសេរអស់មិនដឹងជារាប់រយសន្លឹក មិនដឹងយ៉ាងម៉េច យ៉ាងណាទេ។

**ស៖** សូមអរគុណអ្នកស្រី។ ឥឡូវនេះ ខ្ញុំចង់ពិភាក្សាទៅលើកំណត់ត្រារបស់អ្នកស្រី។ ខ្ញុំចង់បង្ហាញ<ទំព័រ>មួយទៀត<នៃកំណត់ត្រារបស់លោកស្រី> គឺខ្ញុំចង់បង្ហាញនៅលើអេក្រង់ ហើយខ្ញុំសូមអនុញ្ញាតប្រគល់ជូនលោកស្រីគឺខ្មែរមានលេខ 01032946, ភាសាអង់គ្លេសមានលេខ 01036456, ភាសាបារាំងមានលេខ 01036472។

**លោក យីគាំង លូ៖**

លោកប្រធានខ្ញុំ តើខ្ញុំអាចប្រគល់ឯកសារនេះជូនទៅដើមបណ្តឹងរដ្ឋប្បវេណី និងដាក់បង្ហាញនៅលើអេក្រង់បានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោក យីគាំង លូ៖**

**ស៖** ឯកសារនេះគឺមាននៅលើអេក្រង់រួចទៅហើយ។ ដូច្នេះលោកស្រី តើលោកស្រីអាចប្រាប់បានដែរឬទេថា តើឯកសារហ្នឹងគឺមានកាលបរិច្ឆេទថ្ងៃណាដែរ គឺខាងលើបំផុត និងខាងក្រោមបំផុតនោះ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** កាលបរិច្ឆេទរបស់ថ្ងៃដែលខ្ញុំសរសេរកំណត់ហេតុនេះ គឺថ្ងៃខាងលើបំផុតមានថ្ងៃ០៥ ខែ៥ ១៩៧៥។ ចុងបំផុតគឺមានថ្ងៃ០៩ ខែ៥ ៧៥។

**ស៖** សូមអរគុណអ្នកស្រី។ នេះគឺជាកំណត់ត្រាដែលអ្នកស្រីសរសេរនៅក្នុងខែឧសភា ឆ្នាំ៧៥។ អ្នកស្រីអាចប្រាប់បានដែរឬទេថានៅក្នុងខែនេះ នៅក្នុងរយៈពេលនេះ អ្នកស្រីនិយមសរសេរញឹកញាប់ប៉ុនណាដែរ កំណត់ហេតុនៅឆ្នាំ៧៥ហ្នឹង?

**ឆ៖** ពេលដែលខ្ញុំសរសេរកំណត់ហេតុដើមដំបូងឡើង គឺយើងនៅកំពុងតែរត់ នៅកំពុងតែជម្លៀសចេញពីភ្នំពេញ។ ដូច្នេះ ខ្ញុំមានពេលសរសេររៀងរាល់ថ្ងៃ។ អ៊ីចឹងបានជាឃើញនៅក្នុងកំណត់ហេតុខ្ញុំ ថ្ងៃទី០៥, ថ្ងៃទី០៦, ថ្ងៃទី០៧, ថ្ងៃទី០៨, ថ្ងៃទី០៩។ ចាស គឺសរសេររៀងរាល់ថ្ងៃ។

**ស៖** សូមអរគុណអ្នកស្រី។

**លោក យីគាំង លូ៖**

ឥឡូវនេះ ខ្ញុំសុំបង្ហាញឯកសារមួយទៀត។ ដូច្នេះ ខ្ញុំសុំអនុញ្ញាតលោកប្រធានបង្ហាញឯកសារទំព័របន្តនៅលើអេក្រង់ និងប្រគល់ឯកសារជូនទៅលោកស្រី សុផានី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៣:៥៥:១៧]

**សួរដោយលោក យីគាំង លូ៖**

**ស៖** លោកស្រី សុផានី ខ្ញុំចង់ឲ្យលោកស្រីពិនិត្យមើលបន្តិចទៅលើឯកសារនេះ។ លោកស្រី

សូមលោកស្រីពិនិត្យមើលទៅលើឯកសារនេះ គឺដូចគ្នានឹងឯកសារមុននេះដែរ តើលោកស្រីអាចពិនិត្យមើល <តើលោកស្រីអាចប្រាប់ថ្ងៃខែសរសេរបានទេ?> លោកស្រីសរសេរកំណត់ហេតុហ្នឹងញឹកញាប់ប៉ុនណាដែរ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** គឺថាក្រោយមក ខ្ញុំសរសេរមិនសូវញឹកញាប់ទេ ដោយសារតែយើងមានការងារធ្វើ ហើយយើងមិនសូវមានពេលៗសរសេរ បានជាមិនសូវញឹកញាប់។

**ស៖** សូមអរគុណអ្នកស្រី។ តើអ្នកស្រីអាចអាននូវកាលបរិច្ឆេទដំបូងនៃកំណត់ត្រាហ្នឹង និងកាលបរិច្ឆេទចុងក្រោយនៃកំណត់ត្រាហ្នឹង តើវានៅក្នុងអំឡុងពេលណាដែរ?

**ឆ៖** កាលបរិច្ឆេទទី១ គឺដំបូងគឺថ្ងៃ០៣ ខែ១២ ឆ្នាំ១៩៧៥។ ខាងក្រោមបំផុតគឺថ្ងៃ០៣ ខែ០២ ឆ្នាំ១៩៧៦។

**ស៖** សូមអរគុណអ្នកស្រី។ អ្នកស្រីនិយាយថា អ្នកស្រីសរសេរតិចជាងលើកមុន។ ខ្ញុំចង់ដឹងថាហេតុអ្វីបានជាក្នុងរយៈពេលនេះ អ្នកស្រីសរសេរបានតិចជាងរយៈពេលមុន?

**ឆ៖** បានជាខ្ញុំសរសេរតិច ពីព្រោះអីខ្ញុំរវល់ធ្វើការងារៗ ជួនកាលគេប្តូរផ្លាស់ គេប្តូរកន្លែង។ អ៊ីចឹងខ្ញុំមិនសូវបានសរសេរញឹកញាប់ទេ។

**ស៖** លោកស្រី សុផានី ភាគីច្រើននៅក្នុងកំណត់ត្រារបស់អ្នកស្រីៗតែងតែមានកាលបរិច្ឆេទ។ ខ្ញុំចង់ដឹងថាតើអ្នកស្រីធ្វើយ៉ាងដូចម៉េចទើបមានកាលបរិច្ឆេទហ្នឹង? តើអ្នកស្រីមានប្រតិទិនតាមខ្លួន ឬមួយយ៉ាងដូចម្តេចដែរ?

[១៣:៥៧:៤៨]

**ឆ៖** ខ្ញុំពុំមានប្រតិទិនអីតាមខ្លួនខ្ញុំទេ ប៉ុន្តែដើមដំបូងឡើង ខ្ញុំពេលដែលខ្ញុំទៅធ្វើការ គឺថាអង្គការគេចាក់មីក្រូ។ អ៊ីចឹងដោយសារតែមីក្រូហ្នឹង ខ្ញុំស្តាប់ទៅ ខ្ញុំដឹងថ្ងៃខែ។ ដល់ពេលក្រោយមកទៀត ខ្ញុំគ្មានមីក្រូណាស្តាប់ទេ គឺថាខ្ញុំជួនកាលសួរ ឮសួរចាស់ៗនិយាយគ្នាទៅ ខ្ញុំក៏ដឹងតាមចាស់ៗហ្នឹងទៅ។ គាត់អ៊ីចឹងៗសរសេររបៀបហ្នឹង។

**ស៖** សូមអរគុណអ្នកស្រី។

**លោក យីគាំង លួ៖**

ឥឡូវនេះ ខ្ញុំសូមបង្ហាញឯកសារ<ពីរទំព័រ>បន្ត គឺខ្មែរមានលេខ 01032955 ហើយខ្មែរ ERN

បន្ទាប់គឺ 01032957 និង 958។ ចំណែកភាសាអង់គ្លេសមានលេខ 01032465 ដល់ 466, <468> និង <469>។ ភាសាបារាំងមានលេខ 01036485, 488 និង 489។ ខ្ញុំសូមអនុញ្ញាតលោកប្រធានបង្ហាញឯកសារនេះជូនទៅអ្នកស្រី សុផានី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក យីគាំង លួ៖**

**ស៖** លោកស្រីនៅទំព័រដំបូង ដែលខ្ញុំប្រគល់ជូនលោកស្រី គឺថាកាលបរិច្ឆេទនៅនេះ វាមានលក្ខណៈយ៉ាងដូចម្តេចដែរ តើវាជាកាលបរិច្ឆេទដូចដែលលោកស្រីបញ្ជាក់ដូចគ្នាគឺថា មានថ្ងៃខែឆ្នាំដូចពីមុនដែរ ឬក៏យ៉ាងដូចម្តេច?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** លើកនេះ គឺខ្ញុំយកតាមប្រតិទិនខ្មែរ គឺថាកាលដែលខ្ញុំសរសេរជារបៀប១រោច ២រោចអ៊ីចឹងហ្នឹង គឺយកតាមហ្នឹង ដោយសារតែខ្ញុំសួរចាស់ៗហ្នឹង ដូចខ្ញុំបានជម្រាបថា ខ្ញុំគ្មានវ៉ាដ្យូអីស្តាប់ទៀត -- គ្មានវិទ្យុស្តាប់ទៀតទេ គឺខ្ញុំសួរទៅ -- ឮសួរគេនិយាយទៅ ក៏ខ្ញុំកត់តាមហ្នឹងទៅ។

**ស៖** ឥឡូវនេះ យើងមើលទៅទំព័របន្ទាប់គឺមានតារាងមួយចំនួន គឺនៅទំព័របន្ទាប់មានតារាងមួយចំនួន តើលោកស្រីអាចប្រាប់បានទេថា តើតារាងហ្នឹងបង្ហាញអំពីអ្វី ហើយលេខហ្នឹងគឺលេខអ្វីមើលទៅដូចជាការគណនាគណិតវិទ្យាអ៊ីចឹង។ តើអ្នកស្រីអាចប្រាប់បានទេ ថាតើលេខនៅតារាហ្នឹងគឺជាអ្វី?

[១៤:០១:១៨]

**ឆ៖** ខ្ញុំ ពេលដែលខ្ញុំធ្វើគណនា -- ធ្វើអ៊ីចឹងៗ សរសេរលេខហ្នឹង ខ្ញុំវាអត់ដឹងថា ខែបារាំងយ៉ាងម៉េច ខែខ្មែរយ៉ាងម៉េច ប៉ុនខ្ញុំចេះតែចង់ភ្ជាប់ថា បើថ្ងៃនេះថ្ងៃបារាំង តើថ្ងៃខែហ្នឹងប៉ុន្មាន ព្រោះខ្ញុំចង់ -- ខ្ញុំវាចង់រកលេខដើម្បីដាក់ថ្ងៃខែដែលខ្ញុំកើតកូន ព្រោះខ្ញុំអត់ដឹងថាខ្ញុំកើតកូននៅថ្ងៃណា។ អ៊ីចឹងបានខ្ញុំធ្វើទៅក៏ ធ្វើយ៉ាងម៉េចក៏វាមិនចេញដែរ ព្រោះអីគ្រាន់តែខ្ញុំស្មានៗទៅ ខ្ញុំអត់ដឹងថាហ្នឹង ខ្ញុំក៏ចេះដាក់ស្មានទៅ។ ប៉ុន្តែស្មានទៅជ្រលិះគ្នាដែរ ជ្រលិះមួយអាទិត្យ ថ្ងៃក៏ត្រូវ ថាឆ្នាំវាត្រូវហើយ ប៉ុន្តែខ្ញុំដាក់ថ្ងៃខែកូនខ្ញុំដាក់ថ្ងៃ ០៧ ខែ៧ ឆ្នាំ១៩៧៧ ដល់ខ្ញុំរបបនេះដាច់ហើយ ខ្ញុំមើលទៅឃើញកូនខ្ញុំកើតថ្ងៃ១៤ ខែ៧ ឆ្នាំ១៩៧៧ គឺថា ខ្ញុំលោតបានមួយអាទិត្យៗ មុនមួយអាទិត្យថ្ងៃកំណើតកូនខ្ញុំ។

**សះ** សូមអរគុណអ្នកស្រី។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទបន្ទាប់ គឺអំពីការងារនៅក្នុងសម័យខ្មែរក្រហម។ អ្នកស្រីបានឆ្លើយទៅនឹងសំណួររបស់លោកប្រធានថា អ្នកស្រីគឺជាកសិករនៅក្នុងរបបនោះ។ តើអ្នកស្រីអាចពន្យល់បានទេថាតើអ្នកស្រីធ្វើការងារអ្វីខ្លះ? ព្រោះថាប្រើពាក្យកសិករដាំស្រូវហ្នឹង វាហាក់ដូចជាពាក្យទូទៅពេក។ តើអ្នកស្រីអាចបញ្ជាក់បានលម្អិតអំពីការងាររបស់អ្នកស្រីនៅសម័យនោះបានដែរឬទេ?

**ឆះ** ចាសបាន។ ខ្ញុំ បានជាខ្ញុំថាខ្លួនខ្ញុំជាកសិករ ពីព្រោះខ្ញុំពេលខែប្រាំងខ្ញុំរែកដី។ រែកដី ធ្វើថ្នល់ ជីកទំនប់ ជីកប្រឡាយ ជីកត្រពាំង ដែលត្រពាំងធំសព្វថ្ងៃនៅស្រុកត្រាំកក់ហ្នឹង គឺខ្ញុំក៏ចូលរួមបានជីកត្រពាំងហ្នឹងដែរ។ ហើយខ្ញុំធ្វើផ្លូវពីអង្គរកាមកអង្គ ពីអង្គតាសោមមកអង្គរកា។ ហើយខ្ញុំបានចូលធ្វើ គេហៅថា "ស្រែគំរូ"ៗ ហើយខ្ញុំបានចូលរួមធ្វើស្រែ ស្ទូង ដក ច្រូតកាត់ ដូចគេដូចឯងដែរ ហើយនិងបានធ្វើ ជួនកាលខ្ញុំបានធ្វើកប្បាសៗ ផ្ដេចកប្បាស ផ្ដេចអីហ្នឹង ហើយជួនកាលខ្ញុំ ពេលដែលខ្ញុំទម្ងន់ ខ្ញុំបានមើលគោ អ៊ីចឹងខ្ញុំមើលគោ ប៉ុន្តែខ្ញុំមើលគោ ខ្ញុំរវល់តែមើលមាត់វាស៊ីស្មៅ ហត់ណាស់ មើលគោ។ ចាសមើលគោពេលដែលខ្ញុំទម្ងន់។ អរគុណ។

**សះ** សូមអរគុណអ្នកស្រី។ អ៊ីចឹងអ្នកស្រីមិនមែនធ្វើការងារត្រឹមជាកសិករទេ អ៊ីចឹងមែនទេ?

**ឆះ** ចាស ពេលជួនខ្លះខ្ញុំក៏រែកជី។ ជីហ្នឹងមានជីលាមកគោ និងលាមកមនុស្សដែរ ជួនកាល។ ពេលណា ពេលរែកដីដំបូកដាក់ស្រែពេលណារដូវប្រាំង។

[១៤:០៤:៥២]

**សះ** សូមអរគុណអ្នកស្រី។ អ៊ីចឹងអ្នកស្រីធ្វើការងារច្រើន។ អ៊ីចឹង តើអ្នកស្រីអាចជ្រើសរើសការងារតាមដែលអ្នកស្រីចង់ធ្វើដែរឬទេ?

**ឆះ** ខ្ញុំមិនអាចរើសការងារបានទេ ពីព្រោះសុទ្ធតែអង្គការតម្រូវ។

**សះ** តើអ្នកស្រីអាចប្រាប់បានទេថា អ្នកស្រីធ្វើការប៉ុន្មានម៉ោងក្នុងមួយថ្ងៃ បានន័យថាពីមួយពេលទៅមួយពេលហ្នឹង?

**ឆះ** ខ្ញុំជម្រាបថា នៅសម័យប៉ុលពត គឺមានរដូវ។ កាលណារដូវច្រូតកាត់ គឺខ្ញុំធ្វើការសឹងតែមួយថ្ងៃ --មួយយប់ទាល់ភ្លឺ ប៉ុន្តែគ្រាន់តែថា ពេលណាយើងហូបបាយក៏ហូបទៅ ជួនកាលយើងលួចសម្រាកអី ដូចថាគេងលក់នៅលើគំនរចំបើងហ្នឹង គឺថាគេសឹងធ្វើទាល់ភ្លឺ ព្រោះអីគេធ្វើដាក់ -- គេធ្វើអា --អ្នកណាមានកម្លាំងធ្វើទៅ អ្នកណាលក់ក៏លក់ទៅ គឺថាសឹងតែទាល់ភ្លឺ។ តែបើសិនជា នៅរដូវប្រាំង

វិញ គឺយើងមានពេល មានម៉ោង ដូចថាម៉ោងពីព្រលឹមអ៊ីចឹង យើងរែកស្រូវ រែកអាចម៍គោ ឬក៏រែកដីដំបូកអីដាក់ស្រែបានសម្រាកបន្តិច ហើយចូលចុះទៅទៀត។ ហើយបើយប់ឡើង យើងធ្វើជីកប្រឡាយ ជីកត្រពាំង។ អ៊ីចឹងជួនកាលដល់ម៉ោងដប់យប់ៗ។

**ស៖** សូមអរគុណអ្នកស្រី។ ក្នុងរយៈពេលនោះ តើអ្នកស្រីធ្វើយ៉ាងណាបានដឹងថាវាម៉ោង ដប់យប់<?> អ្នកស្រីមាននាឡិកាពាក់ដែរឬទេ?

**ឆ៖** ខ្ញុំគ្មាននាឡិកាទេ ប៉ុន្តែបើសិនជាពេលណាដែលធ្វើជីកស្រះ ជីកត្រពាំង ជីក លើកត្រពាំង ជីកត្រពាំងហ្នឹង គឺមានមីក្រូៗគេបញ្ជាក់ដូចថា ម៉ោងប៉ុណ្ណេះៗទៅ។ អ៊ីចឹងខ្ញុំដឹងតាមមីក្រូហ្នឹង។

[១៤:០៧:២៨]

**ស៖** សូមអរគុណលោកស្រី។ នៅពេលគេឲ្យលោកស្រីធ្វើការ តើគេអនុញ្ញាតឲ្យលោកស្រីឈប់ ឬក៏គេអនុញ្ញាតឲ្យលោកស្រីមិនទៅធ្វើការបានដែរទេ?

**ឆ៖** ចាសគ្មានទេ ទាល់តែយើង ទាល់តែមានការអនុញ្ញាតពីអង្គការ ទាល់តែសុំការអនុញ្ញាត។ យើងអត់អាចឈប់ដោយសេរីស្រេចតែចិត្តយើងទេ។

**ស៖** បាទ សូមអរគុណ។

**លោក យីគាំង លូ៖**

លោកប្រធាន ខ្ញុំសូមបង្ហាញនូវទំព័រមួយ <នៃសៀវភៅ "កាលណាយើងជួបគ្នា">ជូនទៅដល់សាក្សី គឺ ERN ខ្មែរ 00562903, អង់គ្លេស <01037343>, និងភាសាបារាំង <01037351>។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក យីគាំង លូ៖**

**ស៖** លោកស្រី ក្រោយពីលោកស្រីមើលទៅឯកសារនេះរួចហើយ តើនៅក្នុងប្រអប់ពណ៌លឿង តើលោកស្រីអាចបញ្ជាក់បានទេ តើវាចង់មានន័យថាយ៉ាងម៉េចដែរ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ទាំងអស់មានពីរប្រអប់។ អ៊ីចឹងខ្ញុំសូមសួរលោកមេធាវីថា ឲ្យខ្ញុំមើលប្រអប់លើ ឬក៏ប្រអប់ក្រោម?

**ស៖** បាទ សូមឲ្យលោកស្រីប្រាប់ប្រអប់នៅខាងក្រោមនេះ តើប្រអប់នៅខាងក្រោមហ្នឹងចង់

មានន័យថាយ៉ាងដូចម្ដេច?

**ឆ៖** ប្រអប់នៅខាងក្រោមនេះ គឺជាបទចម្រៀងដែលខ្ញុំតែង ទំនុកច្រៀង និងទំនុកភ្លេងដោយខ្លួនខ្ញុំ។ មានចំណងជើងថា "ទារុណអមនុស្សធម៌"។ ប៉ុន្តែពេលនេះ គឺលោកមេធាវីអនុញ្ញាតឲ្យខ្ញុំអានមិនឲ្យខ្ញុំច្រៀងទេ។

[១៤:១០:០១]

អ៊ីចឹង ខ្ញុំសូមអាន៖ "ចេញ ចេញ ចេញ ភ្នំពេញអើយ ខ្ញុំលាអ្នកហើយ ទុក្ខគ្មានស្បើយនៅក្នុងឱរ៉ា ខ្ញុំដឹងថា យើងគ្មានសេរី តាំងពីចេញបានមួយថ្ងៃម៉្លេះ។ ទី២ "ទប់ ទប់ ទប់ លើកទំនប់ និងជីកប្រឡាយ សែនខ្វល់ខ្វាយ ហ្នឹងហើយចំណេះ មហាវិទ្យាល័យនេះ រៀនកាប់រៀនរែក ចាំបាច់អ្វីរៀនក្នុងសាលា។ (បន្ទោ) ខ្ញុំឈរលើស្រែគំរូ ឲ្យអារម្មណ៍ធូរពីទុក្ខសោកា ផ្ទុយទៅវិញ ខ្ញុំសែនខ្លោចផ្សា ព្រោះព្រាត់មាតាបិតា និងញាតិការផងទាំងឡាយ"។ ទី៣ "ស្នេ៍ ស្នេ៍ ស្នេ៍ សហករណ៍ផ្ញើប្រុងចិត្តប្រុងកាយ បើបាត់ខ្លួន កុំបីឆ្ងល់ឆ្ងាយ មុខជាអន្តរាយ កាយសូន្យសង្ខារ។ ឱ! អនិច្ចាវាសនាខ្មែរអើយ!"។

ទំនុកច្រៀងនេះ ខ្ញុំចង់បើកស្រាយថាពេលដែលខ្ញុំចេញពីភ្នំពេញ។ បានជាខ្ញុំថា "លាហើយភ្នំពេញ ទុក្ខគ្មានស្បើយហ្នឹង" ពីព្រោះខ្ញុំគ្រាន់តែចេញផុតពីផ្លូវ ពីផ្លូវផ្ទះខ្ញុំមក ចូលមកដល់ផ្លូវមុនីវង្ស ខ្ញុំឃើញសាកសព ហើយខ្ញុំឃើញប្រជាជនរែកអីវ៉ាន់ទៅតាមទិសដែលអង្គការចង្អុលឲ្យ គឺគ្មានយើង អត់អាចបកក្រោយបានទេ បើថាទៅផ្លូវជាតិលេខ១ គឺយើងទៅផ្លូវជាតិលេខ១។ បើគេបិទផ្លូវជាតិលេខ១ គេឲ្យទៅផ្លូវជាតិលេខ២ យើងត្រូវតែទៅផ្លូវជាតិលេខ២ យើងមិនអាចទៅផ្លូវជាតិលេខ១បាន។ អ៊ីចឹង ខ្ញុំគិតថា ដូចជាអត់មានសេរីភាពតាំងពីថ្ងៃចេញដំបូង។ ដែលខ្ញុំថា "ទប់ ទប់ ទប់ លើកទំនប់ និងជីកប្រឡាយនេះ សែនខ្វល់ខ្វាយ" ពីព្រោះពេលនោះគ្មានសាលារៀនទេ។

[១៤:១២:០៥]

**ស៖** លោកស្រី បាទសូមអរគុណចំពោះការបកស្រាយ។ ពេលដែលបកស្រាយអ៊ីចេះ ខ្ញុំដឹងថា លោកស្រីមានវិរិយភាពនៅក្នុងខ្លួនហើយ។ ខ្ញុំសូមបន្តសួរតទៅទៀត ហើយសូមឲ្យលោកស្រីឆ្លើយចំៗសំណួរខ្ញុំ។ <កាលដែលលោកស្រីធ្វើនេះ គឺវាល្អណាស់ ក៏ប៉ុន្តែវាច្រើនពេកគ្រាន់តែឆ្លើយនឹងសំណួរតែមួយនោះ ហើយអ្នកបកប្រែក៏ប្រហែលមិនអាចចាប់បានដែរ។> ឥឡូវ<លោកស្រី>ប្រហែលជា<បាន>បកស្រាយ <>សំណួរដំបូង<ខ្ញុំរួចហើយ>។ លោកស្រីបានអានហើយនូវទំនុកច្រៀងនេះ។ ខ្ញុំសូមសួរថា តើលោកស្រីបាននិពន្ធទំនុកច្រៀងនេះនៅពេលណាដែរ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** ខ្ញុំនិពន្ធទំនុកច្រៀងនេះ ក្នុងឆ្នាំ១៩៧៥។

**ស៖** សូមលោកស្រីអាចជួយបញ្ជាក់បានទេ គឺក្នុងឆ្នាំ៧៥ហ្នឹងមានអាចចាំថ្ងៃ ចាំខែអីទេ អាចដើមឆ្នាំ៧៥ ឬក៏ចុងឆ្នាំ៧៥ ជាដើម?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាល់ឆ្លើយតប! ក្បាល--

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ខ្ញុំមិនអាចឆ្នាំខែថ្ងៃ ដែលខ្ញុំនេះទេ ប៉ុន្តែគ្រាន់តែខ្ញុំចាំថា ខ្ញុំតែងនៅចុងឆ្នាំ១៩៧៥។

**សួរដោយលោក យីគាំង លួ៖**

**ស៖** អ៊ីចឹង អាចនិយាយបានថា លោកស្រីនិពន្ធនៅក្នុងអំឡុងរបបខ្មែរក្រហម។ តើត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** មុនពេលដែលខ្ញុំបញ្ឈប់លោកស្រី លោកស្រីបានពន្យល់មូលហេតុ<លោកស្រីនិពន្ធ>បទចម្រៀងនេះ។ សុំឱ្យលោកស្រីពន្យល់សង្ខេបបានហើយ ថាហេតុអ្វីបានជាលោកស្រីនឹកឃើញ ហើយសរសេរ និពន្ធនូវបទចម្រៀងនេះឡើង? <ខ្ញុំគិតថា ការបកប្រែដែលខ្ញុំទើបតែបានឮ> គឺថាបើសិនណាជាមានអ្នកណាម្នាក់បាត់ខ្លួន <> គឺមានន័យថា បាត់សង្ខារហើយ។ <ខ្ញុំចង់ឱ្យមានកំណត់ត្រា ការបកប្រែផ្លូវការរបស់តុលាការគឺ "មិនចាំបាច់ឆ្ងល់ទេ បើសិនអ្នកណាម្នាក់បាត់ខ្លួន គឺមានគ្រោះថ្នាក់អ្វីមួយកើតឡើងចំពោះខ្លួនគេ និងជីវិតគេហើយ។> អ៊ីចឹងមែនទេ?

**ឆ៖** ចាស ប្រាកដហើយ។

[១៤:១៤:៤៨]

**ស៖** សូមឱ្យលោកស្រីជួយពន្យល់បន្តិចមក ហេតុអ្វីក៏បានឃ្លាមួយលោកស្រីសរសេរថា "កាលណាបាត់ខ្លួន គឺបាត់បង់អាយុជីវិតហើយ បាត់បង់សូន្យសង្ខារហើយ"។ ហេតុអីលោកស្រីនឹកឃើញសរសេររឿងហ្នឹង?

**ឆ៖** បានជាខ្ញុំសរសេររឿងហ្នឹង ពីព្រោះខ្ញុំទៅដល់ភ្លាមបានប្រាំបួនថ្ងៃ ខ្ញុំឃើញបងស្រីថ្លៃខ្ញុំយំ។ ហើយខ្ញុំឃើញម្ដាយក្មេកខ្ញុំប្រាប់ថា "កុំយំៗប្រយ័ត្នគេយកទៅ"។ ពេលគាត់យំហ្នឹង ដូចថាគាត់មិនបាននិយាយប្រាប់ខ្ញុំផ្ទាល់ទេ ប៉ុន្តែខ្ញុំឮអ្នក -- ដូចថាសាច់ញាតិអីប្ដីខ្ញុំហ្នឹងថា "គេយកបងថ្លៃខ្ញុំទៅហើយ"

។ ហើយដល់ពេលចុងរហូត -- ទៅចុះៗខ្ញុំទៅដល់ដំបូងនោះ ទៅដល់គេយកទៅដំបូង ដល់ពេលខ្ញុំតែងបទភ្លេងហ្នឹងជិតៗចប់ ជិតចុង៧៥ អត់ឃើញត្រឡប់មកវិញៗ ហើយខ្ញុំដឹង ខ្ញុំឮសួរគេថាតែទៅហើយបាត់ហើយ អត់ -- ហើយមិនមែនមានតែគាត់មួយទេ មានស្រ្តីៗមួយគំនរទៀត ដែលមានប្តីជានាយទាហាន ជាគ្រូបង្រៀនជាអី គេយកទៅបាត់អ៊ីចឹងហើយ ហើយគេប្រមូលផ្តុំនារីៗអស់ហ្នឹង គេដាក់ថា "កងមេម៉ាយ"។ ខ្ញុំគ្រាន់តែឮថាពាក្យ "កងមេម៉ាយ" គឺបានន័យថាប្តី -- អត់ប្តីហើយ មេម៉ាយហ្នឹង។ គេដាក់ឈ្មោះ "កងមេម៉ាយ" អ៊ីចឹងហ្នង។ អ៊ីចឹងបានខ្ញុំៗសន្មតថា ទៅហើយអត់ត្រឡប់មកវិញទេ។

**ស៖** សូមអរគុណលោកស្រីៗ បានពន្យល់លម្អិតហើយចំណុចនេះ។ ខ្ញុំសូមបង្ហាញទំព័រមួយទៀតនៃសៀវភៅរបស់លោកស្រី <"កាលណាយើងជួបគ្នា">។ ខ្ញុំសូមអានសម្រង់នេះជូនលោកស្រី ERN ជាភាសាខ្មែរ 00562885 ដល់ 2886, អង់គ្លេស <01037341>, បារាំង 01037349។

**លោក យីគាំង លូ៖**

លោកប្រធានខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញទំព័រនេះជូនសាក្សីតាមរយៈអេក្រង់កុំព្យូទ័រ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៤:១៧:៥០]

**សួរដោយលោក យីគាំង លូ៖**

**ស៖** លោកស្រី សូមលោកស្រីពិនិត្យមើលទំព័រនេះ ហើយនិងពិនិត្យមើលនៅក្នុងប្រអប់ពណ៌លឿងហ្នឹង តើលោកស្រីសរសេរអំពីអ្វីដែរក្នុងប្រអប់ហ្នឹង?

**ឆ៖** ចាសនៅក្នុងប្រអប់នេះខ្ញុំសរសេរថា៖ "តើមិត្តទាំងអស់គ្នាប៉ានលើកដៃតាមសេចក្តីសម្រេចរបស់បក្សទេ? ដែលមានគោលការណ៍ដូចតទៅ៖ ជនណាមិនសកម្មការងារ សេចក្តីសម្រេចអនុម័តថាទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។

**ស៖** លោកស្រី សុផានី អ្នកណាជាអ្នកនឹកឃើញយកពាក្យនេះយកមកសរសេរនេះ?

**ឆ៖** ទេ មិនមានអ្នកណានឹកឃើញយកពាក្យមកសរសេរទេ បើសិនជាអង្គការមិននិយាយដូច្នោះខ្ញុំមានពាក្យអីនឹងនិយាយថា "ទុកក៏មិនចំណេញ ដកចេញមិនខាត"។ គឺអង្គការគេបានប្រជុំថាដូច្នេះ។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែវាមិនច្បាស់។ តើត្រឹមត្រូវទេដែលខ្ញុំអាចនិយាយថាអង្គការជាអ្នកនិយាយឃ្លានេះឡើង តើអ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** ពិតប្រាកដហើយចាស។

**ស៖** សូមអរគុណលោកស្រី តើលោកស្រីធ្វើយ៉ាងម៉េចដែរ ក្រោយពេលលោកស្រីឮសួរអង្គការនិយាយពាក្យហ្នឹងចេញមកនេះ?

**ប្រធានអង្គជំនុំ៖**

លោកស្រី សុផានី កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញ លោកវិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំហាក់បីដូចជាមានភាពច្របូកច្របល់បន្តិច។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី អានសម្រង់ចេញពីសៀវភៅ។ ខ្ញុំមិនដឹងថាតើអ្វីៗដែលសរសេរនៅក្នុងសៀវភៅហ្នឹង គឺជា<កំណត់ហេតុផ្ទាល់ខ្លួន> គឺថាមានគេនិពន្ធ ឬក៏មានគេលើកឃ្លាប្រយោគនេះហើយ មិនមែនជាការធ្វើជារឿងនិទាន ឬក៏ប្រឌិតអីនោះទេ។ ធម្មតាគេយកកំណត់ត្រាហ្នឹងយកមក ហើយសាកសួរ ក៏ប៉ុន្តែនៅពេលនេះគឺថា<សួរឱ្យដើមបណ្ដឹងរដ្ឋប្បវេណីអានសម្រង់ពី>សៀវភៅបែបប្រលោមលោកឬក៏យ៉ាងម៉េចនោះទេ ខ្ញុំ<>មិនដឹង<ច្បាស់>។ <ប៉ុន្តែចម្លើយ គឺថាចូលទៅដល់ព្រឹត្តិការណ៍ជាក់ស្ដែង> តើលោកកំពុងតែសួរ<>ឃ្លានៅក្នុងរឿងប្រលោមលោកមួយ ឬក៏រឿងនៅក្នុង<កំណត់ហេតុ>ជីវិតមួយជាសាមញ្ញធម្មតានោះ? ខ្ញុំមិនជំទាស់ទេ ខ្ញុំគ្រាន់តែសុំឱ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ខ្ញុំចំណុចនេះ។

**លោក យីគាំង លូ៖**

លោក លោកស្រីចៅក្រម ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំមុន ដើម្បីបង្កើតឱ្យឃើញនូវទំនាក់ទំនងរវាងសៀវភៅនេះ ហើយនិងកំណត់ដែកំណត់ត្រារបស់គាត់។ <> បើសិនណាជាមេធាវី<ការពារក្ដី>មិនច្បាស់ <នៅក្នុងពេលគាត់ត្រូវសួរសំណួរ គាត់>អាចសួរទៅលោកស្រី សុផានី ផ្ទាល់តែម្ដង <ហើយសុំឱ្យគាត់ពន្យល់បន្ថែមទៀត>។ បើសិនណាជាអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំសូមបន្តការតាំងសំណួរតទៅទៀតលោកប្រធាន។

**សួរដោយលោក យីគាំង លូ៖**

**ស៖** សូមអរគុណលោកស្រី។ សំណួររបស់ខ្ញុំគឺដូច្នេះ តើលោកស្រីចាំទេ លោកស្រីបានធ្វើអ្វីក្រោយលោកស្រីបានឮពាក្យហ្នឹងចេញពីអង្គការមក។ ពាក្យ“ទុកក៏មិនចំណេញ ដកចេញក៏មិនខាតនេះ”?

[១៤:២២:០៥]

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** ពេលដែលខ្ញុំបានឮកិច្ចប្រជុំរបស់អង្គការនិយាយថា "ទុកក៏មិនចំណេញ ដកចេញមិនខាត" ពេលនោះខ្ញុំក៏លើកដៃ លើកដៃឡើងដើម្បីមានយោបល់ ព្រោះអីធម្មតាយើងសុំការអនុញ្ញាតដើម្បីឆ្លើយ ព្រោះអីពេលហ្នឹងគេអនុញ្ញាតឲ្យយើងឆ្លើយហើយ ឲ្យយើងសួរឬក៏ឆ្លើយហើយនឹងៗពាក្យគេ ឲ្យយើងមានមតិ។ ខ្ញុំភ័យ ពីព្រោះខ្ញុំមានគេហៅថាសុខភាពមិនសូវល្អ ខ្ញុំវារៀងខ្សោយ ខ្ញុំមានឈឺច្រើន។ អ៊ីចឹងខ្ញុំក៏ឡើងថ្លែងថា "ខ្ញុំសព្វថ្ងៃនេះធ្វើការងារជូនអង្គការអត់មានលាក់កម្លាំងទេ ប៉ុន្តែខ្ញុំសូមធ្វើទៅតាមកម្លាំងរបស់ខ្ញុំ ខ្ញុំមិនអាចធ្វើឲ្យហំហាក់ ដូចថាមាំទាំដូចគេទេ"។ ឧទាហរណ៍ជាក់ស្តែងនៅពេលដែលខ្ញុំផ្លាស់ទៅធ្វើចម្ការនៅ១៦០ ខ្ញុំបានបានឃើញស្ត្រីចាស់ម្នាក់ គាត់មានរោគរាករូស ហើយគាត់ដើរទៅធ្វើការអត់បានទេ។ គាត់មានរោគរាករូសហ្នឹង គឺថាបត់ជើងបត់ដៃនៅហ្នឹងកន្លែង។ ហើយពេលហ្នឹងអត់មាននរណាហ៊ានទៅៗជិតស្រីនោះ -- ហ៊ានទៅកើបលាមកស្រីនោះ ហ៊ានទៅគក់សំពត់ស្រីនោះទេ។ ប៉ុន ខ្ញុំថាកិច្ចការនេះវាស្រាល ទោះបីជាគួរឲ្យខ្ពើមរអើមក្តី ក៏ខ្ញុំហ៊ានធ្វើ។ អ៊ីចឹង ខ្ញុំបានលើកនៅក្នុងអង្គប្រជុំថាពេលនោះមិនមែនថាអង្គប្រជុំហ្នឹងមិនឃើញខ្ញុំទេ គឺទាំងអស់គ្នាគឺបានទៅធ្វើការជាមួយខ្ញុំ បានឃើញសកម្មភាពខ្ញុំបោកសំពត់ស្ត្រីដែលប្រឡាក់លាមក ហើយបានកើបដាក់ផេះដាក់អី កុំកន្លែងហ្នឹងធុំក្លិន។ ទាំងអស់គ្នាបានឃើញខ្ញុំធ្វើអ៊ីចឹងមែន ដែលគ្មានអ្នកណាមួយហ៊ានទៅធ្វើកន្លែងគគ្រិច ឆ្អេះឆ្អាបហ្នឹង។ តែខ្ញុំ កម្លាំងខ្ញុំធ្វើបានខ្ញុំធ្វើ។ អាកន្លែងបើរែកដីបង្គីធំៗ ខ្ញុំធ្វើតែមួយថ្ងៃ ខ្ញុំត្រូវឈប់ធ្វើហើយ ព្រោះអីខ្ញុំអត់សូវមានកម្លាំងធ្វើអាហ្នឹង ព្រោះអីខ្ញុំកើតរោគហឺត។ អ៊ីចឹងបានខ្ញុំឡើងការពារ ដើម្បីខ្ញុំការពារសុវត្ថិភាពខ្លួនដែរ ព្រោះខ្ញុំខ្លាចអង្គការគេចោទប្រកាន់ថាខ្ញុំខ្ជិលច្រអូស គេយកខ្ញុំទៅសម្លាប់។ អានេះការពារដែលសុវត្ថិភាពផ្ទាល់ខ្លួន បានជាខ្ញុំហ៊ានឆ្លើយអ៊ីចឹង។

[១៤:២៤:២៩]

**ស៖** សូមអរគុណលោកស្រី សុផានី។ លោកស្រីខ្ញុំស្នើថាឲ្យឆ្លើយខ្លីៗបានហើយដោយសារតែពេលវេលា។ តែការឆ្លើយលម្អិតបែបនេះ ខ្ញុំសូមថ្លែងអំណរគុណច្រើនណាស់ ហើយខ្ញុំសូមបន្តសួរតទៅមុខទៀត។ ខ្ញុំសូមបង្ហាញជូនលោកស្រីនូវទំព័រមួយនៃកំណត់ត្រារបស់លោកស្រី ERN ជាភាសាខ្មែរ 01032955, ERN អង់គ្លេស 01036466, បារាំង 0036485*(ស៊ីក)*។

**លោក យីគាំង លួ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញជូនដើមបណ្តឹងរដ្ឋប្បវេណី <និងបង្ហាញនៅលើអេក្រង់>។ តើលោកប្រធានអនុញ្ញាតឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក យីគាំង លួ៖**

**ស៖** លោកស្រី សុផានី នៅត្រង់ទំព័រនេះក៏មានប្រអប់ ហើយខ្ញុំស្រង់តែមួយឃ្លាទេ ខ្ញុំគូសព័ទ្ធជុំវិញតែមួយឃ្លាទេ។ តើកាលបរិច្ឆេទហ្នឹងគឺថ្ងៃខែឆ្នាំណាដែរ? ហើយនៅក្នុងប្រអប់ពណ៌លឿងនេះដែលខ្ញុំគូសតែមួយបន្ទាត់ តើលោកស្រីចង់សរសេរអំពីអ្វី?

**លោក អ៊ុំ សុផានី៖**

**ឆ៖** នៅក្នុងប្រអប់នេះ ខ្ញុំសរសេរថា "ឯ ស៊ូ ណន រែកដីជាមួយអ្នកទោសបីនាក់"។

**ស៖** លោកស្រី តើប្ដីលោកស្រី គាត់ឈ្មោះ ស៊ូ ណន។ តើ ស៊ូ ណន មួយនេះក៏ជាប្ដីលោកស្រីដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ជាស្វាមីរបស់ខ្ញុំ។

**ស៖** លោកស្រីដឹងទេថា ហេតុអ្វីបានគេបញ្ជូនស្វាមីលោកស្រីឲ្យទៅធ្វើការជាមួយអ្នកទោសបីនាក់ទៀតនោះ?

**ឆ៖** ពីព្រោះគេចោទប្រកាន់ប្ដីខ្ញុំ។ ពេលដែលមុននឹងមកដល់ គេសួរថា៖ "ដើរនិងជិះកង់មួយណាស្រួលជាង?" ប្ដីខ្ញុំថា៖ "ម៉េចស្រួលដូចកង់ កង់លឿនជាង"។ គេសួរទៀតថា៖ "កង់និងម៉ូតូណាស្រួលជាង?" ប្ដីខ្ញុំថា៖ "ម៉ូតូស្រួលជាង"។ គេសួរទៀតថា៖ "ចុះម៉ូតូនិងឡាន?" គាត់ថា៖ "ឡានវាត្រជាក់ វាស្រួល វាលឿន យើងអាក់បាន"។ បានជាគេសួរ -- បានជាគេឮប្ដីខ្ញុំអ៊ីចឹង ក៏គេហៅគាត់ឡើងឡាំប្រឹតាមកឃុំនៅត្រពាំងធំ។ រឿងនេះ ខ្ញុំបានសួរគាត់ពេលចាស់ៗនេះហើយ ប៉ុន្តែគាត់មិនដែលនិយាយសោះ។ ខ្ញុំសួរគាត់ពីយូរហើយ គាត់បានផ្ដុំបានពាក្យប៉ុណ្ណឹងប្រាប់ខ្ញុំ។ អរគុណ។

**ស៖** សូមអរគុណច្រើនលោកស្រី ហើយខ្ញុំក៏ស្នើសុំឲ្យលោកស្រីជួយបញ្ជាក់កាលបរិច្ឆេទពេលវេលានៃការសរសេរកំណត់ត្រានេះផងដែរ។ លោកស្រីអាចមើលឃើញទេអក្សរនេះ អាចមើលឃើញកាលបរិច្ឆេទបញ្ជាក់ជូនអង្គជំនុំជម្រះផងបានទេ?

**ឆ៖** ចាស បាន គឺថ្ងៃ១២ រោច។

[១៤:២៨:៤៥]

**ស៖** សូមអរគុណលោកស្រី។ នៅក្នុងសក្ខីកម្មរបស់លោកស្រីមុនៗ លោកស្រីបាននិយាយថា

សាច់ញាតិខ្លះរបស់លោកស្រីបានបាត់ខ្លួន។ តើសាច់ញាតិដែលបានបាត់ខ្លួនទាំងនោះ ជាអ្នកណាខ្លះដែរ លោកស្រីអាចជម្រាបជូនតុលាការបានទេ?

**ឆ៖** ចាស បាន។ ខ្ញុំបានបែកពីឪពុកម្ដាយនៅឆ្នាំ១៩៧៥។ ខ្ញុំទៅស្រុកត្រាំកក់ហ្នឹងជាមួយបងស្រី និងប្អូន។ ពេលខ្ញុំទៅដល់ ខ្ញុំឃើញសាច់ញាតិខាងប្ដីខ្ញុំ គឺថាគេយកបងថ្លៃខ្ញុំ ដែលពាក់ស័ក្ដិ៤កន្លះ ដែលជាអ្នកបើកបរយន្តហោះទៅបាត់។ ប៉ុន្តែខ្ញុំអត់បានឃើញគេមកនាំទៅទេ ប៉ុនគ្រាន់ខ្ញុំដឹងថា ទៅហើយអត់ឃើញ។ ហើយបងថ្លៃទី៦ ក៏បាត់ខ្លួនអត់ឃើញ។ បងថ្លៃទី៥ ឈ្មោះ ស៊ូ ណែម ហៅ ស៊ូ សូត្រ ជាវេជ្ជបណ្ឌិតបានគេ ត្រូវគេសម្លាប់នៅគុកទួលស្លែង បោះពុម្ពដោយក្រសួងឃោសនាការ និងវប្បធម៌ ទំព័រទី៣៧។

**ស៖** សូមអរគុណលោកស្រី សុផានី។ ខ្ញុំដឹងថាធ្វើឲ្យលោកស្រីមានការពិបាកចិត្តក្នុងការរំឭករឿងរ៉ាវនេះឡើង។ ខ្ញុំសុំបង្ហាញទំព័រមួយទៀតនៃសៀវភៅរបស់លោកស្រីគឺ <1>48 ដែលថា សរសេរថា “យើងមិនបានជួបគ្នាម្ដងទៀតទេ”។ ERN ជាភាសាអង់គ្លេស 00562887 – នេះជាERN ជាភាសាខ្មែរទេ 00562887, ERN អង់គ្លេស 01037342, បារាំង 01037350។

**លោក យីគាំង លូ៖**

លោកប្រធានខ្ញុំសុំធ្វើការអនុញ្ញាតដើម្បី<ដាក់>ឯកសារជូនសាក្សីម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក យីគាំង លូ៖**

**ស៖** លោកស្រី សុផានី ក្រោយពីលោកស្រីឃើញអត្ថបទនេះ ត្រង់ទំព័រនេះ។ តើលោកស្រីអាចជម្រាបជូនតុលាការបានផងទេថា តើលោកស្រីសរសេរអំពីអ្វីដែរនៅក្នុងប្រអប់នេះ?

[១៤:៣១:៤៦]

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** នៅក្នុងប្រអប់នេះខ្ញុំសរសេរថា៖ “និយាយហើយក្នុងខ្លួនខ្ញុំដូចជាពុំនឹកភ័យអ្វីទេ ពីព្រោះខ្ញុំនិយាយមានហេតុផលច្បាស់លាស់ ប៉ុន្តែ អ៊ី កាក់ គាត់ត្រូវជាប្អូនថ្លៃម្ដាយក្មេកខ្ញុំផង ត្រូវជាជន្លងម្ដាយក្មេកខ្ញុំផង បានលួចមកប្រដៅខ្ញុំស្ងាត់ៗថា ផានី អើយ! កុំហ៊ានខ្លាំងពេក ប្រយ័ត្នណា”។

**ស៖** តើមានអ្វីកើតឡើងនៅពេលសាច់ថ្លៃរបស់លោកស្រីម្នាក់មកប្រាប់លោកស្រីថា “កុំហ៊ាន

ខ្លាំងពេកប្រយ័ត្ន!" ហើយតើវាមានអ្វីកើតឡើងទៀតក្រោយពីប្រាប់ហើយនុ៎ង? <ហើយលោកស្រីបាននិយាយថា លោកស្រីលែងខ្លាចទៀតហើយ។ តើត្រឹមត្រូវដែរឬទេ?>

**ឆ៖** ក្រោយពីគាត់ប្រាប់ខ្ញុំហើយ ខ្ញុំគិតថាលែងគិតហើយ ងាប់អីងាប់ទៅ ដូចស្លាប់ស្រួលជាងព្រោះអីវាអត់សិទ្ធិសេរីភាព វាអត់មានដូចថាសប្បាយក្នុងចិត្តសោះ អាហារហូបក៏មិនគ្រប់គ្រាន់។ អ៊ីចឹងខ្ញុំគ្រាន់តែថា -- គាត់ថាប្រយ័ត្នហ្នឹង គឺថាប្រយ័ត្នស្លាប់ហ្នឹងឯង។

**ស៖** សូមអរគុណច្រើនលោកស្រី សុផានី។ ខ្ញុំសុំបន្តជូន ចូលទៅទំព័របន្តបន្ទាប់ទៀតដើម្បីសួរទៅមុខទៀត។ លោកស្រីបាននិយាយ -- ខ្ញុំចង់ថាអ៊ីចេះ ថាតើលោកស្រីធ្វើការអ្វីដែរមុនចាកចេញពីទីក្រុងភ្នំពេញឆ្នាំ១៩៧៥ នោះ?

**ឆ៖** មុនចាកចេញពីភ្នំពេញឆ្នាំ១៩៧៥ ខ្ញុំជានិស្សិតនៅមហាវិទ្យាល័យបុរាណវិទ្យា ឆ្នាំទី៤។

**ស៖** នៅក្នុងចម្លើយរបស់លើកមុន លោកស្រីបានសរសេរថា លោកស្រីមានសុខភាពមិនល្អ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស មែន។

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្រីនៅឯត្រាំកក់នោះ ហើយមានសុខភាពមិនល្អអ៊ីចឹងតើលោកស្រីបានទៅមន្ទីរពេទ្យណាមួយទេ?

**ឆ៖** ពេលដែលខ្ញុំនៅត្រាំកក់ ដែលខ្ញុំមានសុខភាពមិនសូវល្អ ខ្ញុំអត់មានទៅមន្ទីរពេទ្យណាទេប៉ុន្តែខ្ញុំទៅសុំថ្នាំ បានទៅសុំថ្នាំ។

**ស៖** សុំអរគុណច្រើនលោកស្រី។ លោកស្រី ខ្ញុំសុំបង្ហាញជូនលោកស្រីនៅទំព័រមួយទៀត <ដែលនិយាយអំពីការដែលលោកស្រីសម្រាលកូន>។

ហើយសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញមួយទំព័រទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:៣៥:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរបែបនេះ។ អង្គជំនុំជម្រះបានដាក់សម្រង់នេះចូលទៅក្នុងសំណុំរឿង គឺជា<សម្រង់>នៃសំណោររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ យើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនដឹងទេថាតើការជ្រើសរើសកថាខណ្ឌនានាទាំងឡាយយកមកសួរនេះ<ដើម្បីអ្វីទេ។> យើងសូមឱ្យដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់ជាភាសាអង់គ្លេស ដោយមានការបកប្រែទាំងស្រុងតែម្តង ដើម្បីឱ្យយើងខ្ញុំបានយល់ ថាតើដើម<>បណ្តឹងរដ្ឋប្បវេណីរូបនេះគាត់បានសរសេរអំពីអ្វី ប៉ុន្តែមានការបដិសេធ។ ឥឡូវនេះ គឺថាយើងឃើញថាមានការជ្រើសរើសកថាខណ្ឌមួយចំនួន ដែលអាចចាត់ទុកថាជារឿងប្រលោមលោក<ឬក៏រឿងពិត>មួយយ៉ាងដូច្នេះក៏ថាបាន <ដោយមេធាវីការពារក្តីមិនអាចផ្ទៀងផ្ទាត់ ថាតើ>វាទាក់ទងទៅនឹងផ្នែកផ្សេងៗទៀតនៃសៀវភៅនេះយ៉ាងដូចម្តេចដែរ។ ដូច្នេះ ខ្ញុំយល់ឃើញថាការតាំងសំណួរបែបនេះ គឺមិនត្រឹមត្រូវទេ ក្នុងការជ្រើសរើសតែពីរបីកថាខណ្ឌចេញពីសៀវភៅនេះ ហើយរួចហើយយកមកតាំងជាសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ដូច្នេះខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរបែបនេះ។

**លោក យីគាំង លូ៖**

ខ្ញុំសូមឆ្លើយតបទៅនឹងការជំទាស់នេះ។ សៀវភៅនេះ បានដាក់ចូលក្នុងសំណុំរឿងហើយតាំងពីលោកស្រីត្រូវបានទទួលស្គាល់ផ្លូវការជាដើមបណ្តឹងរដ្ឋប្បវេណី។ យើងបានស្នើសុំឱ្យតុលាការធ្វើការបកប្រែជាភាសាអង់គ្លេស។ អ្នកណាក៏មានសិទ្ធិទទួលបានឯកសារនេះដែរ។ ឯកសារទាំងអស់ដែលខ្ញុំប្រើប្រាស់ ដាក់នៅក្នុងសំណុំរឿងតាំងពីមុនខ្ញុំក្លាយជា<>មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមកម្ល៉េះ។ អ្នកៗដទៃទៀតក៏បានអានសៀវភៅនេះដែរ ហើយដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់បានដាក់ឯកសារនេះ ហើយដើម្បីឆ្លើយតាំងពីឆ្នាំទៅមកម្ល៉េះ។ ដូច្នេះបើសិនមេធាវីការពារក្តីចង់<ផ្ទៀងផ្ទាត់>ពីសៀវភៅនេះ <អង្គជំនុំជម្រះអាចជួយបាន ប៉ុន្តែ>ខ្ញុំអត់ដែលបានឃើញសំណើណាមួយជាផ្លូវការពីមេធាវីការពារក្តីនៅឡើយទេមកដល់ម៉ោងនេះ នាទីនេះ។ ខ្ញុំបានទទួលអ៊ីម៉ែលមួយពីមេធាវីការពារក្តី ដែលស្នើឱ្យខ្ញុំផ្តល់ការបកប្រែសៀវភៅនេះជាភាសាអង់គ្លេស ប៉ុន្តែ<ដើម្បីឱ្យច្បាស់> នេះមិនមានន័យថាជាសំណើសុំឱ្យបកប្រែទេ សុំឱ្យផ្តល់ជាភាសាអង់គ្លេស។ លោកស្រី គឺជាអ្នកនិពន្ធដែលមានចំណេះដឹងខ្ពង់ខ្ពស់ម្នាក់។ គាត់សរសេរសៀវភៅច្រើនក្បាលណាស់ ហើយសៀវភៅមួយក្បាលនេះ គាត់ក៏បានស្នើសុំដាក់ឱ្យក្នុងសំណុំរឿង ហើយមេធាវីការពារក្តីសំណើសុំឱ្យផ្តល់នូវការបកប្រែសៀវភៅផ្សេងទៀត មិនមែនសៀវ-ភៅនេះទេ។ អ្វីដែលខ្ញុំបានទទួលព័ត៌មានមកនោះ គឺ<>សំណើសុំនេះ គឺថាមិនអាចដាក់បញ្ជូនមកខ្ញុំផ្ទាល់នោះបានទេ គឺថាត្រូវតែដាក់ យ៉ាងហោចណាស់ក៏ត្រូវដាក់បញ្ជូនតាមរយៈសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ។ ខ្ញុំក៏សម្រេចមិនបានឆ្លើយទៅនឹងអ៊ីម៉ែលរបស់មេធាវីការពារក្តីនោះទេ។

ខ្ញុំសង្ឃឹមថា នេះគឺជាចម្លើយរបស់ខ្ញុំទៅនឹងការបដិសេធ ដើម្បីជូនអង្គជំនុំជម្រះឲ្យបានជ្រាប។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាសម្រេចត្រង់ចំណុចនេះតែម្តង។ សូមអរគុណ។

[១៤:៣៨:៤៥]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអធ្យាស្រ័យលោកប្រធាន ខ្ញុំសូមការបញ្ជាក់។ ប្រហែលជាកំហុសរបស់ខ្ញុំ។ ខ្ញុំសួរទៅវិញតើ<>ដើមបណ្តឹងរដ្ឋប្បវេណីនេះបានសរសេរសៀវភៅពីរក្បាលឬក៏យ៉ាម៉េច? តាមខ្ញុំយល់ ស្មានតែគាត់ហ្នឹងសរសេរសៀវភៅតែមួយក្បាលនេះទេ។

**លោក យីគាំង លូ៖**

បាទ សូមអរគុណច្រើន។ លោកស្រី សុផានី តាមខ្ញុំដឹង គាត់សរសេរសៀវភៅច្រើន<ជាងពីរក្បាល> គាត់មាន<សៀវភៅ>ច្រើន<នៅផ្ទះរបស់គាត់>។ ក្នុងសៀវភៅរបស់គាត់សរសេរបង្ហាញនូវការចងចាំច្រើន ដូចជាសៀវភៅមួយក្បាលនេះជាដើម គឺសរសេរយោងទៅលើបទពិសោធន៍ការចងចាំក៏ដូចជាកំណត់ត្រារបស់គាត់ ហើយបានគាត់សរសេរសៀវភៅនេះឡើង។ សៀវភៅ <"កាលណាយើងជួបគ្នា"> នេះគឺសៀវភៅដែលខ្ញុំមើលទៅគួរឲ្យជឿជាក់បាន ក្នុងនាមជាមេធាវី ខ្ញុំដឹងគឺគាត់សរសេរដោយសំអាងទៅលើអង្គហេតុ គាត់យកអង្គហេតុដាក់នៅក្នុងសៀវភៅដទៃទៀតផងដែរ។ គឺគាត់សរ-សេរដោយសំអាងទៅលើបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហម។ ហើយសៀវភៅដទៃទៀតក៏យោងអង្គហេតុនៅក្នុងរបបខ្មែរក្រហមដែរ តែមិនបានដាក់ទៅក្នុងសំណុំរឿងទេ។ <គាត់សម្រេចជ្រើសរើស>សៀវភៅមួយក្បាលនេះ<> "<កាលណាយើងជួបគ្នា>" <ដាក់ទៅក្នុងសំណុំរឿង តាមរយៈការពិភាក្សាជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដំបូងរបស់គាត់>។ ក្នុងឋានៈខ្ញុំជា<>មេធាវីផងដែរ ខ្ញុំក៏បានសម្រេចយកសៀវភៅនេះ <ដូចការពន្យល់របស់គាត់ ពីមូលហេតុដែលគាត់សម្រេចយកសៀវភៅនេះ> <ខ្ញុំគិតថា រឿងនោះគឺពន្យល់ច្បាស់លាស់ហើយ>។

[១៤:៤០:១៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា ចំពោះនីតិវិធីនៃការធ្វើបែបនេះរបស់មេធាវី ក្រុមមេធាវីការពារក្តី -- ដើមបណ្តឹងរដ្ឋប្បវេណីគឺមិនត្រឹមត្រូវទេ។ ដូច្នេះលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តនីតិវិធីនៃការសួរដេញដោលរបស់ខ្លួនតទៅទៀតចុះ។

**លោក យីគាំង លូ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ បាទ ខ្ញុំសូមស្នើបង្ហាញជូនលោកស្រីសុផានី ទំព័រមួយទៀតនៅសៀវភៅរបស់គាត់ដែលថា "តើកាលណាយើងជួបគ្នាម្តងទៀត"។ ខ្ញុំសូមអាន ERN ជាភាសាខ្មែរ 00562876, 01037340, 01037348។ លោកប្រធាន ខ្ញុំសូមបង្ហាញឯកសារនេះជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក យីគាំង លូ៖**

**ស៖** លោកស្រី សុផានី -- បាទ ចាំឯកសារនេះលេចមកលើអេក្រង់សិន ចាំខ្ញុំតាំងសំណួរទៅកាន់លោកស្រីតែម្តង។ លោកស្រី សុផានី ក្នុងទំព័រនេះមានពីរប្រអប់ ខ្ញុំសូមបង្ហាញប្រអប់ទី២ នៅត្រង់ទំព័រនេះ សូមឱ្យលោកស្រីបញ្ជាក់ជូនអង្គជំនុំជម្រះ តើលោកស្រីសរសេរអំពីអ្វីនៅក្នុងប្រអប់ទី២នេះ?

**លោកស្រី អ៊ុំ សុផានី៖**

**ឆ៖** នៅក្នុងប្រអប់ទី២នេះ ខ្ញុំសរសេរអំពីពេលដែលខ្ញុំឈឺពោះកើតកូន។ ខ្ញុំសរសេរថា៖ "ខ្ញុំចេះតែឈឺពោះ ស្រីម្នាក់ជាប្រធានពេទ្យក៏មកមើលខ្ញុំដែរ។ នាងនោះដល់ឃើញខ្ញុំកើតកូនមិនស្រួលដូចគេដូចឯង ក៏មកពិនិត្យខ្ញុំញឹកញាប់ណាស់។ គេពិនិត្យទៅគេនិយាយថា កូននៅពោះខ្ញុំនេះមិននៅទេ។ បានសេចក្តីថាកូននោះស្លាប់ហើយ។ ខ្ញុំក៏ប្រាប់ពេទ្យថា បើដូច្នេះ ពេទ្យប្រញាប់យកចេញទៅ ខ្ញុំឈឺខ្លាំងណាស់"។

[១៤:៤៣:១២]

**ស៖** តើពេទ្យហ្នឹងគេចាត់ការយ៉ាងម៉េចដែរ ក្រោយពីលោកស្រីប្រាប់ទៅពេទ្យហ្នឹងថា លោកស្រីឈឺខ្លាំងណាស់ឱ្យយកកូនហ្នឹងចេញទៅ បើកូនហ្នឹងស្លាប់?

**ឆ៖** មេពេទ្យនោះនៅក្មេង ខ្ញុំគិតថាប្រហែលជាគ្មានបទពិសោធន៍អ្វីទេ។ បានជាគ្រាន់មកស្ទាបពោះខ្ញុំហើយ វិនិច្ឆ័យថាកូននោះស្លាប់នៅក្នុងពោះ។ ខ្ញុំក៏និយាយថា "សូមពេទ្យយកចេញទៅ ពីព្រោះខ្ញុំឈឺខ្លាំងណាស់" ព្រោះខ្ញុំមិនដែលកើត នេះជាការកើតកូនដំបូង។ បើសិនណាជាពេទ្យ គេមានសមត្ថភាព គេច្បាស់ជាមានវិធីហើយ ប៉ុន្តែនេះពេទ្យអត់មានសមត្ថភាពទេ គឺទុកខ្ញុំចោលតាំងពីខ្ញុំឈឺពោះពេលព្រលឹមថ្ងៃពុធ រហូតដល់ព្រលឹមថ្ងៃព្រហស្បតិ៍ទៀត គឺកើតដោយៗគេហៅថាយថាកម្ម កើតដោយធម្មជាតិមក។ ពេទ្យហ្នឹងអត់មានមធ្យោបាយធ្វើ អសមត្ថភាព។

**ស៖** អ៊ីចឹងមានន័យថា ទារកដែលកើតចេញមកហ្នឹងគឺអត់ទាន់ស្លាប់ទេ អ៊ីចឹងឬក៏យ៉ាងម៉េច លោកស្រី?

**ឆ៖** ចាស ប្រាកដណាស់ គឺថាវារស់ដល់សព្វថ្ងៃនេះ ឈ្មោះ ស៊ូ បុទម។

**ស៖** សូមអរគុណលោកស្រី។ សូមលោកស្រីជម្រាបជូនតុលាការបន្តិចមក <ពី>ពេលដែលលោកស្រីចូលទៅមន្ទីរពេទ្យដើម្បីសម្រាលកូនហ្នឹង។ សូមឲ្យលោកស្រីរៀបរាប់មើលថា តើនៅមន្ទីរហ្នឹងគេមានសេវាពេទ្យហ្នឹងយ៉ាងម៉េចដែរ ហើយគេមានថ្នាំសង្កូវហ្នឹង ឬក៏មិនមានយ៉ាងណានោះដែរ?

[១៤:៤៥:០០]

**ឆ៖** ពេទ្យដែលខ្ញុំទៅសម្រាលកូននោះឈ្មោះហៅថា "ពេទ្យត្រពាំងគល់" ប៉ុន្តែមិនមែនជាពេទ្យទេ គឺតាំងនៅក្នុងវត្ត។ ពេទ្យនោះធ្វើពីឈើ មានខាងត្បូង ខាងជើង ខាងលិច។ ខាងជើង ខាងត្បូង គឺជាអ្នកជំងឺស្រាលចូលទៅ។ ខាងត្បូងជាអ្នកឈឺកើតកូន ចំណែកខាងលិចវិញគឺជាអ្នកជំងឺធ្ងន់។ ជំងឺធ្ងន់ គឺថាតែកាលណាចូលទៅគឺស្លាប់ហើយ។ ភាគច្រើនគឺស្លាប់អត់មានអាចជាមកវិញទេ។ ចំណែកឯមន្ទីរកន្លែងដែលខ្ញុំកើតកូន គឺជាសាលារៀនទេ គេយកធ្វើមន្ទីរពេទ្យហ្នឹង។ គេសាលាវែងអ៊ីចឹង គេគ្រាន់តែបាំងមួយកំណាត់ហ្នឹងធ្វើជាកន្លែងពេទ្យ កន្លែងសម្រាលកូន មួយកំណាត់ទៀតសម្រាប់ស្ត្រីដែលកើតកូនហើយរស់ ដូចថារង់ចាំថ្ងៃចេញមក កើតកូនហើយមកគេងនៅមួយបន្ទប់ជុំគ្នាអ៊ីចឹង។ ហើយគេដុតឧសអ៊ីចឹងទៅឲ្យវា គេហៅថាអាំងភ្លើង ឆេះទៅមានផ្សែង មានអីហ្នឹង គឺទាំងអស់គ្នាហ្នឹងនាំគ្នានៅក្នុងបន្ទប់ហ្នឹងហប់ដោយផ្សែងហ្នឹងទៅ ហើយមន្ទីរពេទ្យហ្នឹងគ្មានបង្គន់ គ្មានមុងគ្មានអីទេ អត់មានអីនេះទេ គឺថាចំណែកឯថ្នាំសង្កូវវិញគឺមានតែថ្នាំមូលៗ ដែលយើងថាថ្នាំអាចម៍ទន្សាយ ដូចថា ខ្មៅៗ វាមិនដឹងថាឈ្មោះថ្នាំអី។ ហើយស៊ីរ៉ូមដែលគេចាក់នោះ ខ្ញុំមិនដឹងថាគេចាក់យកទឹកអីមកទេ ប៉ុន្តែគេដាក់នៅក្នុងដបបេ.ហ្សេ.អ៊ី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី អរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលឈប់សម្រាក។ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមនៅក្នុងបន្ទប់សវនាការកន្លែង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ផ្តល់សក្ខីកម្មនេះវិញ នៅវេលា -- ឲ្យបានមុនម៉ោងបី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៧ នាទី ដល់ម៉ោង ១៥:១៦នាទី)*

[១៥:១៦:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គុយចុះ!

យើងមានបញ្ហានៃសុខភាពរបស់ជនជាប់ចោទ ខៀវ សំផន ដូច្នេះ គឺអង្គជំនុំជម្រះមិនអាចបន្ត កិច្ចដំណើរការសវនាការបានទេ ដោយគាត់បាន -- គ្រូពេទ្យប្រចាំការដែលត្រួតពិនិត្យថែទាំសុខភាពជន ជាប់ចោទនៅ អ.វ.ត.ក នេះ បានផ្តល់អនុសាសន៍ថា គាត់មានបញ្ហាដូច្នេះ ហើយទាមទារឲ្យគាត់ សម្រាក និងបន្តការពិនិត្យព្យាបាលនៅក្នុងអំឡុងពេលរសៀលនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេច ផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែក។ ហើយនៅ ថ្ងៃស្អែកនេះ ខ្ញុំសូមជម្រាបជូនភាគីនិងសាធារណជនជ្រាបថា គឺយើងបន្តដូចសព្វដង គឺចាប់ផ្តើមវេលា ម៉ោងប្រាំបួនព្រឹក។ ហើយនៅព្រឹកថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់របាយការណ៍របស់ អ្នកជំនាញ អំពីលទ្ធផលនៃការពិនិត្យវាយតម្លៃសម្បទាចូលរួមសវនាការរបស់ជនជាប់ចោទ។ ហើយ ទន្ទឹមនឹងនេះផងដែរ ដោយសារការពិនិត្យលើសំណើសុំហ្នឹងគឺមានចំនួនតិច។ អ៊ីចឹង អង្គជំនុំជម្រះប៉ាន់ ស្មានថា ប្រហែលជាកិច្ចដំណើរការសវនាការស្តាប់របាយការណ៍អ្នកជំនាញ ទំនងជាមិនមែនមិនប្រើ ពេលវេលាយូរដូចការគ្រោងទុកទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីដើមបណ្តឹងរដ្ឋ-ប្បវេណី អ៊ុំ សុផានី សូមអញ្ជើញមកជាការត្រៀមបម្រុង ដើម្បីបន្តកិច្ចដំណើរការនីតិវិធី ប្រសិនបើ ពេលវេលាដែលយើងដំណើរការនោះវានៅសេសសល់អាចធ្វើសម្រាប់បញ្ចប់នូវការស្តាប់សក្ខីកម្មរបស់ លោកស្រី។ អ៊ីចឹង អង្គជំនុំជម្រះសូមអញ្ជើញលោកស្រីមកបន្តទៀត ហើយដូចគ្នាដែរ គឺបុគ្គលិកអង្គការ ធី.ភី.អូ ដែលជាជំនួយការ ជំនួយស្មារតីដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការផ្តល់សក្ខីកម្ម ក៏សូមអញ្ជើញ មកដែរ។

បាទ ឥឡូវនេះ គឺអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបទៅកាន់មន្ទីរឃុំឃាំង អ.វ.ត.ក វិញចុះ

ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណី និងបុគ្គលិក ធី.ភី.អូ ត្រឡប់ទៅកាន់លំនៅឋានវិញ ហើយឲ្យអញ្ជើញគាត់ត្រឡប់មកកាន់បរិវេណនៃ អ.វ.ត.ក យើងវិញនេះ នៅចាប់ពីព្រឹកថ្ងៃស្អែកទៅ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:២០នាទី)*